យុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិ

ក្រសួងបរិស្ថាន និង អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន



# របាយការណ៍ស្ថានភាពនៃការអប់រំបរិស្ថាន
# ប្រទេសកម្ពុជា ២០០៥

# មាតិកា


**អារម្ភកថា** ២

**អត្ថបទសង្ខេប** ៣

**បុព្វកថា ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត** ៥

**ការអប់រំបរិស្ថាន** ៧

*សាវតារ* ៧

*ការអភិវឌ្ឍជាអន្តរជាតិលើការអប់រំបរិស្ថាន* ៨

**ការអប់រំបរិស្ថាននៅក្នុងតំបន់** ១១

*ស្ថានភាពបច្ចុប្បន្ននៃការអប់រំបរិស្ថានអាស៊ាន* ១១

*ឧបសគ្គ និង ចន្លោះនៅក្នុងការអនុវត្តគំរោងក្នុងស្រុកលើការអប់រំបរិស្ថាន* ១២

**ស្ថានភាពនៃការអប់រំបរិស្ថាននៅកម្ពុជា** ១៤

*សាវតារ* ១៤

*របាយការណ៍ប្រទេសអាស៊ានលើការអប់រំបរិស្ថាននៅកម្ពុជា* ១៤

*ការអប់រំបរិស្ថាននៅកម្ពុជា* ១៧

*ការអប់រំបរិស្ថាននៅជុំវិញទន្លេសាប* ២០

**វេទិកាពិភាក្សាថ្នាក់ជាតិស្តីពីការអប់រំបរិស្ថាន ឆ្នាំ២០០៥** ២៥

*សុន្ទរកថាបើករបស់ ឯកឧត្តម ស៊ិន វ័ណ្ឌី អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន* ២៥

*ការអប់រំបរិស្ថាន* ២៦

*ការអប់រំក្នុងប្រព័ន្ធ* ២៨

*សំភារៈ និង សកម្មភាពអប់រំបរិស្ថានដែលមានកន្លងមក* ២៩

*ក្រុម ១. ការចូលរួមនៅក្នុងការអប់រំបរិស្ថាន* ៣០

*ក្រុម ២. ការអប់រំបរិស្ថាន និង ការបោះពុម្ពផ្សាយ* ៣១

*ក្រុម ៣. សកម្មភាព និងសំភារៈដែលត្រូវបានប្រើប្រាស់នៅសហគមន៍* ៣១

*ក្រុម ៤. ការអប់រំបរិស្ថាន និងការផ្សព្វផ្សាយព័ត៌មាន* ៣១

*ក្រុម ៥. សកម្មភាពដែលផ្អែកលើការអប់រំបរិស្ថាននៅកម្ពុជា* ៣២

*ឧបសគ្គក្នុងការអនុវត្តការអប់រំបរិស្ថាន* ៣២

*ការធ្វើអោយការអប់រំបរិស្ថានកាន់តែមានប្រសិទ្ធភាព* ៣២

*ការពិភាក្សា និងសេចក្តីសង្ខេប* ៣២

*សុន្ទរកថាបិទរបស់ ឯកឧត្តម ស៊ិន វ័ណ្ឌី អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន* ៣៣

**ការពិនិត្យឡើងវិញ និង អនុសាសន៍** ៣៥

*ការពិនិត្យឡើងវិញ* ៣៥

*អនុសាសន៍* ៣៦

**ឧបសម្ព័ន្ធ ១.** *សាវតារគំរោង-គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប និងវេបនីយដីវមណ្ឌលបឹងទន្លេសាប* ៤០

*គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប* ៤០

*វេបនីយដីវមណ្ឌលបឹងទន្លេសាប* ៤១

**ឧបសម្ព័ន្ធ ២.** *ទស្សនៈទាននៃការអប់រំបរិស្ថាន* ៤៣

**ឧបសម្ព័ន្ធ ៣.** *អន្តការពាក់ព័ន្ធ* ៤៤





# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្តីពីស្ថានភាពនៃការអប់រំបរិស្ថានកម្ពុជានេះ ត្រូវបានរៀបចំឡើងដោយមានការជួយជ្រោមជ្រែង និង គាំទ្រពីអង្គការ ស្ថាប័នរដ្ឋ និងផ្នែកឯកជនជាច្រើនទៀតនៅកម្ពុជា ។ អ្នកនិពន្ធសំខាន់ៗមាន លោក ដេឌី ស្មិត និងលោក គាត ប៊ុនថាន ក្នុងកិច្ចការសហការគ្នាយ៉ាងជិតស្និទ្ធ រួមជាមួយសមាជិកក្រុមរបស់អង្គការ "ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន" នៅកម្ពុជារួមមាន : លោក គ្រីស្ទាន នែលសិន លោក ជុំ សំអូន កញ្ញា ពេជ្រ សុខដានី កញ្ញា អាលិកសិនដ្រា ស៊្វីនសាន់ កញ្ញា ខារីន យ៉ាំង កញ្ញា ជុំ ផលិកា និង លោក ភីធើ ស្តារ ។

របាយការណ៍នេះត្រូវបានបង្កើតឡើង និងសរសេរដាក់ជូនក្រសួងបរិស្ថានទុកជាផ្នែកមួយនៃយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិដែលឋិតនៅផ្នែក១នៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបក្រោមការឧបត្ថម្ភថវិកាពីធនាគារអភិវឌ្ឍន៍អាស៊ី ។ របាយការណ៍នេះធ្វើឡើងដើម្បីឆ្លើយតបនឹងលទ្ធផលជាក់ស្តែងដើម្បីពិនិត្យលើព័ត៌មានជាក់លាក់ពីស្ថានភាពនៃការអប់រំបរិស្ថាននៅកម្ពុជា ។

ការបកប្រែឯកសារនេះជាភាសាខ្មែរពិតជាមិនអាចធ្វើទៅបានបើគ្មានការព្យាយាមពីសមាជិកក្រុមការងាររបស់អង្គការ "ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន" ជាពិសេសកិច្ចប្រឹងប្រែងរបស់ កញ្ញា ពេជ្រ សុខដានី ។

អនុសាសន៍ល្អៗលើរបាយការណ៍នេះយើងបានទទួលពីអង្គការម្លប់បៃតង និង អង្គការសង្គ្រោះសត្វព្រៃ ។ ហើយរបាយការណ៍នេះក៏ត្រូវបានពិនិត្យកែប្រែជាចុងក្រោយដោយលោកបណ្ឌិត នៅ បោនន័រ និង លោក ឡុង ខេង ហើយបើគ្មានការសហការពីកិច្ចប្រឹងប្រែងទាំងនេះទេ ឯកសារនេះក៏នឹងមិនអាចធ្វើទៅបានឡើយ ។

ការជួយគាំទ្រទៅលើសកម្មភាពនេះក៏បានមកពីអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងនេះយើងសូមផ្តោតលើបុគ្គល និង អង្គការនានាដែលបានជួយផ្តល់ជាព័ត៌មានទូទៅ និងករណីសិក្សាមួយចំនួន ។

- លោក លី ខុម : អង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ខេត្តកំពង់ធំ
- លោកស្រី លួយ រស្មីៈ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌
- លោក វ៉ា មឿន លោក ស៊ឹម គង់ លោក សេង វ៉ាន់ដេត : អង្គការម្លប់បៃតង
- កញ្ញា លឹម សូលីន និង លោក ស៊ុន យូរ៉ា : អង្គការសង្គ្រោះសត្វព្រៃ
- លោក ស៊ុន វិសាល : អង្គការអភិរក្សសត្វព្រៃ
- លោក អ៊ូ រតនៈ និង លោក ដួង គង់ : មូលនិធិពិភពលោកដើម្បីអភិរក្សធម្មជាតិ ។ ក្នុងនោះក៏មានមន្ត្រីក្រសួងបរិស្ថានដែលបានជួយក្នុងការចងក្រងរបាយការណ៍នេះ និងចូលរួមជ្រោមជ្រែងក្នុងវេទិកាពិភាក្សាថ្នាក់ជាតិស្តីពី "ការអប់រំបរិស្ថាន" រួមមាន : ឯកឧត្តម ស៊ិន ខ័ណ្ឌី លោក ឡុង ខេង លោក នុប និមល លោក ស៊ុន កុលវីរ៉ា កញ្ញា មាន សុខអូន និង លោក កួច គន្ធាវរៈ ។ យើងក៏សូមលើកពីមន្ត្រីបរិស្ថាន ដែលបានជួយនៅក្នុងការធ្វើរបាយការណ៍ពីការអប់រំបរិស្ថានសំរាប់បណ្តាប្រទេសអាស៊ាននៅឆ្នាំ២០០៣ ដែលក្នុងនេះមាន លោក រត្ន័ សិទ្ធ និង លោក គង់ សៀកលី ។ យើងខ្ញុំក៏សូមធ្វើការកោតសរសើរដល់អ្នកចូលរួមក្នុងវេទិកាពិភាក្សាថ្នាក់ជាតិស្តីពី "ការអប់រំបរិស្ថាន" នៅថ្ងៃ ទី១១ខែវិច្ឆិកា ឆ្នាំ ២០០៥ ។ គួរបញ្ជាក់ថាវេទិកាពិភាក្សាថ្នាក់ជាតិនេះត្រូវបានរៀបចំឡើងដើម្បីស្វែងរកលទ្ធផលបន្ថែមសំរាប់ការសរសេររបាយការណ៍ស្ថានភាពនៃការអប់រំនេះ ។

ក្រសួងអប់រំ យុវជន និងកីឡាក៏បានចូលរួមក្នុងការផ្តួចផ្តើមវេទិកាពិភាក្សាថ្នាក់ជាតិស្តីពី "ការអប់រំបរិស្ថាន" នេះផងដែរ ជាពិសេស លោកស្រី ទន់ សាអ៊ឹម លោកស្រី អ៊ុង គីមសាន និង លោកស្រី ថាច់ ធីសាវ៉ន ដែលបានជួយជ្រោមជ្រែង និងចូលរួមដោយផ្ទាល់ ។ ជាមួយគ្នានេះក៏មានអ្នកសំរបសំរួលដែលមកពីអង្គការផ្សេងទៀតដូចជា លោកស្រី ម៉ាន ម៉ាលី សៅ សម្បត្តមរកត មីន ឃីម និង ញ៉ែម នីតា ។

ជាទីបញ្ចប់ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់គ្រប់អ្នកចូលរួមនៅក្នុងសកម្មភាពផ្សេងៗទៀត ។ របាយការណ៍នេះនឹងមិនអាចធ្វើទៅបានទេបើគ្មានការសហការយ៉ាងសកម្មពីបណ្តាអ្នកអប់រំបរិស្ថានទាំងអស់ ហើយយើងរំពឹងថានឹងអាចបន្តកិច្ចសហការនេះបន្តទៀត និងសង្ឃឹមថា ឯកសារនេះជាឧបករណ៍ដែលអាចផ្តល់ជាប្រយោជន៍សំរាប់យើងទាំងអស់គ្នា ។



# ការអប់រំ និងការរៀនសូត្រជាគ្រឿងផ្សំគន្លឹះសំរាប់ ឈានទៅដល់ភាពប្រសើរឡើងនៃប្រសិទ្ធភាព

## អត្ថបទសង្ខេប


នៅក្នុងកិច្ចព្រមព្រៀងដែលចុះនៅថ្ងៃទី៦ ខែមិថុនាឆ្នាំ២០០៥ ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តអោយអង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន(Live&Learn) ធ្វើការអនុវត្តន៍លើយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិ (NEEAC) ដែលឋិតនៅក្រោមផ្នែក១ នៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប(TSEMP) ដែលផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ីក្រោមប្រាក់កំចីដែលមានលេខកូដ ១៩៣៩ CAM (SF) ។ យុទ្ធនាការនេះនឹងធ្វើការកសាងចំណេះដឹងមូលដ្ឋាន និងលទ្ធផលដែលបានពីអង្គការLive&Learnដែលផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការធ្វើការវាយតំលៃរហ័សលើការយល់ឃើញនៅឆ្នាំ ២០០៤ និងកិច្ចខិតខំប្រឹងប្រែងរបស់អង្គការដែលពាក់ព័ន្ធនឹងការអប់រំបរិស្ថានផ្សេងទៀត ។ វានឹងត្រូវបានធ្វើឡើងដើម្បីធ្វើអោយប្រសើរឡើងលើការយល់ដឹងពីបញ្ហាបរិស្ថាននៅកំរិតផ្សេងៗក្នុងប្រទេសកម្ពុជា ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើប្រព័ន្ធអេកូឡូស៊ីទាំងមូលនៃបឹងទន្លេសាប ។

ការអប់រំ និងការរៀនសូត្រជាគ្រឿងផ្សំគន្លឹះសំរាប់ឈានទៅដល់ភាពប្រសើរឡើងនៃប្រសិទ្ធភាព ។ នៅក្នុងការបង្កើនការយល់ដឹងអំពីបរិស្ថានដែលកំពុងត្រូវបានប្រើប្រាស់ក្នុងរូបភាពអវិជ្ជមានតាមរយៈសកម្មភាពរបស់មនុស្ស បានក្លាយជាការផ្តោតជាសំខាន់ថា តើយើងត្រូវកាត់បន្ថយផលប៉ះពាល់របស់យើងលើបរិស្ថានបានតាមវិធីណាដើម្បីជំរុញទៅកាន់អនាគតដែលប្រកបដោយចីរភាព ។ ទំរង់នៃការអប់រំនេះឋិតនៅក្រោមប្រធានបទជាច្រើនក្នុងផ្នែកនៃការអប់រំបរិស្ថាន ។ ការអប់រំបរិស្ថានត្រូវបានជំរុញយ៉ាងសកម្មនៅក្នុងផ្នែកនៃសន្និសិទអន្តរជាតិកាលពី៣០ឆ្នាំមុន ជាពិសេសទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍ក៏បានជំរុញលើការប្រើប្រាស់ការអប់រំដើម្បីឈានឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាពនេះផងដែរ ។ ថ្មីៗនេះសន្និបាតអង្គការសហប្រជាជាតិបានប្រកាសពីទសវត្សរ៍នៃការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចីរភាពសំរាប់ឆ្នាំ ២០០៥-២០១៤ "ដោយលើកឡើងថា ការអប់រំជាផ្នែកមួយមិនអាចខ្វះបានដើម្បីទទួលបានការអភិវឌ្ឍដែលប្រកបដោយចីរភាព" ។ នៅក្នុងតំបន់មានសកម្មភាពខ្លះដែលត្រូវបានចាត់ទុកថាជាការអប់រំបរិស្ថាន ដូចដែលសមាជិកនៃប្រទេសអាស៊ានធ្វើការលើកឡើងថាពួកគេកំពុងរស់នៅក្នុងប្រទេសដែលស្អាត និងមានព៌ណបៃតង ដែលមាននៅក្នុងប្រពៃណីវប្បធម៌(ជាចំនុចដែលគុណតំលៃ និងការអនុវត្តរបស់ប្រជាជនឋិតនៅក្នុងភាពស៊ីសង្វាក់ និងស្របទៅនឹងធម្មជាតិ) ជាមួយប្រជាជនដែលមានការយល់ដឹងលើបរិស្ថាន ការជ្រួតជ្រាបពីក្រមសីលធម៌បរិស្ថាន ឆន្ទៈ និងសមត្ថភាពដើម្បីធានានូវការអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់តាមរយៈការអប់រំបរិស្ថាន និង លទ្ធភាពនៃការចូលរួមជាសាធារណៈ ។

មុនសង្គ្រាម ប្រទេសកម្ពុជាជាប្រទេសដែលនាំមុខនៅក្នុងតំបន់លើអក្ខរកម្ម និងការអប់រំខ្ពស់ និងនៅឆ្នាំ១៩២៥ កម្ពុជាបានបង្កើតតំបន់ការពារដំបូងគេ តែជាអកុសលប៉ុន្មានឆ្នាំនៃសង្គ្រាមបានធ្វើអោយរេចរឹលលើមូលដ្ឋានល្អៗនៃការអប់រំនេះ ។ ការអប់រំបរិស្ថាននៅកម្ពុជាមានប្រវត្តិទាក់ទងខ្លីមួយដែលការសង្ខេបឯកសារប្រវត្តិសាស្ត្របង្ហាញថា គោលការណ៍នៃការអប់រំបរិស្ថានត្រូវបានបញ្ចូលជាដំបូងទៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាលជាមួយនឹងការបង្កើតក្រសួងបរិស្ថាននៅឆ្នាំ ១៩៩៣ ។ ចាប់ពីពេលនោះមកវាបាននបង្កើននូវការគាំទ្រពីសហគមន៍ផ្តល់ជំនួយ និង ត្រូវបានស្គាល់ថាជាវិធីសាស្ត្រដែលសំខាន់នៅក្នុងការកាត់បន្ថយបញ្ហាបរិស្ថានផ្សេងៗ ដែលកំពុងប៉ះពាល់ដល់ប្រទេសទាំងមូល ។

នេះជាការធ្វើសមាហរណកម្មការអប់រំបរិស្ថានទៅក្នុងផ្នែកខ្លះនៃការអប់រំក្នុងប្រព័ន្ធ ទោះជាយ៉ាងណា សកម្មភាពក្រៅប្រព័ន្ធទៅបានបង្កើតអោយមានការលេចឡើងនូវការអប់រំបរិស្ថាននៅកម្ពុជា ។ ជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសំរាប់ការអប់រំបរិស្ថានត្រូវបានផ្តល់ឲ្យតាមរយៈរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានាចាប់ពីឆ្នាំ១៩៩៣មក ។

អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងបុគ្គលិករដ្ឋាភិបាលដែលធ្វើការនៅក្នុងផ្នែកនៃការអប់រំបរិស្ថាននៅពាសពេញប្រទេស ។ ការអប់រំបរិស្ថានចាប់ផ្តើមនៅក្នុង និងនៅជុំវិញឋបនីយជីវមណ្ឌលបឹងទន្លេសាបក្នុងទំហំតូច និងតាមសហគមន៍ក្នុង

# វិធីសាស្ត្រល្អបំផុតដើម្បីធ្វើការផ្លាស់ប្តូរ អាកប្បកិរិយាអ្នកដទៃគឺយើងត្រូវធ្វើការ នាំមុខគេដោយធ្វើជាគំរូជាមុន



តំបន់គោលដៅ គ្រូបង្រៀន និងសិស្សបឋមសិក្សា ។ អ្នកផ្តួចផ្តើមលើការអប់រំបរិស្ថានដែលមានកន្លងមករួមមាន អង្គការអូស្ទូស អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ នៅក្នុងខេត្តសៀមរាប អង្គការម្លប់បៃតង និងអង្គការសង្រ្គោះសត្វព្រៃ និង អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live & Learn ដែលថ្មីៗនេះបានក្លាយជាអង្គការមួយនៅកម្ពុជា ដែលអង្គការនេះធ្វើការផ្តោតលើការអប់រំបរិស្ថាន នៅក្នុងតំបន់ទន្លេសាប) ។ ផ្នែកនៃករណីសិក្សាដែលបានពីអង្គការផ្សេងៗរួមមាន ៖ អង្គការព្រះពុទ្ធសាសនាសំរាប់អភិវឌ្ឍន៍ខេត្តកំពង់ធំ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ អង្គការម្លប់បៃតង អង្គការសង្រ្គោះសត្វព្រៃ អង្គការអភិរក្សសត្វព្រៃ អង្គការមូលនិធិពិភពលោកដើម្បីអភិរក្សធម្មជាតិ ដែលជួយបង្ហាញពីវិធីសាស្ត្រផ្សេងៗ និងភូមិសាស្ត្រ ដែលកំពុងអនុវត្តការអប់រំបរិស្ថាននៅក្នុងប្រទេសកម្ពុជា ។ វេទិកាថ្នាក់ជាតិស្តីពីការអប់រំបរិស្ថានត្រូវបានធ្វើឡើងនៅខែវិច្ឆិកា ឆ្នាំ២០០៥ ជាមួយនឹងគោលបំណងពីរគឺ ៖ ១-ធ្វើការបង្កើនការយល់ដឹងអោយកាន់តែប្រសើរលើស្ថានភាពនៃការអប់រំបរិស្ថាននៅកម្ពុជា ដោយរួមទាំងគំនិតរបស់អ្នកអប់រំនៅកម្ពុជាលើថាតើយើងគួរតែធ្វើការនាំមុខដោយវិធីណា ២-ផ្តល់ឱកាសដល់អ្នកអប់រំក្នុងការបង្កើតជាបណ្តាញ និងទំរង់ដែលទាក់ទងនឹងកិច្ចសហការនៅថ្ងៃមុខលើសកម្មភាពអប់រំបរិស្ថាន ។ បញ្ហាជាច្រើនត្រូវបានលើកឡើងដោយក្រុមផ្សេងៗទោះជាយ៉ាងណាបញ្ហាដែលត្រូវបានលើកឡើងជាទូទៅនោះគឺទៅលើភាពមានកំរិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ធនធានមនុស្ស កិច្ចសហប្រតិបត្តិការ ភាសា ថវិកា និង សំភារៈ ។ ភាពមានកំរិតនៃក្រុមសីលធម៌បរិស្ថាន នៅក្នុងចំណោមប្រជាជន ការអនុវត្តច្បាប់នៅមានកំរិត និង អំពើពុករលួយត្រូវបានចាត់ទុកថាជាបញ្ហាសំខាន់ក្នុងការឈានទៅកាន់ប្រសិទ្ធភាពនៃការអប់រំបរិស្ថាន ។

វិធីសាស្ត្រដែលបានលើកឡើងដោយក្រុមផ្សេងៗដើម្បីធ្វើអោយការអប់រំបរិស្ថានកាន់តែមានប្រសិទ្ធភាពគឺ ៖ ការចូលរួមអោយបានច្រើនថែមទៀត ការប្រកបរបរចិញ្ចឹមជីវិត កិច្ចសហការ ការកាត់បន្ថយអំពើពុករលួយ ការពង្រឹងច្បាប់ ការប្រើប្រាស់សារព័ត៌មានអោយបានច្រើន ការបណ្តុះបណ្តាល ការបង្អួលបង្ហាញ ការកំសាន្ត និងការលើកទឹកចិត្ត នឹងធ្វើឡើងសំរាប់ជនគោលដៅតាមរយៈការប្រើភាសាសាមញ្ញជាដើម ។

វិធីសាស្ត្រជាយុទ្ធសាស្ត្រដើម្បីអប់រំបរិស្ថាន នឹងតំរូវអោយមានការលើកឡើងពីកិច្ចការនៅក្នុងតំបន់គោលដៅមួយចំនួន ។ ការប្រមូលព័ត៌មាន និងវេទិកាពិភាក្សាថ្នាក់ជាតិស្តីពី "ការអប់រំបរិស្ថាន" ត្រូវបានរួមគ្នាដើម្បីបង្កើតនូវយុទ្ធសាស្ត្រទាំងនេះ ។

**ក្រុមគោលដៅ** ៖ នៅពេលបង្កើតសកម្មភាព និងសំភារៈ យើងចាំបាច់ត្រូវគិតគូរពីជនគោលដៅតើអ្វីដែលគេចង់ធ្វើ ។

**ភាសា** ៖ យើងមិនអាចប្រើភាសាដែលមិនត្រឹមត្រូវ រឺជាហេតុផលដែលមិនអាចធ្វើទៅបាន តែយើងត្រូវប្រុងប្រយ័ត្នជាមួយព័ត៌មានដែលយើងប្រើ និងថាតើត្រូវបកប្រែយ៉ាងដូចម្តេច

**អត្ថន័យ** ៖ យើងអាចធ្វើការផ្លាស់ប្តូរដោយយោងលើវិធីសាស្ត្រផ្សេងៗដើម្បីបង្កើនការយល់ដឹង ចំណេះដឹង និងភាពសកម្មដែលផ្តោតលើការសង្កត់ធ្ងន់លើបញ្ហានៃការផ្លាស់ប្តូរអាកប្បកិរិយា ។

**ការផ្សព្វផ្សាយ** ៖ ពួកយើងចាំបាច់ត្រូវធ្វើការប្រើប្រាស់អោយកាន់តែប្រសើរនូវការគ្រប់គ្រងធនធានមានតំលៃទាំងអស់នៅក្នុងការពង្រីកអត្ថន័យ និងសកម្មភាពរបស់យើង ។

**លទ្ធផល** ៖ ជាមួយនឹងទស្សនៈដែលកាន់តែរឹងមាំនៃអ្វីដែលយើងចង់បានដើម្បីទទួលបានក្នុងរយៈពេលវែង នោះសកម្មភាព និងសំភារៈរបស់យើងនឹងកាន់តែមានប្រសិទ្ធភាព ។

**ការសំរបសំរួល** ៖ ជាជាងការធ្វើការត្អូញត្អែរពីកង្វះខាតនៃការសំរបសំរួល ចូរយើងធ្វើការនាំមុខដោយធ្វើជាគំរូ និងធ្វើការងារជាមួយគ្នា ។

**ការវាយតំលៃ** ៖ ជាមួយការវាយតំលៃដែលត្រូវបានបង្កើនឡើង យើងនឹងធ្វើឲ្យការអប់រំបរិស្ថានកាន់តែមានប្រសិទ្ធភាព ។

**ការតាំងចិត្ត** ៖ វិធីសាស្ត្រល្អបំផុតដើម្បីធ្វើការផ្លាស់ប្តូរអាកប្បកិរិយាអ្នកដទៃគឺយើងត្រូវធ្វើការនាំមុខគេដោយធ្វើជាគំរូជាមុន ។

**ដំណើរដ៏វែងឆ្ងាយបំផុត ចាប់ផ្តើមឡើងជាមួយនឹងជំហានដំបូងក្នុងទិសដៅដែលត្រឹមត្រូវ ។**





# អារម្ភកថា

# ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត



រាជរដ្ឋាភិបាលកម្ពុជា គឺជាហត្ថលេខីមួយ ចំពោះកិច្ចព្រមព្រៀង និងអនុសញ្ញាអន្តរជាតិជាច្រើនដែលទាក់ទងនឹងបរិស្ថាន និងការអភិវឌ្ឍ ។ ក្នុងនោះការអប់រំបរិស្ថាន គឺជាឧបករណ៍សំខាន់មួយដែលត្រូវបានបញ្ចូលទៅក្នុងវិធីសាស្ត្រអន្តរជាតិទាំងនោះ ។ ការរៀបចំរបាយការណ៍ស្តីពីស្ថានភាពនៃការអប់រំបរិស្ថាននេះនឹងជួយដល់កម្ពុជាក្នុងការប្រើប្រាស់ការអប់រំបរិស្ថានទុកជាឧបករណ៍មួយសំរាប់ការអភិវឌ្ឍប្រកបដោយចេរភាព ។ របាយការណ៍នេះត្រូវបានធ្វើឡើងស្របពេលជាមួយនឹងការចាប់ផ្តើមទសវត្សរ៍នៃការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចេរភាព (២០០៥-២០១៤) របស់អង្គការសហប្រជាជាតិ ។ កំឡុងពេលនៃការសរសេររបាយការណ៍នៅឆ្នាំ ២០០៥ ប្រទេសកម្ពុជាកំពុងឋិតក្នុងស្ថានភាពរឹងមាំមួយក្នុងការប្រើប្រាស់ទសវត្សរ៍នេះដើម្បីជំរុញការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចេរភាពនៅទូទាំងប្រទេស ។

ក្រសួងបរិស្ថានបានទទួលការគាំទ្រផ្នែកបច្ចេកទេសពីអង្គការ "ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន" សំរាប់ការចងក្រងរបាយការណ៍ស្តីពីស្ថានភាពនៃការអប់រំបរិស្ថាន ។ របាយការណ៍នេះគឺជាផ្នែកមួយនៃយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិដែលត្រូវបានបង្កើតឡើងសំរាប់ផ្នែក១នៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ។

គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបជាគំរោងមួយមានសារៈសំខាន់ធំធេងសំរាប់បឹងទន្លេសាបដែលជាបឹងទឹកសាបធំជាងគេនៅអាស៊ីអាគ្នេយ៍ ។ បឹងទន្លេសាបនេះបានផ្តល់នូវផលិតភាពផលផលច្រើនបំផុតនៅលើពិភពលោក និងបានផ្តល់ដោយផ្ទាល់សំរាប់សកម្មភាពនៃការប្រកបរបរចិញ្ចឹមជីវិតដល់ប្រជាជនកម្ពុជាប្រមាណ១១% ។ តួលេខនេះមួយគត់បានបង្ហាញពីតំលៃ និងគុណភាពដែលប្រជាជនកម្ពុជាអាចពឹងអាស្រ័យនៅពេលអនាគត ។ ការដាក់បឹងទន្លេសាបទៅក្នុងប្រព័ន្ធបំរុងជីវមណ្ឌលបឹងទន្លេសាបបានកត់សំគាល់ថែមទៀតពីអាងស្តុកនៃជីវៈចំរុះមានតំលៃជាសាកល និងបានទទួលស្គាល់អំពីលក្ខណៈពិសេសនៃបរិស្ថាន អេកូឡូស៊ី និងសារៈសំខាន់នៃបឹងចំពោះសង្គម និងវប្បធម៌ ។ ការអប់រំបរិស្ថាននឹងដើរតួនាទីសំខាន់នៅក្នុងការធានាបាននូវបរិស្ថានបឹងទន្លេសាបនៅថ្ងៃអនាគត ។

ការយកចិត្តទុកដាក់របស់គំរោងទៅលើការអប់រំបរិស្ថានជាសក្ខីភាពរបស់រដ្ឋាភិបាលក្នុងការបញ្ជាក់ថាការអប់រំបរិស្ថានគឺជាឧបករណ៍ដ៏សំខាន់នៅក្នុងការគ្រប់គ្រងបរិស្ថាន ។ របាយការណ៍នេះបានប្រមូលនូវព័ត៌មានដែលមានកន្លងមក និងព័ត៌មានបច្ចុប្បន្នទាក់ទងនឹងការអប់រំបរិស្ថាននៅកម្ពុជា ។ របាយការណ៍បានដកស្រង់នូវព័ត៌មានរបស់ក្រសួងបរិស្ថានសំរាប់បញ្ជីសារពើភ័ណ្ឌនៃការអប់រំបរិស្ថានអាស៊ាន ការជួបប្រជុំជាមួយមន្ត្រីអប់រំបរិស្ថាន និងបានមកពីវេទិកាពិភាក្សាថ្នាក់ជាតិស្តីពី "ការអប់រំបរិស្ថាន" ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៥ ដែលប្រភពព័ត៌មានទាំងនេះធ្វើឲ្យយើងប្រមូលបានទិន្នន័យពាក់ព័ន្ធពីស្ថានភាពបច្ចុប្បន្ននៃការអប់រំបរិស្ថាននៅកម្ពុជា ។ ជាមួយនឹងការយល់ដឹងកាន់តែប្រសើរពីអ្នកដែលពាក់ព័ន្ធនៅក្នុងការអប់រំបរិស្ថាន និងអ្វីដែលពួកគេកំពុងធ្វើ ។ យើងមានឱកាសធ្វើកិច្ចសហការ និងកិច្ចប្រតិបត្តិការដែលប្រកបដោយប្រសិទ្ធភាពរវាងអ្នកអនុវត្តការងារនេះ ។

ខ្ញុំសូមជូនពរអោយអ្នកអប់រំបរិស្ថានគ្រប់គ្នាដែលរបាយការណ៍នេះបានលើកឡើងឲ្យសំរេចបាននូវជោគជ័យនៅក្នុងការងារនេះ ។ ខ្ញុំសូមលើកទឹកចិត្តចំពោះការបង្កើនការយល់ដឹងចំនេះដឹង និងអាកប្បកិរិយារបស់ប្រជាជន ហើយព្រមគ្នានេះដែរត្រូវខិតខំឆ្ពោះទៅរកការបង្កើនជំនាញ និងការប្រើប្រាស់ចំនេះដឹងតាមរយៈសកម្មភាពវិជ្ជមានទៅលើបរិស្ថានផងដែរ ។ ខ្ញុំសូមអោយយើងធ្វើការរួមគ្នានៅក្នុងទឹកចិត្តសហការ ដូចនេះយើងអាចប្រើប្រាស់ធនធានបានកាន់តែប្រសើរដើម្បីជំរុញការ





ផ្សព្វផ្សាយពីបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចេរភាពអោយមានប្រសិទ្ធភាព ។ សាររបស់ខ្ញុំទៅកាន់ប្រជាជនទាំងអស់គ្នាគឺគុណភាពជីវិតរបស់ពួកយើងអាស្រ័យលើការប្រើប្រាស់ដែលគិតគូរពីបរិស្ថាន ពួកយើងត្រូវការពារបរិស្ថានដើម្បីអនាគតយើងទាំងអស់គ្នា ។ ពួកយើងត្រូវការការប្រើប្រាស់ការអប់រំបរិស្ថានអោយមានប្រសិទ្ធភាពដើម្បីធ្វើឲ្យប្រជាជនមិនត្រឹមតែយល់ពីសារៈសំខាន់បរិស្ថានប៉ុណ្ណោះទេតែក៏បានអនុវត្តលើការយល់ដឹងនេះផងដែរដើម្បីសំដៅធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមានទៅលើអាកប្បកិរិយារបស់ពួកគេ ។

គន្លឹះដើម្បីការពារបរិស្ថានគឺផ្អែកលើការចូលរួមជាសាធារណៈពីគ្រប់ជាន់ថ្នាក់ ការជំរុញភាពជាកម្មសិទ្ធរបស់ពួកគេ សមត្ថភាពពេញលេញ និងឆន្ទៈនយោបាយរួមជាមួយការគាំងចិត្តពីរដ្ឋាភិបាលនៅក្នុងការការពារបរិស្ថាន ។ ការចូលរួមនេះនឹងកើតមាននៅពេលប្រជាជនមានការយល់ដឹងពិតប្រាកដ និងស្គាល់ពីសារៈសំខាន់នៃបរិស្ថានសំរាប់កូនចៅជំនាន់ក្រោយ និងសំរាប់យើងទាំងអស់គ្នា ហើយក្នុងន័យនេះការអប់រំបរិស្ថាននឹងជួយជំរុញនូវការយល់ដឹងនេះ ។

ភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៦
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត**



## របាយការណ៍សង្ខេប

គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបត្រូវបានផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី ភ្នាក់ងារអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងទឹកប្រាក់សរុបចំនួន ២០លានដុល្លាអាមេរិក ។ គំរោងនេះត្រូវបានគេអនុម័តនៅ ឆ្នាំ២០០២ ជាមួយនឹងផ្នែកទាំង៣នៃគំរោងគឺ ៈ ការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ ការរៀបចំសហគមន៍ និងការអភិរក្សជីវៈចំរុះនៅឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ (ឧបសម្ព័ន១)

គំរោងគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាបមានសកម្មភាពចំបងធំៗពីរដែលទាក់ទងនឹងការអប់រំបរិស្ថាន ។ សកម្មភាពមួយក្នុងចំនោមសកម្មភាពទាំងពីរគឺការរៀបចំ និងអនុវត្តយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិ ។ គោលបំនងចំបងនៃយុទ្ធនាការនេះ គឺធ្វើការគាំទ្រដល់ផ្នែកទី១នៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបតាមរយៈគំរោងសំរបសំរួល និងកសាងយន្តការផ្សព្វផ្សាយព័ត៌មានមូលដ្ឋាននៃចំនេះដឹង និងលទ្ធផលដែលទទួលបានពីការវាយតំលៃរហ័សលើការយល់ដឹង(RAP) និងកិច្ចប្រឹងប្រែងក្នុងការអប់រំបរិស្ថាននៅក្នុងតំបន់ដែលពាក់ពន្ធ័ ។ ចំពោះសកម្មភាពចំបងមួយផ្សេងទៀតនោះ គឺកម្មវិធីផ្សព្វផ្សាយ និងអប់រំបរិស្ថានដោយចុះផ្ទាល់ដល់មូលដ្ឋានដែលអនុវត្តដោយគំរោងអភិរក្សបឹងទន្លេសាបឋិតនៅផ្នែក៣នៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ។

នៅក្នុងកិច្ចព្រមព្រៀងនៅថ្ងៃទី ០៦ មិថុនា ឆ្នាំ ២០០៥ ក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជាបានកំនត់អោយអង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថានអនុវត្តលើយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិដែលឋិតនៅក្នុងផ្នែក១នៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP) ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ថវិកាកំចីដែលមានលេខកូដ១៩៣៩ CAM (SF) ដល់គំរោងនេះ ។ យុទ្ធនាការនេះនឹងបញ្ចូលទាំងវិធីសាស្ត្រអប់រំបរិស្ថានផ្សេងៗមាន ៈ ការសំដែងល្ខោន ការផ្សាយតាមវិទ្យុ ទូរទស្សន៍ ការពិនិត្យលើកម្មវិធីសិក្សា និងការអនុវត្តជាក់ស្តែង ។ អ្នកពាក់ព័ន្ធថ្នាក់តំបន់ និងថ្នាក់ជាតិនឹងដើរតួនាទីសំខាន់នៅក្នុងការបង្កើត និងអនុវត្តយុទ្ធនាការនេះ ។





យុទ្ធនាការនេះសំដៅធ្វើអោយប្រសើរឡើងនូវការយល់ដឹងលើបញ្ហាបរិស្ថាននៅក្នុងកំរិតផ្សេងៗនៃសង្គមកម្ពុជា ជាមួយនិងការផ្ដោតជាសំខាន់លើប្រព័ន្ធអេកូឡូស៊ីទន្លេសាបទាំងមូល ហើយក៏នឹងផ្ដោតលើគោលគំនិតបរិស្ថាន សេដ្ឋកិច្ច និងផ្នែកសង្គមនៃប្រព័ន្ធអេកូឡូស៊ីដែលវាជាប្រភពផ្ដល់ស្បៀងជលសាស្ត្រពិសេសរបស់វា ក៏ដូចជាបញ្ហាដែលត្រូវប្រឈមមុខផងដែរ ។ យុទ្ធនាការនេះនឹងធ្វើការប្រើលក្ខណៈពិសេសរបស់បឹងទន្លេសាប ដើម្បីបង្ហាញពីភាពចាំបាច់នៃការប្រើប្រាស់ដែលរក្សាបាននូវចេរភាព និងការគ្រប់គ្រងធនធានធម្មជាតិនៅកម្ពុជា ។

យុទ្ធសាស្ត្ររបស់យុទ្ធនាការនេះចាប់ផ្ដើមដោយធ្វើការស្វែងយល់អោយកាន់តែច្បាស់ពីស្ថានភាពអប់រំបរិស្ថាននៅកម្ពុជា ដើម្បីបញ្ចូលទៅក្នុងលទ្ធផលទី១ដែលផ្ដោតលើការបង្ហាញពីព័ត៌មាន និងស្ថានភាពនៃការអប់រំបរិស្ថាន ។ គោលបំណងនៃរបាយការណ៍នេះគឺដើម្បីឆ្លើយតបនឹងលទ្ធផលទី១នេះ និងបន្ទាប់មកគឺដើម្បីផ្ដល់ជាឯកសារយោងសំរាប់ការអប់រំបរិស្ថាននៅទូទាំងប្រទេសកម្ពុជា ។ របាយការណ៍នេះជាលទ្ធផលជាក់ស្ដែងដែលបានពីការប្រមូលព័ត៌មានលើគំនិតផ្ដួចផ្ដើមការអប់រំបរិស្ថានដែលមានតាំងពីមុន និងបច្ចុប្បន្ននៅកម្ពុជា ។ លទ្ធផលដែលទទួលបាននឹងត្រូវបានប្រើប្រាស់ដោយផ្ទាល់នៅក្នុងការជំរុញប្រសិទ្ធភាពនៃការអនុវត្តរបស់យុទ្ធនាការផ្សព្វផ្សាយនិងអប់រំបរិស្ថានថ្នាក់ជាតិ ។

សក្ដានុពលនៃផលប្រយោជន៍ដែលបានមកពីរបាយការណ៍នេះក៏រួមមាន ៖ ផ្ដល់ទំនាក់ទំនងល្អរវាងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល បង្កើនកិច្ចប្រតិបត្តិការ បន្ថយនូវការអនុវត្តលើការងារដែលមានលក្ខណៈជាន់គ្នា បង្កើនប្រសិទ្ធភាពនៅក្នុងបណ្ដាញអ្នកពាក់ព័ន្ធ និងជាពិសេសធ្វើអោយការអប់រំបរិស្ថាននៅកម្ពុជាកាន់តែមានប្រសិទ្ធភាព ។

# ការអប់រំបរិស្ថាន

## សាវតារ

មនុស្សលោកក៏ដូចភាវៈផ្សេងៗទៀតពឹងអាស្រ័យលើធនធានធម្មជាតិដែលជាធនធានចាំបាច់នៃជីវិតរស់នៅ ។ ភាគច្រើនការអភិវឌ្ឍរបស់មនុស្សជាសំខាន់ត្រូវបានគិតពីវិធីទាញយកធនធានទាំងឡាយពីបរិស្ថាន ដូចជាឧបករណ៍ធ្វើពីថ្ម សំភារៈកសិកម្ម និងឧស្សាហកម្ម ។ល ។ កន្លងមកមនុស្សបានកែប្រែយ៉ាងមានប្រសិទ្ធភាពក្នុងការទាញយកធនធានមកប្រើប្រាស់ដែលនេះជាហេតុផលចំបងមួយក្នុងការធ្វើអោយមនុស្សមានឥទ្ធិពលលុបលើភាវៈផ្សេងទៀត ។ សមត្ថភាពក្នុងការទាញយកធនធានធម្មជាតិនេះត្រូវបានចែករំលែកគ្នាយ៉ាងសកម្មក្នុងចំនោមប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅថ្ងៃមុខតាមរយៈការអប់រំនិង ការរៀនសូត្រ ។ ជាអកុសលការទាញយកផលពីធនធានរបស់យើងបានធ្វើអោយបាត់បង់ចេរភាពដូចជា ការប្រែប្រួលបរិស្ថានដែលយើងរស់នៅ និងកាត់បន្ថយនូវផលិតភាពរបស់បរិស្ថានសំរាប់ពេលអនាគត ។ ក្នុងការដោះស្រាយបញ្ហាដែលបណ្ដាលមកពីការប្រព្រឹត្តិដែលធ្វើអោយបាត់បង់ចេរភាព ជាហេតុធ្វើឲ្យមានការជំរុញជាលក្ខណៈអន្តរជាតិមួយដើម្បីឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចេរភាព ហើយបច្ចុប្បន្នយើងត្រូវការការអប់រំដើម្បីជួយយើងអោយឈានទៅកាន់គោលដៅនេះ ។ ***ការអប់រំ និងការរៀនសូត្រ គឺជាគ្រឿងផ្សំសំខាន់ក្នុងការធ្វើអោយមានបំលាស់ប្ដូរទៅកាន់លក្ខណៈចេរភាព ។***

ការឆ្លើយតបទៅនឹងការយល់ដឹងកាន់តែច្បាស់ពីបរិស្ថានដែលកំពុងត្រូវបានទទួលរងនូវឥទ្ធិពលអវិជ្ជមានដែលបង្កដោយសកម្មភាពមនុស្ស ផ្នែកជាក់លាក់មួយនៃការអប់រំបានបង្វែរទៅរកវិធីដើម្បីកាត់បន្ថយឥទ្ធិពលរបស់យើងចំពោះបរិស្ថានក្នុងគោលបំណងធានាដល់ចេរភាពនៅពេលអនាគត ។ វិធីនៃការអប់រំនេះឋិតនៅក្រោមការចងក្រងប្រធានបទជាច្រើនក្នុងទំរង់នៃការអប់រំបរិស្ថាន ។ ទោះបីជាមិនត្រូវបានគេយល់ច្បាស់នៅពេលដែលពាក្យនៃការអប់រំបរិស្ថានត្រូវបានគេប្រើប្រាស់ដំបូង តែរហូតដល់ឆ្នាំ១៩៧៨ វាត្រូវបានគេជ្រើសយកមកប្រើកាន់តែច្រើន



# ការអប់រំបរិស្ថានត្រូវបានក្លាយជាឧបករណ៍គន្លឹះដែលចាត់ទុកថាមានសារៈសំខាន់សំរាប់ការផ្លាស់ប្តូរជាអន្តរជាតិក្នុងការឆ្ពោះទៅរកការគ្រប់គ្រងបរិស្ថានអោយកាន់តែប្រសើរឡើង

ទៅៗ ។ នៅក្នុងដំណាក់កាលនោះ សន្និសីទអន្តរជាតិសំរាប់ការអប់រំបរិស្ថានត្រូវបានរៀបចំឡើងនៅទីក្រុង Tbilisi (1978) ដែលត្រូវបានចាត់ទុកថាជាសន្និសីទអន្តររដ្ឋាភិបាលពិភពលោកលើកដំបូងស្តីពី "ការអប់រំបរិស្ថាន" ហើយបានចេញជាឯកសារដែលត្រូវបានស្គាល់ថាជាសេចក្តីថ្លែងការណ៍ Tbilisi ។ *(សូមមើលឧបសម្ព័ន្ធទី២ចំពោះនិយមន័យនៃការអប់រំបរិស្ថាន)* ។

## ការអភិវឌ្ឍជាអន្តរជាតិលើការអប់រំបរិស្ថាន

ការអប់រំបរិស្ថានត្រូវបានក្លាយជាឧបករណ៍គន្លឹះដែលចាត់ទុកថាមានសារៈសំខាន់សំរាប់ការផ្លាស់ប្តូរជាអន្តរជាតិក្នុងការឆ្ពោះទៅរកការគ្រប់គ្រងបរិស្ថានអោយកាន់តែប្រសើរឡើង ។ សន្និសិទ្ធអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍនៅក្នុងឆ្នាំ១៩៩២ និងកិច្ចប្រជុំកំពូលបានផ្តល់នូវអាទិភាពខ្ពស់នៅក្នុងរបៀបវារៈ ទី២១ របស់ខ្លួនចំពោះតួនាទីនៃការអប់រំអោយស្របគ្នាជាមួយប្រភេទនៃការអភិវឌ្ឍដែលត្រូវគោរពនិងថែរក្សាបរិស្ថានធម្មជាតិ ។ សន្និសីទនេះផ្តោតលើដំណើរការនៃការអប់រំដែលមានទិសដៅ និងគ្មានទិសដៅដើម្បីលើកកំពស់គុណតំលៃ និងអាកប្បកិរិយានៃការគោរពចំពោះបរិស្ថាន ហើយវាក៏ជាវិធីសាស្រ្ត និងមធ្យោបាយដែលគេចង់បានពីការអនុវត្តបែបនេះដែរ ។ នៅក្នុងកិច្ចប្រជុំកំពូលក្នុងឆ្នាំ ២០០២ និយមន័យនៃការអភិវឌ្ឍប្រកបដោយចីរភាពបានពង្រីកទៅដល់បញ្ហាយុត្តិធម៌ សង្គម និងភាពក្រីក្រ ។ ទិដ្ឋភាពមនុស្ស និងសង្គមនៃការអភិវឌ្ឍប្រកបដោយចីរភាពមានន័យថាសាមគ្គីភាព សមធម៌ ភាពជាដៃគូរ និងកិច្ចសហការដែលមានសារៈសំខាន់ដូចគ្នានឹងវិធីសាស្រ្តដែលមានលក្ខណៈវិទ្យាសាស្រ្តសំរាប់កិច្ចការពារបរិស្ថាននេះដែរ ។ ថ្មីៗនេះទៀតសហគមន៍អន្តរជាតិបានរួមគ្នាក្នុងកិច្ចប្រឹងប្រែងមួយដើម្បីសំរេចទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។







## ទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍

ដោយមានការទទួលស្គាល់ដោយសហគមន៍អន្តរជាតិក្នុងឆ្នាំ២០០០ ទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍ត្រូវបានចាត់ទុកជាផែនការសំខាន់មួយសំរាប់មនុស្សលោកធ្វើការសហការគ្នានៅក្នុងការតស៊ូដើម្បីឆ្ពោះទៅរកទិសដៅអភិវឌ្ឍន៍ ។ ជាពិសេសទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ផ្តល់នូវទិសដៅសកម្មភាពជាអន្តរជាតិដើម្បី ជួយកាត់បន្ថយភាពក្រីក្រ លើកកំពស់សុខភាពម្តាយនិងកូន ពង្រីកនូវការអប់រំ និងដោះស្រាយនូវអសមភាពយេនឌ័រនៅក្នុងការអប់រំ ព្រមទាំងបង្កើតនូវយុទ្ធសាស្ត្រជាតិសំរាប់ការអភិវឌ្ឍប្រកបដោយចីរភាព ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានព្រមព្រៀងលើសេចក្តីថ្លែងការណ៍សហស្សវត្សរ៍ និងបានប្តេជ្ញាចិត្តដើរតាមជំហាននៃទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍នេះ ។

របាយការណ៍ទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជាឆ្នាំ២០០៣ ផ្ទុកនូវព័ត៌មានជាច្រើនពាក់ព័ន្ធនឹងការអប់រំបរិស្ថានដោយសង្កត់ធ្ងន់ថា ៖

- ថ្វីបើសេដ្ឋកិច្ចមានការលូតលាស់នៅក្នុងអំឡុងសតវត្សរ៍មុនមានសន្ទុះខ្លាំង តែភាពក្រីក្រមិនទាន់ធ្លាក់ចុះគួរអោយកត់សំគាល់នៅឡើយ
- ការទទួលបានការអប់រំនៅបឋមសិក្សាបានកើនឡើង ប៉ុន្តែការទទួលបានការអប់រំនៅអនុវិទ្យាល័យនៅមានកំរិតនៅឡើយ
- ធនធានធម្មជាតិក្នុងស្រុកកំពុងធ្លាក់ចុះយ៉ាងលឿន
- សកម្មភាពត្រួតពិនិត្យនិងវាយតំលៃធ្វើឡើងដោយមិនស្រុះស្រួលគ្នា ។

ទាក់ទងទៅនឹងទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងថា ៖ ធនធានធម្មជាតិរបស់កម្ពុជាត្រូវតែនៅជាការផ្តោតការយកចិត្តទុកដាក់របស់យើងព្រោះយើងត្រូវផ្តល់នូវកេរ្តិ៍ដំណែលបរិស្ថានដ៏មានតំលៃនិងសំបូរបែបនេះទៅអោយមនុស្សជំនាន់ក្រោយ(២០០៣) ។

## ទសវត្សរ៍នៃការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចីរភាព

នៅក្នុងខែធ្នូ ឆ្នាំ២០០២ មហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាសជាផ្លូវការពីទសវត្សរ៍នៃការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចីរភាពសំរាប់ឆ្នាំ២០០៥ ដល់ឆ្នាំ២០១៤ "ដោយសង្កត់ធ្ងន់ថា ការអប់រំជាចំណែកមួយដែលមិនអាចខ្វះបានដើម្បីទទួលបាននូវការអភិវឌ្ឍដោយចីរភាព" ។ ចំនុចចាប់ផ្តើមគឺគិតគូរពីការអប់រំដើម្បីឈានដល់ទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដូចដែលបានលើកឡើងដោយអង្គការ យូនេស្កូខាងក្រោមថា៖

*ទសវត្សរ៍នៃការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិមានគោលបំណងដើម្បីពិនិត្យមើលការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចីរភាពដែលបានអនុវត្តក្នុងរូបភាពច្រើនដែលពាក់ព័ន្ធនឹងសមាហរណកម្មនៃការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចីរភាពទៅក្នុងស្ថានភាពសិក្សាផ្សេងៗគ្នាជាច្រើន ។ (UNESCO2003)*

ប្រទេសជាច្រើនបានបង្កើតគណៈកម្មការដែលពាក់ព័ន្ធនឹងការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងនោះមានប្រទេសមួយចំនួនតូចប៉ុណ្ណោះដែលធ្វើការអភិវឌ្ឍទាន់ពេល ។ និន្នាការអន្តរជាតិជាមួយនឹងសេចក្តីថ្លែងការណ៍ និងគោលការណ៍នៅក្នុងការគាំទ្រការអប់រំដែលបានកំនត់ទុកដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវបានចេញដោយក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រីនៃក្រសួងអប់រំ និងក្រសួងបរិស្ថានថ្នាក់តំបន់ (Fien 2002) ។ នៅក្នុងដំណាក់កាលនេះសកម្មភាពរបស់ប្រទេសកម្ពុជាបានផ្តោតលើការអប់រំបរិស្ថានប៉ុន្តែនៅថ្នាក់ជាតិវិញប្រទេសយើងនៅមិនទាន់បង្កើតគណៈកម្មការ ដើម្បីដោះស្រាយលើការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅឡើយ ។







# ករណីសិក្សា

## ព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ខេត្តកំពង់ធំ

ព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ខេត្តកំពង់ធំប្រើប្រាស់វិធីសាស្ត្រអប់រំបរិស្ថានផ្សេងៗរួមមាន : សំភារៈបោះពុម្ពផ្សាយ សំភារៈចាក់ផ្សាយ ការបណ្តុះបណ្តាល និងសកម្មភាពអនុវត្តផ្ទាល់ ។ សំភារៈជាច្រើនដែលអង្គការនេះប្រើ បានមកពីអង្គការផ្សេងៗ ។ ខាងក្រោមនេះជាការសង្ខេបនូវវិធីសាស្ត្រមួយចំនួននៃការអប់រំបរិស្ថានរបស់អង្គការនេះ

***សំភារៈបោះពុម្ពផ្សាយ*** : ផ្ទាំងរូបភាពទាំងឡាយដែលត្រូវបានបង្កើតឡើងដោយអង្គការផ្សេងៗ និងបានប្រើប្រាស់ដោយអង្គការនេះរួមមាន : សុខភាព ការគ្រប់គ្រងធនធានធម្មជាតិ សត្វព្រៃ និងកសិកម្ម ។ ពួកគេក៏មានសៀវភៅ កសិកម្មដែលទទួលបានពីអង្គការ Church World Service ផងដែរ ។

***ការបណ្តុះបណ្តាល*** : ពួកគេបានរៀបចំវគ្គបណ្តុះបណ្តាលដូចជា សារៈសំខាន់សហគមន៍ព្រៃឈើ សហគមន៍ព្រៃឈើ ច្បាប់ដីធ្លី និងក្រុមប្រឹក្សាឃុំ សីលធម៌ សិទ្ធិមនុស្ស ការសរសេររបាយការណ៍ ការគ្រប់គ្រង និង ភាពជាអ្នកដឹកនាំ ។

***សំភារៈចាក់ផ្សាយ*** : ពួកគេមិនបានបង្កើតសំភារៈផ្ទាល់ខ្លួនរបស់ពួកគេទេ តែពួកគេប្រើប្រាស់ ថាសចំរៀង ដែលបានមកពីអង្គការម្ញប់បៃតង ។

***សកម្មភាពអនុវត្តផ្ទាល់*** : ការប្រជុំប្រចាំខែ និងការប៉ាន់ប្រមាណពីជនបទដោយមានការចូលរួម ត្រូវបានធ្វើជាមួយគណៈកម្មការសហគមន៍ព្រៃឈើដែលបានបង្កើតឡើង ។ បានបង្កើតលក្ខន្តិកៈសហគមន៍ព្រៃឈើ បានកំនត់ព្រំប្រទល់ និងចុះល្បាតតំបន់សហគមន៍ព្រៃឈើ ។ ពួកគេបានជួយលើសកម្មភាពនៃការប្រកបរបរចិញ្ចឹមជីវិតដូចជា ការដាំដុះ ការចិញ្ចឹមសត្វ ការធ្វើជីកំប៉ុស្ត និងធនាគារស្រូវ ។ ពួកគេក៏បានធ្វើសកម្មភាពទាក់ទងនឹងសុខភាពបឋម និងក្រុមជួយខ្លួនឯងផងដែរ ។

***មេរៀន បុ្បទពិសោធន៍ : ព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ខេត្តកំពង់ធំ – នាយកអង្គការ លោក លី ខុម***

ជាការសំខាន់ណាស់យើងត្រូវបង្រៀនសហគមន៍មូលដ្ឋានអោយចេះសរសេរបែបបទលិខិតទៅកាន់ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហា ។ ដើម្បីគ្រប់គ្រងសហគមន៍ព្រៃឈើអោយមានប្រសិទ្ធភាព តំរូវអោយមានការបែងចែកការទទួលខុសត្រូវតាមភូមិនីមួយៗដែលសហគមន៍នោះស្ថិតនៅ ។ ការលើកទឹកចិត្តសហគមន៍អោយចេះប្រើលក្ខន្តិកៈសហគមន៍ព្រៃឈើ នោះនឹងធ្វើអោយពួកគេយល់ដឹងពីបទល្មើស ហើយចេះដោះស្រាយបញ្ហានោះទៀត ។ ការប្រើប្រាស់ជីធម្មជាតិជំនួសជីគីមី វាជួយកាត់បន្ថយការចំណាយថវិកា ហើយវាជាការល្អសំរាប់បរិស្ថាន ។ ការបង្កើនជីវភាពរស់នៅក្នុងសហគមន៍នឹងជួយកាត់បន្ថយចំណាកស្រុកទៅរកការងារខាងក្រៅ ។ នៅពេលដែលសហគមន៍ចូលរួមសកម្មភាពសហគមន៍ព្រៃឈើ នោះពួកគេនឹងយល់ពីសារៈប្រយោជន៍នៃកិច្ចការពារព្រៃឈើ សត្វព្រៃ និងច្បាប់សហគមន៍ព្រៃឈើ ។ ជាការល្អដែលយើងគួរធ្វើការផ្សព្វផ្សាយពីការយល់ដឹងជាមូលដ្ឋានពីសារសំខាន់របស់ធនធានធម្មជាតិ ។



# កម្មវិធីសំរបសំរួលការអប់រំបរិស្ថាននៅអាស៊ាន គឺជាជំហានដ៏យូរអង្វែងមួយដើម្បីបង្ហាញពីបញ្ហា អតុល្យភាព និងភាពមិនច្បាស់លាស់នៅក្នុងបរិស្ថាន

## ការអប់រំបរិស្ថាននៅក្នុងតំបន់

នៅខែធ្នូឆ្នាំ២០០២សមាជិកនៃសមាគមអាស៊ានបានមកជួបគ្នាសំរាប់ផែនការអនុវត្តលើការអប់រំបរិស្ថានអាស៊ានឆ្នាំ ២០០០-២០០៥នៅក្រោមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យពាក់កណ្តាលវគ្គ និងភាពជាដៃគូសំរាប់អនុវត្ត ។ ការសង្ខេបពីការបង្ហាញខាងក្រោមត្រូវបានប្រើដើម្បីបង្ហាញពីបរិបទក្នុងតំបន់សំរាប់ការអប់រំបរិស្ថាន ។ សំរាប់ភាពលំអិតផ្សេងទៀតអាចឃើញមាននៅក្នុងបញ្ជីសារពើភ័ណ្ឌនៃការអប់រំបរិស្ថានអាស៊ាន ។ http://aeeid.aseansec.org

បណ្តាប្រទេសជាសមាជិកអាស៊ានត្រូវបានចាត់ទុកថាជាប្រទេសដែលស្អាត និងមានព៌ណបៃតងដែលមាននៅក្នុប្រពៃណីវប្បធម៌ (ជាចំនុចដែលគុណតំលៃ និងការអនុវត្តរបស់ប្រជាជនឋិតនៅក្នុងភាពស៊ីសង្វាក់ និងស្របនឹងធម្មជាតិ) ជាមួយប្រជាជនដែលមានការយល់ដឹងលើបរិស្ថាន ការជ្រួតជ្រាបពីក្រមសីលធ៌មបរិស្ថាន ឆន្ទៈ និងសមត្ថភាពដើម្បីធានានូវការអភិវឌ្ឍប្រកបដោយចេរភាពក្នុងតំបន់តាមរយៈការអប់រំបរិស្ថាន និងកិច្ចខិតខំប្រឹងប្រែងចូលរួមជាសាធារណៈ ។

ថ្នាក់ដឹកនាំបរិស្ថាននៃសមាគមអាសាិនបានទទួលយកផែនការសកម្មភាពអប់រំបរិស្ថានអាស៊ាននៅខែតុលា ឆ្នាំ ២០០០។ ការអប់រំបរិស្ថានមិនមែនជាបញ្ហាថ្មីនៅក្នុងតំបន់ឡើយ ហើយប្រទេសអាស៊ានបានបង្កើតកម្មវិធីផ្ទាល់លើសកម្មភាពនេះតាំងពីសន្និបាទអន្តរជាតិដំបូងស្តីពីការអប់រំបរិស្ថានដែលធ្វើឡើងនៅប្រទេសបង់ក្លាដេស នៅឆ្នាំ១៩៧៥មកម្ល៉េះ ។ ប្រទេសជាសមាជិកបានស្វែងរករួចជាស្រេចនូវលទ្ធភាពផ្សេងៗលើការអប់រំបរិស្ថាន អ្វីដែលគួរអោយកោតសរសើរនោះគឺចំនុចនៃភាពគ្មានផែនការច្បាស់លាស់លើសកម្មភាពអប់រំបរិស្ថានសំរាប់អាស៊ានត្រូវបានគេលើកជាអាទិភាពសំរាប់ផែនការសកម្មភាពអប់រំបរិស្ថានអាស៊ាន ។

កម្មវិធីសំរបសំរួលការអប់រំបរិស្ថាននៅអាស៊ាន គឺជាជំហានដ៏វែងឆ្ងាយមួយដើម្បីបង្ហាញពីបញ្ហាអតុល្យភាព និងភាពមិនច្បាស់លាស់ទៅលើបរិស្ថានដូចដែលផែនការសកម្មភាពយុទ្ធ-សាស្រ្តអាស៊ានទៅលើបរិស្ថានសំរាប់ឆ្នាំ ១៩៩៦-១៩៩៨ ដែលមានលក្ខណៈខ្ពីហើយច្បាស់ត្រូវបានដាក់បញ្ចូលទៅក្នុងនោះ „ការអប់រំបរិស្ថានមានសារៈសំខាន់ខ្លាំងណាស់សំរាប់អោយប្រជាជនដឹង ជាពិសេសសំរាប់សិស្សសាលាដូចដែលបានធ្វើឡើងនៅក្នុងការបង្កើតសិទ្ធិលើក្រមសីលធម៌បរិស្ថាន និងកសាងនូវការទទួលខុសត្រូវលើបរិស្ថាន និង សង្គម" ។ ចុងបញ្ចប់នេះមូលដ្ឋានបង្អែកដ៏ល្អ និងរឹងមាំសំរាប់ការអភិរក្ស និងការពារបរិស្ថាន និងអ្នកដែលធ្វើអាជីវកម្មដែលមានការគិតគូរពីធនធានធម្មជាតិគឺប្រជាជនដែលមាន ការយល់ដឹងពីភាពអវិជ្ជមានដែលអាចកើតឡើងពីសកម្មភាពរបស់មនុស្ស ហើយវាមិនត្រឹមតែសំរាប់មនុស្សជំនាន់នេះទេ ប៉ុន្តែក៏សំរាប់មនុស្សជំនាន់ក្រោយផងដែរ ។ ដូចនេះវាមានសារៈសំខាន់ណាស់សំរាប់តំបន់ទាំងមូលលើកិច្ចសហប្រតិបត្តិការ ។

## ស្ថានភាពបច្ចុប្បន្ននៃការអប់រំបរិស្ថានអាស៊ាន

គេអាចនិយាយបានថា ជាទូទៅប្រទេសមាជិកអាស៊ានជាប្រទេសដែលមានភាពសកម្មនៅក្នុងការជំរុញការអប់រំបរិស្ថាននៅក្នុងជួររដ្ឋាភិបាល និងផ្នែកឯកជននានានៅក្នុងសង្គមទាំងទៅលើផ្នែកអប់រំក្នុង និងក្រៅប្រព័ន្ធ និងនៅគ្រប់កំរិតនៃការអប់រំក្នុងប្រព័ន្ធ (បឋមសិក្សា អនុវិទ្យាល័យ និងឧត្តមសិក្សា)។ ប្រទេសមួយចំនួនបានចាប់ផ្តើមយុទ្ធនាការមុនគេជាមួយថវិកាច្រើន ដូចនេះគេបានអនុវត្តសកម្មភាពបានច្រើនជាងប្រទេសផ្សេងៗ ។ ទោះជាយ៉ាងណាបណ្តាប្រទេសទាំងអស់មានគោលបំណងតែមួយគឺធ្វើការងារសំរាប់សុវត្ថិភាព និងផលិតភាពនៃបរិស្ថានអាស៊ាន ហើយទាំងអស់គ្នាបានព្រមព្រៀងលើគោលការណ៍នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ និងតំបន់ ដោយរួមបញ្ចូលទាំងការចែករំលែកជំនាញ និងបទពិសោធន៍នៅក្នុងការដោះស្រាយបញ្ហាបរិស្ថាន ព័ត៌មានបរិស្ថាន និង យុទ្ធសាស្រ្ត ព្រមទាំងសំភារៈសំរាប់បង្រៀនលើការអប់រំបរិស្ថាន ។



## ឧបសគ្គ និង ចន្លោះនៅក្នុងការអនុវត្ត គំរោងក្នុងស្រុកលើការអប់រំបរិស្ថាន

សមាជិកប្រទេសអាស៊ានភាគច្រើនជឿលើភាពមានកំរិតនៃធនធានមនុស្សសំរាប់ការអប់រំបរិស្ថានដោយយោងលើ ៖

(ក) ការយល់ដឹងរបស់គ្រូបង្រៀនក្នុងមាតិកានៃការអប់រំបរិស្ថាន

(ខ) គ្រូបណ្ដុះបណ្ដាល

(គ) សំភារៈបង្ហាញ និង

(ឃ) ការអប់រំសហគមន៍ពីការអប់រំបរិស្ថាន ។

មានប្រទេសមួយចំនួនតូចបានលើកពីឧបសគ្គដូចជា ៖ ការខ្វះខាតសំភារៈបណ្ដុះបណ្ដាល និងសំភារៈបង្ហាញ កង្វះខាតលើការផ្ដួចផ្ដើមជាសាធារណៈ និងការលំបាកនៅក្នុងការលើកទឹកចិត្តអោយមានការចូលរួម ភាពមានកំរិតលើបណ្ដាញទាក់ទង រឺការសំរបសំរួលត្រូវបានយកចិត្តទុកដាក់តិចតួចពីស្ថាប័នជាន់ខ្ពស់ និងការលំបាកក្នុងការបង្រៀន ។ ម្យ៉ាងប្រទេសមួយចំនួនតូចទៀតបានលើកពីព័ត៌មានមូលដ្ឋាននៅមានកំរិតស្ដីពីបរិស្ថានក្នុងប្រទេស និងក្នុងតំបន់សំរាប់ការរៀបចំសៀវភៅមេរៀន និងឯកសារយោងលើការអប់រំបរិស្ថានពិសេសសំភារៈដែលមានស្រាប់ស្ដីពីបរិស្ថានអាស៊ីប៉ាស៊ីហ្វិចដែលគួរត្រូវធ្វើការចែកចាយដើម្បីប្រើប្រាស់នៅក្នុងការបណ្ដុះបណ្ដាល និងការបង្រៀនលើការអប់រំបរិស្ថាន ។

ជាចុងក្រោយគ្រប់ប្រទេសសមាជិកទាំងអស់យល់ឃើញថាថវិកាដែលកំនត់ដោយរដ្ឋាភិបាលសំរាប់ការអប់រំបរិស្ថានគួរត្រូវបង្កើន រឺ រកជំនួយថវិកាបន្ថែមដើម្បីគាំទ្រលើកិច្ចប្រឹងប្រែងសំរាប់ការអប់រំបរិស្ថានទៅតាមរដ្ឋាភិបាលរៀងៗខ្លួន ។










# ករណីសិក្សា

## ៖សមាគមថែរក្សាបរិស្ថាន និងវប្បធម៌

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ប្រើប្រាស់វិធីសាស្ត្រការអប់រំបរិស្ថានមួយចំនួនរួមមាន ៖ សំភារៈបោះពុម្ពផ្សាយ សំភារៈចាក់ផ្សាយ ការបណ្តុះបណ្តាល និងសកម្មភាពអនុវត្តផ្ទាល់ ។ ខាងក្រោមនេះជាការសង្ខេបនូវវិធីសាស្ត្រមួយចំនួននៃការអប់រំបរិស្ថានរបស់អង្គការ ៖

***សំភារៈបោះពុម្ពផ្សាយ*** ៖ បានផលិតផ្ទាំងរូបភាពអំពី ទំនប់វារីអគ្គិសនី និងធនធានជលផល ខិតប័ណ្ណអំពីទំនប់វារីអគ្គិសនី សៀវភៅស្តីពីទំនប់វារីអគ្គិសនី និងទន្លេមេគង្គ ការស្រាវជ្រាវធនធានធម្មជាតិ បានប្រមូល និងចងក្រងជាព័ត៌មានបរិស្ថាន បានបោះពុម្ពជាព្រឹត្តិបត្របរិស្ថានរៀងរាល់បីខែម្តងដែលពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន ។ សំភារៈទាំងនេះបានចាប់ផ្តើតតាំងពីឆ្នាំ ១៩៩៨ មកម្លេះ ។

***ការបណ្តុះបណ្តាល*** ៖ ពួកគេបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការតស៊ូមតិ និងការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយចេរភាព ។ ភាគច្រើនពួកគេបានបណ្តុះបណ្តាលដល់និស្សិតដែលចាប់អារម្មណ៍នឹងបញ្ហាបរិស្ថាន ដែលសកម្មភាពនេះធ្វើឡើងរៀងរាល់ឆ្នាំដោយមានរយៈពេលបីខែ ។

***សំភារៈចាក់ផ្សាយ*** ៖ ពួកគេបានផលិតខ្សែវិដេអូចំនួនពីរដែលទីមួយ ស្តីពីទំនប់វារីអគ្គិសនី និងជលផល ហើយមួយទៀតស្តីពីច្បាប់ និងការគ្រប់គ្រងធនធានធម្មជាតិ ។

***សកម្មភាពអនុវត្តផ្ទាល់*** ៖ ការចុះល្បាតតំបន់ព្រៃសហគមន៍ និងតំបន់នេសាទ ការចុះត្រួតពិនិត្យ និងវាយតំលៃសកម្មភាពការងារចុះស្រាវជ្រាវអនុវត្តជាក់ស្តែងតាមតំបន់ផ្សេងៗ ។ បន្ទាប់ពីបានបណ្តុះបណ្តាលក៏មានការប្រជុំបណ្តាញការងារប្រចាំខែ និងការចុះអប់រំបរិស្ថាននៅតាមសហគមន៍ផងដែរ ។

***មេរៀន បទពិសោធន៍ ៖ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ – នាយិការង លោកស្រី លុយ រស្មី***

សំរាប់ការអប់រំប្រជាពលរដ្ឋដែលមានចំណេះដឹងទាប ជាការសំខាន់ត្រូវប្រើសំភារៈអប់រំដូចជា វិដេអូ ប៉ូស្ទ័រ និងរូបភាពផ្សេងៗដើម្បីងាយយល់ ។ ការគ្រប់គ្រងធនធានធម្មជាតិអោយមានប្រសិទ្ធភាព តំរូវអោយមានទាំងសកម្មភាពអប់រំបរិស្ថាន និងសកម្មភាពបង្កើនជីវភាពរស់នៅប្រកបដោយចេរភាព ។ ប្រជាពលរដ្ឋមូលដ្ឋានគួរតែបណ្តុះបណ្តាលពីសិទ្ធិ និងកាតព្វកិច្ចក្នុងការប្រើប្រាស់ធនធានធម្មជាតិដោយស្របច្បាប់ ។ ការការពារធនធានធម្មជាតិតំរូវអោយមានការចូលរួមពីអ្នកដែលពាក់ព័ន្ធរួមទាំងអាជ្ញាធរដែនដី សមាជិកសហគមន៍ និងសិស្សសាលាជាដើម ហើយអ្នកពាក់ព័ន្ធទាំងនេះគួរត្រូវបានទទួលការអប់រំបរិស្ថាន ។ មុននឹងផលិតសំភារៈ អប់រំបរិស្ថានសំរាប់សហគមន៍មូលដ្ឋាន ត្រូវប្រមូលព័ត៌មានពីតំរូវការរបស់ពួកគេដោយប្រើវិធីសាស្ត្របែប

ចូលរួម ។ វាជាការប្រសើរណាស់បើការចូលរួមរបស់សហគមន៍ធ្វើឡើងតាមលក្ខណៈស្ម័គ្រចិត្ត ហើយជាសំខាន់យើងត្រូវចូលរួមក្នុងការកសាងទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដីដើម្បីជំរុញលើកទឹកចិត្តអោយពួកគេគាំទ្រដល់សកម្មភាពអប់រំបរិស្ថាន ។

# ស្ថានភាពនៃការអប់រំបរិស្ថាននៅកម្ពុជា



**នៅមុនសង្គ្រាមប្រទេសកម្ពុជាជាប្រទេសដែលនាំមុខគេនៅក្នុងតំបន់លើអក្ខរកម្ម និងការអប់រំខ្ពស់ តែជាអកុសលប៉ុន្មានឆ្នាំនៃសង្គ្រាមបានធ្វើអោយរេចរឹលលើមូលដ្ឋានល្អៗនៃការអប់រំនេះ**

## សាវតារ

ប្រមាណជាងម្ភៃឆ្នាំនៃសង្គ្រាមនៅកម្ពុជាបាននាំមកនូវរយៈពេលនៃការកាត់បន្ថយទំនាក់ទំនងជាមួយសហគមន៍អន្តរជាតិ ។ ឋិតក្នុងរយៈពេលនេះវាស្របគ្នាជាមួយការកើនឡើងនូវការយល់ដឹងជាអន្តរជាតិលើបញ្ហាបរិស្ថាន និងការកើនឡើងនូវការយល់ដឹងពីទស្សនៈទាននៃការអប់រំបរិស្ថាន និងការអភិវឌ្ឍដែលប្រកបដោយចេរភាព ។ ប៉ុន្មានឆ្នាំថ្មីៗនេះកម្ពុជាបានបើកទូលាយទៅកាន់សហគមន៍អន្តរជាតិ និងធ្វើការបង្កើនផងដែរលើការលើកឡើងពីតួនាទីដែលថាការអភិវឌ្ឍប្រកបដោយចេរភាព និងការអប់រំបរិស្ថានអាចជួយកាត់បន្ថយបញ្ហាបរិស្ថាននៅកម្ពុជា ។

នៅមុនសង្គ្រាម ប្រទេសកម្ពុជាជាប្រទេសដែលនាំមុខគេនៅក្នុងតំបន់លើអក្ខរកម្ម និងការអប់រំខ្ពស់ តែជាអកុសលប៉ុន្មានឆ្នាំនៃសង្គ្រាមបានធ្វើអោយរិចរិលលើមូលដ្ឋានល្អៗនៃការអប់រំនេះ ។ អាទិភាពបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជាកំពុងឋិតនៅលើខ្សែបន្ទាត់តែមួយជាមួយអង្គការសហប្រជាជាតិលើយុទ្ធសាស្ត្រនៃ "ការអប់រំសំរាប់ទាំងអស់គ្នា" សំរាប់ការអប់រំនៅតាមសាលារៀន ។ ការចាប់អារម្មណ៍នាពេលបច្ចុប្បន្នគឺផ្តោតលើអក្ខរកម្មជាមួយកិច្ចសង្គ្រោះជាអន្តរជាតិដែលត្រូវបានតំរង់ឆ្ពោះទៅកាន់ការអប់រំ ដោយរួមបញ្ចូលការគាំទ្រពីធនាគារអភិវឌ្ឍអាស៊ី ធនាគារពិភពលោក និងជំនួយផ្សេងទៀតពីប្រទេសអេស្ប៉ាញ ញូហ្សីឡែន អង់គ្លេស ជប៉ុន និប្រទេសអូស្ត្រាលី ។ ការងើបឡើងនៃសេដ្ឋកិច្ចនៅអាស៊ីបានបង្ហាញពីទំនាក់ទំនងផ្ទាល់រវាងការអប់រំ និងការរីកចំរើននៃសេដ្ឋកិច្ចដែលជាចំនុចដែលការអប់រំ និងទំនាក់ទំនងសេដ្ឋកិច្ចត្រូវបានគេបង្កើតឡើង ។ វាត្រូវបានសង្ឃឹមថា ជាមួយការបង្កើននូវការអប់រំ កម្ពុជាអាចបង្កើនលើផលប្រយោជន៍សេដ្ឋកិច្ចផងដែរ ។

មិនត្រឹមតែធ្លាប់ជាប្រទេសមានស្តង់ដាខ្ពស់លើការអប់រំ និងអត្រានៃអក្ខរកម្មខ្ពស់ប៉ុណ្ណោះទេ កម្ពុជាក៏ជាប្រទេសមួយនៅក្នុងអាស៊ីអាគ្នេយ៍ដែលបានបង្កើតឧទ្យានជាតិដំបូងគេ ។ នៅឆ្នាំ១៩២៥ ព្រៃឈើនៅជុំវិញប្រាសាទអង្គរត្រូវបានគេកំនត់ជាតំបន់ការពារ ។ តាមរយៈការបង្កើតឧទ្យានជាតិត្រូវបានគេភ្ជាប់ទៅនឹងការបង្កើនការយល់ដឹងពីតំបន់ធម្មជាតិដើម្បីធ្វើការអភិរក្ស វាអាចមានន័យថា កំរិតជាក់លាក់លើការយល់ដឹងពីបរិស្ថានជាអាទិភាពទៅលើដីលោះផ្ទៃក្នុង ។ ការពង្រីកពិតប្រាកដលើការយល់ដឹងនៅកម្ពុជាមិនត្រូវបានគេដឹងច្បាស់លាស់នៅឡើង តែផ្នែកបន្ទាប់នៃរបាយការណ៍នឹងបង្ហាញពីអ្វីដែលគេបានដឹងពីស្ថេរភាពកម្ពុជានៅដើមទសវត្សរ៍ ៩០ ថ្មីៗនេះ ។

### រឿងព្រេងខ្មែរ

មានរឿងព្រេងបុរាណមួយនៅប្រទេសកម្ពុជាដែលលើកពីអ្នកតាដែលពួកគាត់ជាព្រលឹងថែរក្សាស្រុក រឺពិភពលោក ។ អ្នកតាជាបុគ្គលដំបូងដែលបានបង្កើតព្រៃ ។ អ្នកតាស្ថិតក្នុងដើមឈើដែលជាទូទៅត្រូវបានតំណាងដោយថ្ម ។ ពួកគាត់ត្រូវបានគេជឿថាអាចធានាបានលើការប្រមូលផល ផ្តល់ទឹកភ្លៀង និងការពារទឹកដីពីសត្រូវ និងជំងឺ ។ សំរាប់ប្រជាជនខ្មែរដែលមានជំនឿលើព្រះពុទ្ធសាសនា ចាត់ទុកអ្នកតាជាតំណាងអោយភាពចុះថ្កើងនិងសុភមង្គល ។ (SIPAR)

## របាយការណ៍ប្រទេសអាស៊ានលើការអប់រំបរិស្ថាននៅកម្ពុជា

របាយការណ៍នេះត្រូវបានធ្វើការសង្ខេបពីសៀវភៅ "ផែនការសកម្មភាពការអប់រំបរិស្ថានអាស៊ាន ២០០០-២០០៥" កិច្ចប្រជុំស្តីពីការត្រួតពិនិត្យពាក់កណ្តាលវគ្គ និងភាពជាដៃគូសំរាប់ការអនុវត្ត(២០០២) ។ សេចក្តីសង្ខេបលើការពិនិត្យឡើងវិញនេះគឺដើម្បីបង្ហាញពីបរិបទដែលកន្លងទៅថ្មីៗនេះសំរាប់ការអប់រំបរិស្ថាននៅកម្ពុជាពីរដ្ឋាភិបាល និងជាពិសេសគោលគំនិតរបស់ក្រសួងបរិស្ថាន ។





## ការពិនិត្យឡើងវិញលើការអប់រំបរិស្ថានថ្នាក់ជាតិ

ក្រសួងបរិស្ថានជាស្ថាប័នមួយដែលឋិតនៅក្រោមរាជរដ្ឋាភិបាលកម្ពុជាដែលទទួលបន្ទុកលើការជំរុញការការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិទូទាំងប្រទេសដើម្បីផ្តល់ជាវិភាគទានដល់ការធ្វើឲ្យប្រសើរឡើងនូវគុណភាពបរិស្ថាន សុខមាលភាពសាធារណៈ វប្បធម៌ និងសេដ្ឋកិច្ចជាតិ ។ ក្រសួងមានតួនាទីជំរុញ និងគាំទ្រលើការចូលរួមជាសាធារណៈនៅក្នុងការធ្វើការសំរេចចិត្តដើម្បីដោះស្រាយលើការប្រើប្រាស់ធនធានធម្មជាតិ និងបញ្ហាបរិស្ថាន ។ ដើម្បីឆ្លើយតបនឹងគោលបំណងនេះ ក្រសួងបរិស្ថានបានសហការជាមួយក្រសួងផ្សេងៗ ស្ថាប័ននានា អង្គការជាតិ និងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និង ប្រជាជនកម្ពុជា ។

នៅក្នុងការទទួលខុសត្រូវដោយផ្ទាល់ដើម្បីធានានូវការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍដែលធានាបាននូវចេរភាពបរិស្ថាន ក្រសួងបរិស្ថានបានផ្តល់ការពង្រឹងសមត្ថភាពលើបច្ចេកទេសតាមរយៈវគ្គបណ្តុះបណ្តាលទៅលើការអភិរក្ស និងការពារធនធានធម្មជាតិ ច្បាប់ និងគោលនយោបាយបរិស្ថាន អធិការកិច្ច និងការត្រួតពិនិត្យការបំពុល ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងការអប់រំបរិស្ថាន ។

ក្រសួងបរិស្ថានមានអគ្គនាយកចាត់ចែងទូទៅពីរទៀតគឺ : អគ្គនាយកចផ្នែកបច្ចេកទេស និងអគ្គនាយកផ្នែករដ្ឋបាល ។ ឋិតនៅក្រោមនាយកចាត់ចែកបច្ចេកទេសមាននាយកដ្ឋានបច្ចេកទេសធំៗចំនួនប្រាំមួយ ក្នុងនោះនាយកដ្ឋានទំនាក់ទំនង និងការអប់រំបរិស្ថាន (ដែលសព្វថ្ងៃត្រូវបានគេស្គាល់ថាជានាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន) ដែលពាក់ព័ន្ធច្រើនជាងគេសំរាប់ការអប់រំបរិស្ថាន និងបានកំនត់ការអនុវត្តកម្មវិធីគោល៤ដែលរួមមាន : ការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាល និងអប់រំបរិស្ថាន ការផ្សព្វផ្សាយ និងផ្តល់ព័ត៌មានស្តីពីបរិស្ថាន ការស្រាវជ្រាវ និងសរសេរពីព័ត៌មានបរិស្ថាន ។

ទំហំ និងគោលដៅកម្មវិធីរបស់នាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថានមាន :

**កម្មវិធីទី ១ : ការអភិវឌ្ឍធនធានមនុស្ស**

*គោលដៅ : ពង្រឹងសមត្ថភាពបុគ្គលិកនាយកដ្ឋាន និងលើកកំពស់ការយល់ដឹងរបស់ស្ថាប័នរដ្ឋាភិបាល និងប្រជាជនអំពីបរិស្ថាន*

**កម្មវិធីទី ២ : ការបណ្តុះបណ្តាល និងការអប់រំបរិស្ថាន**

*គោលដៅ : ជំរុញការបណ្តុះបណ្តាល និងការអប់រំបរិស្ថានទៅដល់គ្រប់ភាគីពាក់ព័ន្ធដើម្បីស្វែងរកការគាំទ្រ និងការចូលរួមសំរាប់ការអភិរក្ស និងការពារបរិស្ថាន ។*

**កម្មវិធីទី ៣ : ការផ្សព្វផ្សាយ និងការផ្តល់ព័ត៌មានបរិស្ថាន**

*គោលដៅ : ជំរុញការផ្សព្វផ្សាយលើព័ត៌មានបរិស្ថានទៅដល់ភាគីពាក់ព័ន្ធដើម្បីស្វែងរកការគាំទ្រ និងចូលរួមលើការអភិរក្ស និងការពារបរិស្ថាន ។*

**កម្មវិធីទី ៤ : ការសរសេរ និងស្រាវជ្រាវព័ត៌មានបរិស្ថាន**

*គោលដៅៈ ជំរុញ និងធ្វើការលើកទឹកចិត្តលើស្តង់ដានៃការស្រាវជ្រាវ និងសរសេរពីព័ត៌មានបរិស្ថាន ។*

គោលដៅដែលបានលើកឡើងខាងលើហាក់ដូចជាអាចសំរេចបាន ប៉ុន្តែតាមការពិតវាមិនអាចធ្វើទៅបានដោយយោងទៅលើធនធានដែលមិនគ្រប់គ្រាន់ដូចជាថវិកា អំណាច ធនធានមនុស្ស និងសំភារៈជាដើម ។ បញ្ហាទាំងនេះបានធ្វើអោយសកម្មភាពនៃការអប់រំបរិស្ថាននៅកម្ពុជាត្រូវបានធ្វើឡើងក្នុងករណីពិសេសមិនដូចទៅនឹងអ្វីដែលមាននៅក្នុងផែនការការងារឡើយ ។ ចាប់ពីឆ្នាំ ២០០០-២០០២ នាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថានបានអនុវត្ត និងធ្វើសកម្មភាពជាច្រើនដែលទាក់ទងទៅនឹងការអប់រំបរិស្ថាន និងទំនាក់ទំនងដោយរួមបញ្ចូលទាំងការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍលើការពង្រឹងសមត្ថភាព ការលើកកំពស់ការយល់ដឹងជាសាធារណៈ និងយុទ្ធនាការបរិស្ថានដែលសកម្មភាពទាំងនេះត្រូវបានធ្វើឡើងនៅទូទាំងប្រទេស ។ សមិទ្ធិផលទាំងនោះមាន :



# ដំណើរដ៏វែងឆ្ងាយបំផុតចាប់ផ្តើមឡើងជាមួយនឹងជំហានដំបូងក្នុងទិសដៅដែលត្រឹមត្រូវ

**ការអប់រំក្នុងប្រព័ន្ធ** : នៅក្នុងកិច្ចសហប្រតិបត្តិការ (កិច្ចព្រមព្រៀង) រវាងសាកលវិទ្យាល័យវិចិត្រសិល្បៈ និងនាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន ការសិក្សាពីបរិស្ថានយ៉ាងទៀងទាត់ត្រូវបានធ្វើឡើងសំរាប់ផ្តល់ចំនេះដឹងបរិស្ថានដល់និស្សិតសាកលវិទ្យាល័យ ។ ជាមួយកិច្ចព្រមព្រៀងនេះ នាយកដ្ឋានអប់រំ ព័ត៌មាន និង ផ្សព្វផ្សាយបរិស្ថាន ត្រូវធ្វើការបែក មេរៀនសំរាប់ថ្នាក់ធម្មតាសំរាប់៨ម៉ោងក្នុងមួយខែទៅដល់សិស្សប្រមាណ៣០នាក់ដែលបានបញ្ចប់ឆ្នាំសិក្សាដំបូងរបស់គេ ។ បន្ថែមលើនេះទៀត នាយកដ្ឋានអប់រំ ព័ត៌មាន និង ផ្សព្វផ្សាយបរិស្ថានក៏បានចុះកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំ យុវជន និងកីឡា សំរាប់បែកចាយមុខវិជ្ជាសំរាប់៣ថ្ងៃដល់គ្រូបឋមសិក្សា ។ ជាទូទៅគ្រូប្រមាណ ៣០០នាក់ទទួលយកមុខវិជ្ជានេះជារៀងរាល់ឆ្នាំ ។

**ការអប់រំក្រៅប្រព័ន្ធ** : ជាទូទៅការអប់រំក្រៅប្រព័ន្ធត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធផ្សព្វផ្សាយដូចជាទូរទស្សន៍និងវិទ្យុជាតិ ។ នៅក្នុងកិច្ចសហការជាមួយក្រសួងព័ត៌មានទូរទស្សន៍ជាតិបានយល់ព្រមលើការចេញផ្សាយប្រចាំសប្តាហ៍ទៅលើបញ្ហាបរិស្ថាន ព័ត៌មាន និងបញ្ហាដែលទាក់ទងនឹងការអប់រំផ្សេងទៀត ។ ម្យ៉ាងទៀតកម្មវិធីសំនួរចំលើយក៏បានធ្វើឡើងនៅក្នុងគោលបំនងជំរុញការយល់ដឹងជាសាធារណៈលើបរិស្ថានត្រូវចាក់ផ្សាយរាល់បីខែម្តង។ ស្រដៀងគ្នានេះដែរវិទ្យុជាតិបានធ្វើការបញ្ចូលបញ្ហាបរិស្ថានទៅក្នុងកម្មវិធីផ្សាយរៀងរាល់ ២សប្តាហ៍ម្តង (ថ្ងៃច័ន្ទ និង ថ្ងៃព្រហស្បតិ៍) ។បន្ថែមលើនេះទៀត ចាប់ពីឆ្នាំ ២០០០-២០០២ នាយកដ្ឋានអប់រំព័ត៌មាន និងទំនាក់ទំនង បានរៀបចំយុទ្ធនាការដែលទាក់ទងនឹងបរិស្ថានរួមមាន : ទិវាបរិស្ថានជាតិ និងពិភពលោក (ថ្ងៃ៥ មិថុនា) យុទ្ធនាការសំអាតពិភពលោក (ថ្ងៃ ២កញ្ញា) និងរុក្ខទិវា (ថ្ងៃ ៩ កក្កដា) ជាដើម ។ យុទ្ធនាការនេះអនុវត្តឡើងក្នុងគោលបំណងលើកទឹកចិត្តដល់សាធារណជនដើម្បីចូលរួមនៅក្នុងការការពារ និងអភិរក្សបរិស្ថានកម្ពុជា ។

**ការកសាងសមត្ថភាពអ្នកកាន់អំណាច** : នាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងបានរៀបំ និងអនុវត្តវគ្គបណ្តុះបណ្តាលពីរសំរាប់បុគ្គលិកមន្ទីរបរិស្ថាននៅតាមខេត្ត ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះគឺដើម្បីផ្តល់ និងពង្រឹងសមត្ថភាពបុគ្គលិកក្រសួងបរិស្ថានក្នុងនោះមានអ្នកចូលរួមប្រមាណ ៣០នាក់បានចូលរួមនៅវគ្គបណ្តុះបណ្តាលនីមួយៗ ។

## ឱកាស និងឧបសគ្គនៃការអប់រំបរិស្ថាន

### ឱកាសសំរាប់ការអប់រំបរិស្ថាន :

ក្រសួងបរិស្ថានជាក្រសួងមួយដែលថ្មី ប៉ុន្តែមានបុគ្គលិកច្រើនដែលមានបរិញ្ញាបត្រ វិសញ្ញាបត្រ័ថ្នាកវិស្វកម្មនៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ និងសង្គម ។

- បញ្ហាបរិស្ថានគឺជាប្រធានបទថ្មីមួយនៅកម្ពុជាដែលធ្វើអោយប្រជាជនមានការចង់ចេះចង់ដឹង និងឆន្ទៈក្នុងការស្វែងយល់កាន់តែច្បាស់ពីវា
- នាយកដ្ឋានអប់រំ ព័ត៌មាន និង ផ្សព្វផ្សាយបរិស្ថានគឺជាស្ថាប័នរដ្ឋាភិបាលដែលទទួលបន្ទុកលើគ្រប់មធ្យោបាយនៃសកម្មភាពអប់រំបរិស្ថាន
- ក្រសួងបរិស្ថានមានបណ្តាញមន្ទីរបច្ចេកទេសនៅតាមខេត្ត-ក្រុងនីមួយៗទទួលបន្ទុកលើការគ្រប់គ្រងបរិស្ថានអោយបាននៅក្នុងតំបន់កាន់កាប់របស់គេ
- ក្រសួងបរិស្ថានបានសហការជាមួយស្ថាប័នរដ្ឋផ្សេងទៀតដែលធ្វើការទាក់ទងនឹងបញ្ហាបរិស្ថាន
- ប្រទេសកម្ពុជាមានស្ថេរភាពនយោបាយ
- ប្រជាជនកម្ពុជាភាគច្រើនមិនយល់ដឹងថាអ្វីជាបរិស្ថាន និងសារៈសំខាន់នៅក្នុងជីវិតប្រចាំថ្ងៃ
- ការអប់រំបរិស្ថាននៅកម្ពុជាត្រូវបានដាក់អោយប្រើតាមរយៈការអប់រំក្នុងប្រព័ន្ធ (ប្រព័ន្ធអប់រំ សង្គម និង សាសនា) និងការអប់រំក្រៅប្រព័ន្ធ និង ប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ ទូរទស្សន៍ កាសែត ជាដើម)





- ការអប់រំបរិស្ថានអាចអនុវត្តតាមសហគមន៍ដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ សហគមន៍នេសាទ និងព្រៃឈើជាដើម
- ប្រមាណជាង៥០%នៃប្រជាជនកម្ពុជាបានទទួលការអប់រំមូលដ្ឋាន

**ឧបសគ្គនៅក្នុងការអប់រំបរិស្ថាន :**

ការអនុវត្តការអប់រំបរិស្ថាននៅក្នុងប្រទេសកម្ពុជាប្រឈមមុខនឹងឧបសគ្គជាច្រើនដូចជា :

- ធនធានមនុស្សនៅមានកំរិតសំរាប់ការអប់រំបរិស្ថាន
- ឧបករណ៍សំរបសំរួល និងសំភារៈសំរាប់អប់រំបរិស្ថាននៅមានកំរិត
- ខ្វះខាតថវិកាគាំទ្រ
- ខ្វះខាតការធ្វើផែនការសំរាប់ការអប់រំបរិស្ថាន
- ការតាំងចិត្ត និងកិច្ចសហការពីអ្នកពាក់ព័ន្ធនៅមានកំរិត ការយល់ដឹងរបស់ប្រជាជនលើបរិស្ថាននៅមានកំរិត ដូចនេះការចូលរួម និងការតាំងចិត្តរបស់ពួកគេនៅក្នុងសកម្មភាពបរិស្ថានក៏នៅមានកំរិតដែរ
- ក្រសួងបរិស្ថានជាស្ថាប័នថ្មី
- ប្រទេសកម្ពុជានៅមានកំរិតលើការតាក់តែងច្បាប់បរិស្ថានបទបញ្ញានានា និងឧបករណ៍អនុវត្តសំរាប់គ្រប់គ្រងធនធានធម្មជាតិ ។

ជំពូកជាបន្តនឹងបង្ហាញពីការអភិវឌ្ឍថ្មីៗទៅលើការអប់រំបរិស្ថាននៅកម្ពុជា បន្ទាប់មកនឹងធ្វើការសង្ខេបពីស្ថានភាពបច្ចុប្បន្ននៃការអប់រំបរិស្ថាននៅកម្ពុជានៅជំពូកបន្ត ។ ការបង្ហាញបែបនេះ គឺក្នុងគោលបំណងផ្តល់លទ្ធភាពនាដើម្បីអភិវឌ្ឍនៅពេលខាងមុខ និងជំរុញការអប់រំសំរាប់ការអភិវឌ្ឍប្រកបដោយចេរភាពនៅកម្ពុជា ។




## ការអប់រំបរិស្ថាននៅកម្ពុជា

ផ្នែកខាងលើបានបង្ហាញពីការត្រួតពិនិត្យលើការអប់រំបរិស្ថានពីគោលគំនិតរបស់ក្រសួងបរិស្ថាន ទោះជាយ៉ាងណា របាយការណ៍នេះត្រូវបានកំនត់ពេលវេលា និងទិសដៅច្បាស់លាស់ដើម្បីផ្តោះទៅកាន់វិធីសាស្ត្ររបស់ក្រសួងក្នុងការពិនិត្យលើស្ថានភាពទូទៅនៃការអប់រំបរិស្ថាននៅកម្ពុជា ។ នៅក្នុងផ្នែកនេះ យើងនឹងលើកឡើងផងដែរពីការបង្ហាញការអប់រំបរិស្ថាននៅកម្ពុជាក្នុងកិច្ចសហការរវាងតួនាទីរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងការជំរុញ និងការអភិវឌ្ឍ ការអប់រំបរិស្ថាននៅកម្ពុជា ។ ព័ត៌មានខ្លះនឹងនៅតែមានភាពជាន់គ្នា ប៉ុន្តែសង្ឃឹមថាអ្នកអាននឹងអាចបង្កើននូវការយល់ដឹងកាន់តែទូលាយទៅលើស្ថានភាពនៃការអប់រំបរិស្ថាននៅកម្ពុជាពីការបញ្ចូលនូវគោលគំនិតទាំងនេះ ។





## ការពិនិត្យឡើងវិញ

ការអប់រំបរិស្ថាននៅកម្ពុជាមានប្រវត្តិទាក់ទងខ្លីមួយ ដែលការសង្ខេបឯកសារប្រវត្តិសាស្ត្របង្ហាញថា គោលការណ៍នៃការអប់រំបរិស្ថានត្រូវបានបញ្ចូលជាដំបូងទៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាលស្របពេលនៃការបង្កើតក្រសួងបរិស្ថាននៅឆ្នាំ ១៩៩៣ ។ សំរាប់ពេលនេះនាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថានរួមជាមួយគណៈកម្មាធិការអន្តរក្រសួងសំរាប់ការអប់រំបរិស្ថានត្រូវបានគេបង្កើតឡើង ។ ហើយគណៈកម្មាធិការនេះទទួលបន្ទុកលើការអប់រំបរិស្ថាននៅក្នុងផ្នែកអប់រំក្នុងប្រព័ន្ធដោយរួមមាន ៖ បឋមសិក្សា អនុវិទ្យាល័យ និងការអប់រំសំរាប់ព្រះសង្ឃ ។ ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសសំរាប់ការអប់រំបរិស្ថានត្រូវបានផ្តល់ដោយផ្ទាល់ និងប្រយោលសំរាប់ការអប់រំបរិស្ថានតាមរយៈរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលចាប់ពីឆ្នាំ ១៩៩៣ ។ អង្គការសហប្រជាជាតិ និងអង្គការជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលបានប្រើប្រាស់គ្រប់ផ្នែកទាំងអស់នៃការអប់រំបរិស្ថាននៅក្នុងសកម្មភាពរបស់ពួកគេ ។ គណៈកម្មាធិការតំរែតំរង់ទិសអន្តរក្រសួងបានចូលរួមនៅក្នុងការកែប្រែពង្រាងមគ្គុទេសក៍អប់រំបរិស្ថានថ្នាក់បឋមសិក្សាសំរាប់គ្រូ និងសៀវភៅស្តីពីការអប់រំបរិស្ថានសំរាប់ព្រះសង្ឃ ។ ដោយឡែក គណៈកម្មាធិការនេះមិនបានជួបគ្នាតាំងពីឆ្នាំ ១៩៩៩ ដោយសារការខ្វះខាតជំនួយថវិកា ។

ជាការពិតដែលប្រទេសកម្ពុជាជាអ្នកទទួលជំនួយច្រើនពីម្ចាស់ជំនួយទៅលើគំរោងអភិវឌ្ឍប្រកបដោយចីរភាព និងទៅលើសកម្មភាពដែលធានាថាការអភិវឌ្ឍប្រកបដោយចីរភាពនៅតែជាផ្នែកអាទិភាព ។ នៅក្នុងទ្រឹស្តី ទោះជាមិនសូវបានអនុវត្តប៉ុន្តែការអប់រំគឺជាផ្នែកស្នូលមួយសំរាប់ការអភិវឌ្ឍដែលប្រកបដោយចីរភាព ។ ការអប់រំបរិស្ថាននៅតែឋិតនៅក្នុងភាពក្មេងខ្ចីនៅក្នុងប្រទេសកម្ពុជានៅឡើយ ប៉ុន្តែដោយផ្អែកលើឥទ្ធិពលខ្លាំងពីម្ចាស់ជំនួយ សកម្មភាពនេះបានកើនឡើងនូវការគាំទ្រ និងការយល់ដឹងបន្ថែមថាជាឧបករណ៍សំខាន់នៅក្នុងការកាត់បន្ថយបញ្ហាបរិស្ថានផ្សេងៗដែលកើតមាននៅក្នុងប្រទេសនៅពេលថ្មីនេះ ។ ការផ្តោតជាសំខាន់របស់គំរោងទៅលើការអប់រំបរិស្ថាននៅកម្ពុជាត្រូវបានក្លាយជាកម្មវិធីទីប្រឹក្សាបច្ចេកទេសបរិស្ថាន ក្នុងនោះមានអង្គការក្រៅរដ្ឋាភិបាលបីដែលធ្វើការផ្តោតលើការអប់រំបរិស្ថាន ក្នុងនោះមានអង្គការម្ជប់បៃតង អង្គការសង្គ្រោះសត្វព្រៃ និងអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន ។ បន្ថែមលើនេះ ក៏នៅមានស្ថាប័ន អង្គការ និងទីភ្នាក់ងារផ្សេងៗទៀតដែលបានចែករំលែកការអប់រំបរិស្ថានដោយប្រើប្រាស់នូវវិធីសាស្ត្រផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា ។

## ការអប់រំបរិស្ថានក្នុងប្រព័ន្ធ

សកម្មភាពផ្ទាល់ និងប្រយោលដែលទាក់ទងនឹងការអប់រំបរិស្ថាននៅក្នុងប្រព័ន្ធរួមមាន ៖ សកម្មភាពនៅតាមសាលា និងនៅក្នុងកម្មវិធីសិក្សា សិក្ខាសាលាកសាងសមត្ថភាព និងវគ្គបណ្តុះបណ្តាល ។ សកម្មភាពទាំងនេះច្រើនទាក់ទងទៅនឹងការអប់រំក្នុងប្រព័ន្ធនៅតាមសាលរៀន និងមហាវិទ្យាល័យ ។ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើនបរិមាណទៅលើប្រធានបទបរិស្ថាននៅក្នុងកម្មវិធីសិក្សាដូចជានៅថ្នាក់ទី៩ - ១២មានមុខវិជ្ជាបរិស្ថានដោយឡែក និងមុខវិជ្ជាផ្សេងទៀតដែលអាចបង្កើតប្រធានបទទាក់ទងនឹងបរិស្ថាន ។ ការលើកពីផ្នែកបំនិនជីវិតនៅក្នុងកម្មវិធីសិក្សានៅកម្ពុជាផ្តល់នូវឱកាសកាន់តែច្រើនសំរាប់ការអប់រំបរិស្ថានក្នុងការបញ្ចូលទៅក្នុងកម្មវិធីសិក្សា ។

អង្គការក្រៅរដ្ឋាភិបាលកំពុងធ្វើការជាមួយរដ្ឋាភិបាលទៅលើការបញ្ចូលការអប់រំបរិស្ថានទៅក្នុងកម្មវិធីសាលា ។ ឯកសារណែនាំសំរាប់អ្នកអប់រំបរិស្ថានត្រូវបានបង្កើត និងប្រើប្រាស់រួមគ្នាដោយអង្គការស្បៀងអាហារ និង កសិកម្មនៃសហប្រជាជាតិ អង្គការម្ជប់បៃតង អង្គការសង្គ្រោះសត្វព្រៃ និងអង្គការអូស្មូស ។ ក្លឹបបរិស្ថាន ក៏បានធ្វើឡើងនៅតាមសាលាជាមួយការបណ្តុះបណ្តាលបរិស្ថានដល់គ្រូបង្គោល និងសកម្មភាពសំរាប់សិស្សចូលរួម ។

ការបណ្តុះបណ្តាលរបស់រដ្ឋាភិបាលជាផ្លូវការទាក់ទងនឹងបរិស្ថានរួមមានសកម្មភាពនៅកំរិត បច្ចេកទេស និងការគ្រប់គ្រងក្នុងវិស័យព្រៃឈើ កសិកម្ម ជលផល សត្វព្រៃ និងការគ្រប់គ្រងតំបន់ការពារភាគច្រើនត្រូវបានអនុវត្តដោយដេប៉ាតឺម៉ង់



**ជាការពិតដែលប្រទេសកម្ពុជាជាអ្នកទទួលជំនួយច្រើនពីម្ចាស់ជំនួយ នៅលើគំរោងអភិវឌ្ឍន៍ប្រកបដោយចេរភាព និងនៅលើសកម្មភាព ដែលធានាថាការអភិវឌ្ឍប្រកបដោយចេរភាពនៅតែជាផ្នែកអាទិភាព**

បរិស្ថាននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងការិយាល័យបណ្តុះបណ្តាលការអប់រំបរិស្ថាន ។ ដេប៉ាតឺម៉ង់វិទ្យាសាស្ត្របរិស្ថានបានធ្វើការស្រាវជ្រាវលើបញ្ហាបរិស្ថានដែលកម្មវិធីស្រាវជ្រាវនេះអាស្រ័យលើការផ្តល់ជំនួយដែលសមស្របនឹងការធ្វើការស្រាវជ្រាវ ។ តួនាទីចំបងរបស់ដេប៉ាតឺម៉ង់បរិស្ថានទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្សទៅលើការគ្រប់គ្រងបរិស្ថាន ។

ការិយាល័យបណ្តុះបណ្តាលការអប់រំបរិស្ថានទទួលស្គាល់ថាជាមួយនឹងការមើលឃើញរបស់រាជរដ្ឋាភិបាលកម្ពុជានឹងប្រឈមមុខនឹងបញ្ហាសំខាន់ៗ នៅក្នុងការស្វែងរកការអភិវឌ្ឍប្រកបដោយចេរភាពដោយរួមបញ្ចូលទាំងកង្វះខាតផ្នែកធនធានហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីធានានូវសេវាកម្មចែកចាយដោយធ្វើការសង្កត់ធ្ងន់លើការចង់បាន និងតំរូវការខ្ពស់សំរាប់ការបណ្តុះបណ្តាលបរិស្ថានពីបុគ្គលិករដ្ឋាភិបាល និងបុគ្គលិករបស់គំរោងក្រៅរដ្ឋាភិបាល ។

ការបណ្តុះបណ្តាលគឺជាផ្នែកដ៏សំខាន់មួយដែលស្របនឹងសកម្មភាពរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងដូចគ្នានេះដែរមានការបណ្តុះបណ្តាលបរិស្ថានជាច្រើនត្រូវបានផ្តល់ទៅអោយអ្នកចូលរួមតាមរយៈអ្នកបណ្តុះបណ្តាលភាគច្រើនជាមួយដំណោះស្រាយល្អៗទៅលើគុណភាព ។ ការបណ្តុះបណ្តាលបច្ចេកទេសត្រូវបានសំដៅទៅលើការបង្កើតការអនុវត្តបរិស្ថានគំរូដើម្បីធ្វើអោយប្រសើរឡើងនូវផលិតភាព និងចេរភាពធនធានដោយផ្អែកលើការអនុវត្ត ។ ទោះជាយ៉ាងណាដើម្បីទទួលបានផលប្រយោជន៍ពីការគ្រប់គ្រងបរិស្ថានល្អ និងដើម្បីធានានូវចេរភាពធនធានធម្មជាតិជាចំបង គឺគុណភាពនៃកម្មវិធីបណ្តុះបណ្តាលនេះគួរត្រូវបានស្ទាបស្ទង់ដើម្បីធានាថាព័ត៌មានដែលបានបង្រៀន និងផ្តល់អោយដល់អ្នកចូលរួមជាព័ត៌មានដែលថ្មី និងត្រឹមត្រូវ ។

ការសំដែងល្ខោនបរិស្ថាន ដែលរៀបចំដោយអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន ក្រោមការឧបត្ថម្ភពី គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប







# លំដាប់ការអប់រំបរិស្ថានក្រៅប្រព័ន្ធមានលក្ខណៈចំរុះ ដោយសារវិសាលភាពនៃការអប់រំបរិស្ថានមានភាពទូលំទូលាយ

## ការអប់រំក្រៅប្រព័ន្ធ

ក្រសួងផ្សេងៗ អង្គការជាតិ និងអន្តរជាតិបានអនុវត្តលើសកម្មភាពនៅក្នុងផ្នែកអប់រំក្រៅប្រព័ន្ធរួមបញ្ចូលទាំងការប្រើប្រាស់ វិទ្យុ ផ្ទាំងរូបភាព ទូរទស្សន៍ និងកម្មវិធីពិសេសផ្សេងៗ បន្ថែមលើគំនិតដែលបានលើកឡើងនៅក្នុងផ្នែកការអប់រំក្នុងប្រព័ន្ធ។ ប្រមាណជាង ៨០% នៃអ្វីដែលយើងបានរៀនសូត្រត្រូវបានធ្វើឡើងនៅក្រៅការអប់រំក្នុងប្រព័ន្ធ ដូចនេះការអប់រំក្រៅប្រព័ន្ធជាផ្នែកសំខាន់សំរាប់ការអប់រំបរិស្ថាន។ លំដាប់ការអប់រំបរិស្ថានក្រៅប្រព័ន្ធមានលក្ខណៈចំរុះដោយសារវិសាលភានៃការអប់រំបរិស្ថានមានភាពទូលំទូលាយ ហើយក្នុងនោះអ្នកអនុវត្តខ្លះមិនអាចហៅអ្វីដែលពួកគេកំពុងធ្វើថាជាការអប់រំបរិស្ថានឡើយ ប៉ុន្តែវានៅតែអាចត្រូវបានចាត់ទុកថាជាការអប់រំបរិស្ថាន។

សកម្មភាពក្រៅប្រព័ន្ធនេះបង្កើតអោយមានការលេចឡើងនូវការអប់រំបរិស្ថាននៅកម្ពុជា។ គំនិតផ្តួចផ្តើមនៃការអប់រំបរិស្ថានក្រៅប្រព័ន្ធមានលក្ខណៈចំរុះ និងរួមគ្នាដូចជាកម្មវិធី "វិធានការចំរុះក្នុងការគ្រប់គ្រងកត្តាចង្រៃដែលត្រូវបានអនុវត្តនៅកំរិតសហគមន៍" ដែលទទួលបានការជួយជ្រោមជ្រែងពីអង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ និងកម្មវិធីសំរាប់ព្រះសង្ឃដែលផ្តួចផ្តើមដោយអេកូវិទូម្នាក់ដែលជាព្រះសង្ឃដើម្បីជំរុញសកម្មភាពឲ្យកាន់តែសកម្ម និងការសិក្សាបរិស្ថានតាមរយៈវត្តអារាម។ សហគមន៍ផ្សេងទៀតដែលផ្អែកលើគំរោងគ្រប់គ្រងសាកល្បងក៏បានបង្កើតឧបករណ៍អប់រំក្រៅប្រព័ន្ធដើម្បីជំរុញលើការអនុវត្តលើកសិកម្ម និងរុក្ខកម្មអោយកាន់តែប្រសើរឡើងដែរ។

## ការអប់រំបរិស្ថាននៅជុំវិញទន្លេសាប

ការអប់រំបរិស្ថាននៅក្នុង និងជុំវិញថបនីយជីវមណ្ឌលបឹងទន្លេសាបត្រូវបានចែកជាផ្នែកតូចៗ និងទៅតាមសហគមន៍ក្នុងតំបន់គោលដៅ ដល់គ្រូបង្រៀន និងសិស្សបឋមសិក្សា។ អ្នកផ្តល់នូវការចាប់ផ្តើមលើការអប់រំបរិស្ថានមានអង្គការអូស្មូស អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ អង្គការមូបបៃតង អង្គការសង្គ្រោះសត្វព្រៃ និងអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន (Live &Learn- ដែលទើបនឹងក្លាយជាអង្គការក្រៅរដ្ឋាភិបាលថ្មីនៅកម្ពុជា ដែលអង្គការនេះធ្វើការផ្តោតលើការអប់រំបរិស្ថាន) បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និង បុគ្គលិករដ្ឋាភិបាលនានា។ កន្លងមកពុំទាន់មានការវាយតំលៃហេតុប៉ះពាល់ជាផ្លូវការណាមួយត្រូវបានធ្វើលើការចាប់ផ្តើមនេះនៅឡើយទេ។ បញ្ហានេះធ្វើអោយមានការលំបាកក្នុងការវាយតំលៃ និងចែករំលែកមេរៀនពីវិធានការដែលទទួលបានជោគជ័យ និងមានប្រសិទ្ធភាព និងទៅលើវិធានការដែលនៅមានភាពខ្វះខាតដើម្បីធ្វើការកែលំអឡើងវិញ។ របាយការណ៍គំរោង Capacity 21 CBTS របស់កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិស្តីពីយុទ្ធសាស្ត្រសំរាប់ពង្រឹងសមត្ថភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពលើគំរោងក្នុងតំបន់ទន្លេសាបបានលើកឡើងថាការអប់រំបរិស្ថាននៅថបនីយជីវមណ្ឌលបឹងទន្លេសាបនៅតែស្ថិតនៅក្នុងភាពក្មេងខ្ចី។ ការធ្វើការវាយតំលៃរហ័សលើការយល់ឃើញជុំវិញបឹងទន្លេសាបដែលអនុវត្តដោយអង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន បានរកឃើញថាវាពិតជាស្ថិតនៅក្នុងភាពក្មេងខ្ចីមែន។

អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិនៅខេត្តសៀមរាបក្រោមកិច្ចសហការជាមួយអង្គការអូស្មូស និងអង្គការមូបបៃតងបានបង្កើតសៀវភៅណែនាំកម្មវិធីសិក្សាមួយដោយចេញផ្សាយ បាន ១០០០ ច្បាប់នៅឆ្នាំ ២០០៣ ដែលនៅក្នុងសៀវភៅនេះមាន១៨ផ្នែក។ មកដល់សព្វថ្ងៃនេះអង្គការអូស្មូសបានធ្វើការបណ្តុះបណ្តាលគ្រូ៤០នាក់នៅក្នុងសិក្ខាសាលា២ថ្ងៃដើម្បីអោយពួកគេអាចប្រើប្រាស់សៀវភៅនេះបាន។ អង្គការមូបបៃតងបានបណ្តុះបណ្តាលគ្រូ ២៥នាក់ដើម្បីប្រើផ្នែកផ្សេងៗនៃសៀវភៅនៅក្នុងការអនុវត្តកម្មវិធីសិក្សានៅតាមសាលាក្លឹបបរិស្ថានសំរាប់សិស្សបឋមសិក្សានៅក្នុងខេត្តកំពង់ស្ពឺ។ អង្គការសង្គ្រោះសត្វព្រៃបានបើកវគ្គបណ្តុះបណ្តាលរយៈពេលបីថ្ងៃដល់គ្រូជាង២០០នាក់ ដែលមកពីខេត្តកំពត កោះកុង ពោធិ៍សាត់ ក្រចេះ មណ្ឌលគិរី រតនៈគិរី និងខេត្តស្ទឹងត្រែងដោយប្រើផ្នែកផ្សេងៗនៃសៀវភៅនេះអង្គការទាំងពីរនេះបានចំណាយប្រាក់ឧបត្ថម្ភដល់គ្រូលើការបញ្ចូលការអប់រំពីបរិស្ថានអោយស្របនឹងមេរៀនសាលាដែល

  

សកម្មភាពនេះត្រូវបានគិតទុកសំរាប់ឲ្យមានការចូលរួមពីគ្រូដើម្បីអនុវត្តសកម្មភាព និង ផ្តល់នូវការលើកទឹកចិត្តសំរាប់អនុសាសន៍លើការពិនិត្យឡើងវិញលើសៀវភៅនេះ ។ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០០៤មក ដៃគូនេះបានធ្វើការពិនិត្យសៀវភៅណែនាំនេះឡើងវិញដោយយោងតាមអនុសាសន៍របស់គ្រូបង្រៀន។ ពួកគេកំពុងធ្វើការកែប្រែ និងបំរុងបោះពុម្ពជាលើកទីពីរនៅឆ្នាំ២០០៥នេះ ។ អង្គការម្លប់បៃតងក៏បានធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជាក្នុងមួយសប្តាហ៍ពីរដងជាផ្លូវការដែលកម្មវិធីនេះមានរយៈពេល១៥នាទីសំរាប់បញ្ហាបរិស្ថាន និងរយៈពេល១ម៉ោងសំរាប់ការទូរសព្ទ័ហៅចូលដើម្បីធ្វើការចោទសួរសំនួរផ្សេងៗ តែកន្លងមកប្រសិទ្ធភាពពិតប្រាកដនៃកម្មវិធីនៅមិនទាន់ជាវិធីសាស្ត្រដែលទទួលបានជោគជ័យនៅឡើយ ។

ការចូលរួមគ្រប់គ្រងធនធានធម្មជាតិរបស់អង្គការស្បៀងអាហារនៃសហប្រជាជាតិ និងកសិកម្មនៅក្នុងគំរោងតំបន់បឹងទន្លេសាប បានបង្កើតមជ្ឈមណ្ឌលតុកកែ (GECKO Center- Greater Environment- Chong Khneas Office) នៅឆ្នាំ១៩៩៩ ដោយមជ្ឈមណ្ឌលនេះជាកន្លែងតាំងពិព័ណ៌បណ្តែតទឹកមួយមានទីតាំងនៅភូមិចុងឃ្នាស ខេត្តសៀមរាប ។

មជ្ឈមណ្ឌលនេះបង្ហាញនូវការប្រកបរបរចិញ្ចឹមជីវិត និងបច្ចេកទេសនេសាទផ្សេងៗដែលត្រូវបានប្រើនៅក្នុងវបនីយជីវមណ្ឌលបឹងទន្លេសាបក៏ដូចជាការបង្ហាញផ្សេងទៀតពីជីវៈចំរុះ ។ បុគ្គលិកមជ្ឈមណ្ឌលបានសំគាល់ទុកថា អ្នកចូលទស្សនានៅថ្ងៃខាងមុខនឹងជាប្រជាជនសហគមន៍នេសាទនៅក្នុងតំបន់ អ្នកទេសចរ និងសិស្សបឋមសិក្សា តែទោះជាយ៉ាងណាអ្នកដែលចូលទស្សនាបច្ចុប្បន្នភាគច្រើនជាសិស្សសាលាដែលនៅជិតមជ្ឈមណ្ឌលនេះ ។ ពេលថ្មីៗនេះមានសិស្សសាលាបឋមសិក្សាដែលមានគ្នា ១៦ នាក់ធ្វើការទស្សនាមជ្ឈមណ្ឌលតុកែនេះក្នុងមួយសប្តាហ៍ម្តងក្នុងរយៈពេលមួយម៉ោងដែលសកម្មភាពនេះធ្វើឡើងដោយអនុវត្តតាមសៀវភៅណែនាំបរិស្ថាន ។តាមដឹងមកថាមានសិស្សប្រមាណ ៥០០០ នាក់បានចូលរួមនៅក្នុងផ្នែកខ្លះនៃវគ្គខ្លីៗជាមួយរឺដោយគ្មានការណែនាំនៅឯមជ្ឈមណ្ឌលតុកកែនេះ ។ មជ្ឈមណ្ឌលតុកកែបានលើកទឹកចិត្តដល់ការបង្កើតវីដេអូស្តីពីការការពារព្រៃលិចទឹកក៏ដូចជាទៅលើផ្ទាំងរូបភាព និងសញ្ញាដែលអាចផ្តល់ដល់ការយល់ដឹងលើបរិស្ថាន ។

អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិក៏បានរៀបចំសិក្ខាសាលាស្តីពីការអប់រំបរិស្ថានសំរាប់ព្រះសង្ឃ និងបានបង្កើតជាឯកសារណែនាំសំរាប់ការអប់រំបរិស្ថានដែលយកតាមទស្សនៈរបស់ព្រះពុទ្ធក្នុងនោះនៅតាមវត្តនីមួយៗមានព្រះសង្ឃ ៥អង្គត្រូវបានបណ្តុះបណ្តាល និងមានវត្ត៤ បានទទួលការបណ្តុះបណ្តាលនេះកន្លងមក ហើយអង្គការម្លប់បៃតងក៏បានអនុវត្តការបណ្តុះបណ្តាលតាមរយៈវត្តអារាមផងដែរ ។ អង្គការស្បៀងអាហារនិងកសិកម្មនៃសហប្រជាជាតិក៏បានធ្វើការចុះទៅដល់មូលដ្ឋានសំរាប់ការអប់រំនៅក្រៅប្រព័ន្ធនៅក្នុងសហគមន៍នេសាទផងដែរ យ៉ាងណាមិញការផ្តល់ជំនួយសំរាប់ពេលថ្មីៗនេះតំរូវអោយបន្តកម្មវិធីនេះបន្តទៀត ។ ឋិតក្នុងកំឡុងពេលនៃការអនុវត្តកម្មវិធីមានភូមិពីរបានចូលរួមនៅក្នុងការផ្តល់តួសំដែងសំរាប់ការផលិតខ្សែវីដេអូដែលលទ្ធផលបានបង្ហាញនូវការផ្លាស់ប្តូរអកប្បកិរិយាខ្លះដែលគួរអោយកត់សំគាល់ ។ អ្នកផ្តល់ការអប់រំបរិស្ថានសំខាន់ៗមានទីតាំងនៅព្រែកទាល់ និងនៅខេត្តសៀមរាប ដែលសកម្មភាពរបស់ពួកគេផ្តោតសំខាន់លើការផ្តល់ការយល់ដឹង និងសំដៅផ្តល់ដល់អ្នកដែលមានការយល់ដឹងទាប ។

សេវាកម្មអភិវឌ្ឍន៍គ្រួសារកម្ពុជា (CFDS) អង្គការស៊ីប៉ា (SIPAR) និងអង្គការNGO Forum បានបង្កើតសំភារៈខ្លះៗដែលភាគច្រើនជាផ្ទាំងរូបភាព និងរឿងសំរាប់សហគមន៍ប្រើប្រាស់ ។ មន្ទីរបរិស្ថានខេត្តនៅក្នុងខេត្តបាត់ដំបង និងពោធិ៍សាត់ក៏បានបង្កើតផ្ទាំងរូបភាពដែលឋិតនៅក្នុងកិច្ចសហការជាមួយនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថាន និងផ្នែកសំរបសំរួលបច្ចេកទេសនៅតំបន់ព្រែកទាល់ ។ អង្គការសហគមន៍កែច្នៃ និងអនាម័យ (CSARO) ធ្វើការនៅទីក្រុងភ្នំពេញលើគំរោងកែច្នៃឡើងវិញ ស្របគ្នានេះភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានចូលរួមជាមួយការបណ្តុះបណ្តាលការយល់ដឹងបរិស្ថាននៅក្នុងកំរិតរដ្ឋាភិបាល ។ ក្រសួងបរិស្ថានមានផ្នែកបរិស្ថានព័ត៌មាន និង ទំនាក់ទំនងដែលផ្តោតលើការបង្កើតលទ្ធភាពដល់សហគមន៍ឆ្ពោះទៅកាន់«ទិវាសំអាតពិភពលោក” និងព្រឹត្តបត្រប្រចាំត្រីមាស ។





គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបមានសកម្មភាពសំខាន់ៗពីរដែលទាក់ទងនឹងការអប់រំបរិស្ថានក្នុងនោះមានយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិ និងគំរោងផ្សព្វផ្សាយ អប់រំ និងសេវាចុះដល់មូលដ្ឋានស្តីពីបរិស្ថាន ។ គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបធ្វើការផ្តោតសំខាន់នៅតាមខេត្ត ដោយខេត្តមួយៗមានផ្នែកអនុវត្តគំរោង ដែលបុគ្គលិកនៃផ្នែកនេះត្រូវបានកំនត់ឲ្យមានសកម្មភាពលើការអប់រំបរិស្ថាន ។ បច្ចុប្បន្នបុគ្គលិកផ្នែកអនុវត្តគំរោងបានបង្កើតក្រុមអប់រំបរិស្ថាននៅខេត្តនីមួយៗជុំវិញបឹងទន្លេសាប ។ ពួកគេក៏បានផ្តួចផ្តើមសកម្មភាពមួយចំនួនដូចជាការបណ្តុះបណ្តាល ការបញ្ចាំងវីដេអូ ការបង្ហាញផ្ទាំងរូបភាព ការផ្សព្វផ្សាយច្បាប់ ថ្នាក់បរិស្ថានតាមសាលា និងសិក្ខាសាលាពីអនាម័យ និងបរិស្ថានជាដើម ។

ក្រសួងបរិស្ថានបានចុះកិច្ចសន្យាជាមួយអង្គការ "ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន" ទៅលើការអនុវត្តយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិនៅជុំវិញបឹងទន្លេសាប ។ យុទ្ធនាការនេះនឹងរួមមានវិធីសាស្ត្រអប់រំបរិស្ថានផ្សេងៗដូចជា : ការបង្កើតល្ខោន វិទ្យុ ទូរទស្សន៍ កម្មវិធីសិក្សា និងសកម្មភាពអនុវត្តគំរូ ។ អ្នកពាក់ព័ន្ធក្នុងតំបន់ និងថ្នាក់ជាតិនឹងដើរតួនាទីសំខាន់នៅក្នុងការបង្កើត និងអនុវត្តលើយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិនេះ ។ យុទ្ធនាការនេះសំដៅធ្វើឲ្យប្រសើរឡើងនូវការយល់ដឹងពីបញ្ហាបរិស្ថាននៅគ្រប់កំរិតក្នុងសង្គមកម្ពុជា ជាមួយការផ្តោតសំខាន់លើប្រព័ន្ធទាំងមូលនៃបឹងទន្លេសាប ។ យុទ្ធនាការនេះនឹងផ្តោតផងដែរលើគំនិតបរិស្ថានសេដ្ឋកិច្ច និងសង្គមលើផ្នែកផ្សេងៗនៃស្ថានប្រព័ន្ធដូចជាវាផ្តល់ជាអាហាររូបត្ថម្ភ សារៈសំខាន់នៃប្រពន្ធ័ទឹក ក៏ដូចជាកត្តាគំរាមកំហែងចំពោះមុខ និងប្រើលក្ខណៈពិសេសរបស់បឹងទន្លេសាបដើម្បីពន្យល់បន្ថែមពីសារៈសំខាន់នៃការប្រើប្រាស់ធនធានប្រកបដោយចេរភាពនៅកម្ពុជា ។

គំរោងអភិរក្សបឹងទន្លេសាបដែលជាផ្នែកមួយទៀតរបស់គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប នឹងធ្វើការផ្តោតផងដែរលើការអប់រំបរិស្ថាន ។ គំរោងនេះនឹងបង្កើត និងអនុវត្តកម្មវិធីផ្សព្វផ្សាយ អប់រំ និងសេវាចុះដល់មូលដ្ឋានស្តីពីបរិស្ថានដែលផ្តោតលើសកម្មភាពពីមុន សកម្មភាពដែលកំពុងអនុវត្ត និងផែនការរបស់ភ្នាក់ងាររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាប ដោយផ្តោតលើការអភិរក្សជីវៈចំរុះ ។ ការចែកចាយនឹងធ្វើតាមប្រព័ន្ធសាលា និងតាមរយៈមជ្ឈមណ្ឌលអប់រំបរិស្ថាន (មជ្ឈមណ្ឌលគ្រប់គ្រងតំបន់ស្នូល មជ្ឈមណ្ឌលបន្តែតទឹកនៅខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់ មជ្ឈមណ្ឌលតុកកែនៅខេត្តសៀមរាប) ដែលនឹងផ្តល់ជាមូលដ្ឋានគ្រឹះសំរាប់ការចុះទៀងទាត់ទៅដល់មូលដ្ឋាននៅជុំវិញបឹងទន្លេសាប ។



## ករណីសិក្សា

### អង្គការម្លប់បៃតង

អង្គការម្លប់បៃតងមានធនធានសំរាប់អប់រំបរិស្ថានជាច្រើនរួមមានដូចជាសំភារៈបោះពុម្ពផ្សាយ សំភារៈចាក់ផ្សាយ សំភារៈសំរាប់បង្ហាញផ្ទាល់ និង សេវាកម្មបណ្តុះបណ្តាល ក៏ដូចជាសកម្មភាពអនុវត្តផ្សេងៗទៀត ។ ខាងក្រោមនេះជាការសង្ខេបនូវវិធីសាស្ត្រមួយចំនួន :

***សំភារៈបោះពុម្ពផ្សាយ*** : អង្គការម្លប់បៃតងបានសហការជាមួយអង្គការសង្គ្រោះសត្វព្រៃ អង្គការមូលនិធិពិភពលោកសំរាប់អភិរក្សធម្មជាតិ និងអង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ ក្នុងការផលិតឯកសារណែនាំសំរាប់អ្នកអប់រំបរិស្ថាន ។ អង្គការនេះក៏បានផលិតឯកសារណែនាំសំរាប់ក្លឹបបរិស្ថាន មេរៀនសំរាប់សិស្សបឋមសិក្សា ព្រឹត្តិបត្របរិស្ថានខ្ញុំ







សំភារៈបង្រៀននៅគិរីរម្យ កូនសៀវភៅដាំកូនឈើ ម៉ូឌុលបណ្តុះបណ្តាលគ្រូបង្គោលបរិស្ថាន ផ្ទាំងរូបភាពអំពីស្តៅ គិរីរម្យ ព្រះពុទ្ធសាសនា ភ្នែកសត្វ និងអំពីត្រីដូហ្វីន ។ ក្រៅពីនេះអង្គការបានផលិតជាប្រតិទិនប្រចាំឆ្នាំ ដាមលិត ល្បែងបរិស្ថាន ស៊ីចយ័រ អាវយឺត និងម៉ាសមុខធ្វើពីក្រដាស់ប្រើប្រាស់ឡើងវិញ ។

**ការបណ្តុះបណ្តាល** : រួមមាន ទស្សនៈបរិស្ថានទូទៅ ការអប់រំបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងសំណល់ ការសំរបសំរួល ការអភិរក្សសត្វព្រៃ ការគូរគំនូរ ការបោះពុម្ព ព្រះពុទ្ធសាសនា និងបរិស្ថាន ការត្រួតពិនិត្យ និងវាយតំលៃ ការបណ្តុះបណ្តាលគ្រូបង្គោល ការវាយតំលៃជនបទដោយមានការចូលរួម ការធ្វើអត្តសញ្ញាណសត្វស្លាប និង បណ្តុះ និងបំប៉ៅដើមឈើ ។

**សំភារៈចាក់ផ្សាយ** : បានផលិតជាខ្សែវិដេអូស្តីពីការបង្កើតសហគមន៍ព្រៃឈើ ទេសចរណ៍ធម្មជាតិចំបក់ គិរីរម្យ និងឡូរាក ។ ពួកគេផលិតកម្មវិធីវិទ្យុបរិស្ថានប្រចាំសប្តាហ៍ ការសែតមា៉ញស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួពីសហគមន៍ និងស៊ីឌីចំរៀងបរិស្ថាន (www.mlup.org) ។

**សកម្មភាពអនុវត្តន៍ផ្ទាល់** : ចូលរួមទិវាតំបន់ដីសើមពិភពលោក និងទិវាបរិស្ថានជាតិ និងអន្តរជាតិ ទេសចរណ៍អប់រំ និងសកម្មភាពដាំដើមឈើ ។ សកម្មភាពគ្រប់គ្រងសំរាមនៅក្នុងខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ដោយបានបង្កើតជាធុងសំរាម និង សកម្មភាពស្រាវជ្រាវសំណល់ និងបញ្ហាបរិស្ថាន ត្រូវបានធ្វើនៅក្នុងខេត្តបី ។ ការចុះត្រួតពិនិត្យការងារនៅតាមតំបន់គោលដៅ ការរៀបចំទស្សនៈកិច្ចសិក្សាសំរាប់សហគមន៍ និងសាលារៀន ការចុះល្បាតសហគមន៍ព្រៃឈើ ។ រៀងរាល់ថ្ងៃព្រហស្បតិ៍នៅសាលាក្លឹបបរិស្ថានមានគ្រូដឹកនាំសិស្សធ្វើសកម្មភាពបរិស្ថាន ។




### មេរៀន ឬ បទពិសោធន៍ : មន្ត្រីគំរោងមជ្ឈមណ្ឌលធនធាន (លោក សេង វណ្ណដេត)

មុននឹងរៀបចំវគ្គបណ្តុះបណ្តាលអ្វីមួយគួរតែមានការវាយតំលៃពីតំរូវការវគ្គ ។ ដើម្បីអោយការពិភាក្សាជាក្រុមមានប្រសិទ្ធភាព គួរតែបែងចែកក្រុមទៅតាមចំនេះដឹងរបស់សិក្ខាកាម ។ ក្រុមចុះត្រួតពិនិត្យការងារគួរតែប្រើរចនាសម្ព័ន្ធដែលមានស្រាប់ ហើយវាជាការសំខាន់ដែលគួរតែមានប្រព័ន្ធឧបត្ថម្ភដល់ក្រុមការងារដែលចុះត្រួតពិនិត្យមុននឹងអនុវត្តគំរោងអ្នកគួរតែស្គាល់អោយច្បាស់លាស់ថា តើអ្នកណាខ្លះជាមនុស្សសំខាន់ដើម្បីធ្វើការងារជាមួយគ្នានៅក្នុងសហគមន៍ ។

### អ្នកសំរបសំរួលកម្មវិធី (លោក ស៊ីម គង់)

ដើម្បីអនុវត្តគំរោងអោយមានដំនើរការល្អ តំរូវអោយបុគ្គលិកម្នាក់ៗមានការទទួលខុសត្រូវច្បាស់លាស់ចំពោះការងារ ហើយគួរតែបញ្ចូលពួកគេអោយចូលរួមក្នុងការធ្វើផែនការ និងកិច្ចការដទៃទៀត ដើម្បីបង្កើនសមត្ថភាពក្នុងការអនុវត្តគំរោង ។ ការប្រើប្រាស់លក្ខណៈវិនិច្ឆ័យដើម្បីជ្រើសរើសតំបន់គោលដៅសំរាប់អនុវត្តការងារមានសារៈសំខាន់ណាស់ ។ ការចូលរួមពីសហគមន៍ដោយស្ម័គ្រចិត្តជាវិធីសាស្រ្តជោគជ័យមួយសំរាប់ការអនុវត្តគំរោង ។ ទស្សនៈកិច្ចសិក្សាជាវិធីសាស្រ្តល្អមួយក្នុងការផ្លាស់ប្តូរបទពិសោធន៍ និងចំនេះដឹងអោយគ្នាទៅវិញទៅមក ។ ការត្រួតពិនិត្យការងារ អាចជួយបុគ្គលិកក្នុងការអនុវត្តការងារ ជំរុញគុណភាពគំរោង និងអាចមានប្រយោជន៍នៅក្នុងការរៀបចំរបាយការណ៍ច្បាស់លាស់សំរាប់ម្ចាស់ជំនួយ ។








# ករណីសិក្សា

## ~អង្គការសង្គ្រោះសត្វព្រៃ

អង្គការសង្គ្រោះសត្វព្រៃមានវិធីសាស្ត្រអប់រំបរិស្ថានរួមមានដូចជា សំភារៈបោះពុម្ពផ្សាយ សំភារៈចាក់ផ្សាយ ការបណ្ដុះបណ្ដាល និងសកម្មភាពអនុវត្តផ្ទាល់ ។ ខាងក្រោមនេះជាការសង្ខេបនូវវិធីសាស្ត្រមួយចំនួន ៖

***សំភារៈបោះពុម្ពផ្សាយ*** ៖ អង្គការនេះបានផលិតសៀវភៅរឿងបរិស្ថានល្អៗ និងទទួលបានការចាប់អារម្មណ៍ ។ ការបោះពុម្ពទាំងនេះរួមមាន ឯកសារណែនាំសំរាប់គ្រូ និងព័ត៌មានដាក់លាក់អំពីសត្វព្រៃ និងបញ្ហាពាក់ព័ន្ធ ហើយត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ។ សៀវភៅរឿងរួមមាន "តើអ្នកលឺចំរៀងខ្ញុំទេ" „ដំនើរឆ្លងកាត់ព្រៃ" „ការប៉ះពពក" „ចេក និង ចូច" „បងខ្លា! បងខ្លា! ហេតុអ្វីបានជាបងលាក់ខ្លួន" "កូនដំរីស" "សំណាង និង ត្រីរាជ" "កូនខ្លាឃ្មុំ" និង"សៀវភៅពណ៌សត្វព្រៃកម្ពុជា" ។ សៀវភៅគំនូររូបកំប្លែងស្ដីពី „សិទ្ធិ" ដែលទើបផលិតនៅពេលថ្មីៗនេះ ។ សំភារៈបណ្ដុះបណ្ដាល និងកម្មវិធីសិក្សាត្រូវបានបង្កើតឡើងសំរាប់ដែនជំរកសត្វព្រៃភ្នំសំកុស ឧទ្យានជាតិបូកគោ និងភ្នំក្រវាញ ។ ប៉ូស្ទ័រ និងសៀវភៅស្ដើងៗត្រូវបានផលិតឡើងស្ដីពីច្បាប់តំបន់ការពារ និងច្បាប់ព្រៃឈើ ហើយពួកគេក៏បានផលិតជាល្បែងបរិស្ថានផងដែរ ។

***ការបណ្ដុះបណ្ដាល*** ៖ ការអប់រំបរិស្ថាន ការបណ្ដុះបណ្ដាលគ្រូបង្គោល ការបណ្ដុះបណ្ដាលគ្រូបង្រៀន និងអាជ្ញាធរដែនដី ច្បាប់តំបន់ការពារ និងច្បាប់ព្រៃឈើ ការបណ្ដុះបណ្ដាលគ្រូក្រៅប្រព័ន្ធ និងដែនជំរកសត្វព្រៃភ្នំសំកុស ។

***សំភារៈចាក់ផ្សាយ*** ៖ កម្មវិធីវិទ្យុប្រចាំថ្ងៃស្ដីពីសិទ្ធិ និងការទទួលខុសត្រូវ នឹងចាប់ផ្ដើមផ្សាយនៅក្នុងឆ្នាំ ២០០៦ មានខ្សែវីដេអូស្ដីពីការអភិរក្សសត្វព្រៃ និងមានគេហទំព័រ (www.cambodiaswildlife.org) ។

***សកម្មភាពអនុវត្ត*** ៖ មានការប្រជុំ សិក្ខាសាលា បទឧទ្ទេសបង្ហាញ ទស្សនៈកិច្ចសិក្សា ការបង្កើតលក្ខន្តិកៈ តាមមូលដ្ឋាន ការគូសដែនទីធនធាន ការកំនត់ព្រំប្រទល់ ការសំរបសំរួល និងការជួយដល់គណៈកម្មការគ្រប់គ្រង សហគមន៍ និងសមាគមកសិករ ។ អង្គការនេះក៏បានជួយទៅលើការចិញ្ចឹមជីវិតតាមរយៈការបណ្ដុះកូនឈើ និនការដាំដើមឈើឡើងវិញ ប្រពលវប្បកម្មស្រូវ ធនាគារស្រូវ និងបសុសត្វភូមិ និងអ្នកស្ម័គ្រចិត្តដាំដំណាំ ។

### មេរៀន ឬ បទពិសោធន៍ ៖ មន្ត្រីកម្មវិធី លោក ស៊ុន យូរ៉ា

នៅពេលមានទិវាសំខាន់ៗដូចជាទិវាបរិស្ថានពិភពលោក ជាការល្អត្រូវអញ្ជើញមន្ត្រីសំខាន់ៗចូលរួមដើម្បីបង្ហាញពី ការគាំទ្រ និងការចូលរួមការពារបរិស្ថាន ។មុននឹងអនុវត្តគំរោងកម្មវិធីនៅក្នុងសហគមន៍ជាការល្អត្រូវពន្យល់ពីគោលបំណងគំរោងអោយច្បាស់លាស់ដល់សហគមន៍ ក្រុមប្រឹក្សាឃុំ មន្ត្រីស្រុក និងអ្នកមានអំណាចដើម្បីអោយមានការគាំទ្រ និងចូលរួមក្នុងគំរោងកម្មវិធី ។ វាជាការសំខាន់ណាស់ក្នុងការកសាងទំនាក់ទំនងជាមួយអ្នកដែលមានឥទ្ធិពលមកលើគំរោងកម្មវិធី ជាពិសេសជាមួយអភិបាលស្រុក ។ កិច្ចសហការជាគន្លឹះមួយសំរាប់សកម្មភាពអប់រំបរិស្ថានគឺ ជួយបង្កើននូវការចែករំលែកព័ត៌មានរវាងអង្គការ និងអង្គការក៏ដូចជារវាងអង្គការ និងរដ្ឋាភិបាលដែរ ។ ការប៉ាន់ប្រមាណពីតំរូវការវគ្គបណ្ដុះបណ្ដាលគួរតែធ្វើអោយបានមុនវគ្គបណ្ដុះបណ្ដាល ។ ការវាយតំលៃសកម្មភាពគួរតែរៀបចំឡើងដើម្បីទទួលបានចំលើយតបដែលអាចជួយដល់ការកែលំអសកម្មភាពនោះ ។ ការបង្កើតសំភារៈសំរាប់បង្រៀនអោយបានច្រើនដើម្បីជួយដល់សហគមន៍មូលដ្ឋានជាពិសេសអ្នកដែលមិនចេះអក្សរ ។



# វេទិកាពិភាក្សាថ្នាក់ជាតិស្តីពីការអប់រំបរិស្ថាន ២០០៥

គោលបំណងរបស់វេទិកាពិភាក្សាថ្នាក់ជាតិស្តីពីការអប់រំបរិស្ថានមានពីរ ដោយយោងតាមអាទិភាពវាត្រូវបានធ្វើឡើងដើម្បីបង្កើននូវការយល់ដឹងអោយកាន់តែប្រសើរពីស្ថានភាពបច្ចុប្បន្ននៃការអប់រំបរិស្ថាននៅកម្ពុជា ហើយយើងក៏ចង់ដឹងពីគំនិតរបស់អ្នកអប់រំបរិស្ថាននៅកម្ពុជាថាតើយើងអាចធ្វើការនាំមុខជាគំរូដោយវិធីណា ។ វេទិកានេះក៏ត្រូវបានចាត់ទុកជាការផ្តល់ឱកាសសំរាប់អ្នកអប់រំបរិស្ថាន និងសង្ឃឹមថានឹងបង្កើតបានបណ្តាញការងារសំរាប់ការសហការលើសកម្មភាពអប់រំបរិស្ថាន ។

## សុន្ទរកថាបើករបស់ ឯកឧត្តម ស៊ិន ខំណ្ឌី អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន

ថ្ងៃនេះខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយដោយបានចូលរួមជាគណៈអធិបតីក្នុងពិធីបើកវេទិកាពិភាក្សាថ្នាក់ជាតិស្តីពី "ការអប់រំបរិស្ថាន" ដែលរៀបចំដោយអង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន" ដោយមានការសហការជាមួយគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប និងក្រសួងបរិស្ថានក្រោមការឧត្តម្ភថវិកាពីធនាគារអភិវឌ្ឍអាស៊ី ។ តាងនាមអោយក្រសួងបរិស្ថាន ខ្ញុំសូមសំដែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះភ្ញៀវកិត្តយសទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងថ្ងៃនេះ និងសូមកោតសរសើរដល់ការខិតខំប្រឹងប្រែងរបស់លោក-លោកស្រីលើការងារដែលទាក់ទងទៅលើការថែរក្សានិងកែលំអបរិស្ថាន ។ ខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំងដោយឃើញមានអ្នកចូលរួមច្រើនក្នុងវេទិកាពិភាក្សាថ្នាក់ជាតិស្តីពី "ការអប់រំបរិស្ថាន" នៅថ្ងៃនេះ ។ បច្ចុប្បន្នយើងគ្រប់គ្នាមានឱកាសរៀនសូត្រកាន់តែច្រើនពីគ្នាទៅវិញទៅមកនូវអ្វីដែលយើងកំពុងអនុវត្តនិងពិភាក្សាគ្នាថាតើយើងត្រូវធ្វើការរួមគ្នាយ៉ាងណាដើម្បីអោយការអបរំបរិស្ថាននៅកម្ពុជាកាន់តែមានប្រសិទ្ធភាពដោយផ្អែកលើបញ្ហាបរិស្ថានដែលយើងបានជួបកន្លងមក ។

លោក លាកស្រី នាងកញ្ញាតំណាងឲ្យក្រសួងស្ថាប័ន និងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ដែលមានវត្តមាននៅទីនេះ ខ្ញុំមានកិត្តិយសយ៉ាងខ្លាំងដែលថ្ងៃនេះយើងមានឱកាសជួបគ្នាហើយខ្ញុំសង្ឃឹមថាយើងនឹងមានកិច្ចសហការកាន់តែជិតស្និតថែមទៀតទៅលើសកម្មភាពនានាដែលទាក់ទងនឹងបរិស្ថាន ។ ខ្ញុំសូមបញ្ជាក់ថាការគ្រប់គ្រងបរិស្ថានក៏ដូចជាការអភិវឌ្ឍប្រកបដោយចេរភាវាមិនមែនជាបន្ទុករបស់រដ្ឋាភិបាលតែឯងនោះទេ ប៉ុន្តែវាត្រូវការបន្ថែមទៀតនូវសកម្មភាពចូលរួមពីប្រជាជនគ្រប់រូបនៅកម្ពុជា ។

ការជួបប្រជុំក្នុងវេទិកាថ្ងៃនេះពិតជាធ្វើឡើងស្របពេលជាមួយនឹងទសវត្សរ៍នៃការអប់រំបរិស្ថានប្រកបដោយចេរភាពរបស់អង្គការសហប្រជាជាតិសំរាប់ឆ្នាំ២០០៥-២០១៤ ដែលមានសារៈសំខាន់ខ្លាំង និងជំរើសដ៏ឈ្លាសវៃដែលកម្ពុជាប្រើការអប់រំបរិស្ថានដើម្បីឈានដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ប្រកបដោយចេរភាព ។ ខ្ញុំសូមលើកឡើងថាការអប់រំដើម្បីតែការយល់ដឹងតែម្យ៉ាងមិនគ្រប់គ្រាន់ទេ ប្រជាជនទាំងអស់គ្នាចាំបាច់ត្រូវមានជំរើសក្នុងការអនុវត្តដើម្បីអោយអកប្បកិរិយា និងសកម្មភាពរបស់ពួកគេអាចនឹងឈានដល់លក្ខណៈចេរភាព ។

ការយកចិត្តទុកដាក់ពីបរិស្ថានសំរាប់ប្រទេសកម្ពុជាកើតមានតាំងពីបុរាណមកម្លេះ ដូចជាតាមរយៈរូបសំណាកនាគរាជដែលតំណាងអោយម្ចាស់នៃប្រភពទឹក ជាងនេះប្រជាជនខ្មែរបានចាត់ទុកទឹកជាវត្ថុដែលមានសេរីសួស្តី និងជ័យជំនះរួមជាមួយការយកចិត្តទុកដាក់លើធម្មជាតិដែលនៅជុំវិញខ្លួនដូចជាព្រៃព្រឹក្សា និងសត្វជាដើម ។ រហូតដល់ឆ្នាំ១៩៩៣ ការអប់រំបរិស្ថានបានធ្វើឡើងស្របពេលជាមួយការបង្កើតក្រសួងបរិស្ថានដោយយុទ្ធសាស្ត្រនេះមានសារៈសំខាន់ខ្លាំងណាស់សំរាប់ការគ្រប់គ្រងប្រកបដោយចេរភាពទៅលើបរិស្ថាននៅកម្ពុជា ។ ការអប់រំបរិស្ថាននឹងជួយដល់ការឈានទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ជាពិសេសសំរាប់ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយចេរភាព យើងចាំបាច់ត្រូវធ្វើការគាំទ្រលើជំរើសរបស់ប្រជាជនព្រោះកាធ្វើបែបនេះពួកគេអាចមានជំរើសដែលប្រកបដោយចេរភាពដើម្បីអនុវត្តលើចំណេះដឹងរបស់ពួកគេ ។ គោលដៅដំបូងនៃការអប់រំបរិស្ថានគឺ ដើម្បីអោយប្រជាជនទាំងអស់មានការយល់ដឹងផ្នែកបរិស្ថាន និងឈានទៅដល់ការចូលរួមកាន់តែសកម្មលើការគ្រប់គ្រងបរិស្ថានធម្មជាតិក៏ដូចជាដើរតួនាទីក្នុងការធានានូវការប្រើប្រាស់ដែលមានលក្ខណៈចេរភាព ។ ដូចជាតាមរយៈ



ទន្លេមេគង្គដែលបានហូរកាត់ប្រទេសកម្ពុជា ក្នុងប្រវែងវែងជាងគេក្នុងបណ្តាប្រទេសទន្លេមេគង្គផ្សេងទៀត តែតាមរយៈការប្រើប្រាស់ដោយមិនបានយកចិត្តទុកដាក់ទៅលើការបំពុលនឹងធ្វើអោយគុណភាពទឹកធ្លាក់ចុះដូចនេះសង្ឃឹមថាការអប់រំបរិស្ថាននឹងជួយកែប្រែសកម្មភាពរបស់ពួកគេអោយមានលក្ខណៈប្រសើរឡើង ។

លោក-លោកស្រី នាងកញ្ញាជាទីគោរព ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមសំដែងនូវភាពរីករាយយ៉ាងខ្លាំងក្នុងការមកជួបអស់លោក-លោកស្រីទាំងអស់គ្នាក្នុងថ្ងៃនេះ ខ្ញុំសង្ឃឹមថាការពិភាក្សានៅវគ្គបន្តនឹងទទួលបាននូវសមិទ្ធិផល និងលទ្ធផលដែលប្រកបដោយផ្លែផ្កាក៏ដូចជាបង្កើននូវការសហការល្អក្នុងភាពជាដៃគូរវាងក្រសួង ស្ថាប័ន និងអង្គការទាំងអស់ពីវេទិកាថ្នាក់ជាតិនេះ ។

ជាទីបញ្ចប់នេះ តាងនាមអោយក្រសួងបរិស្ថានខ្ញុំសូមប្រកាសបើកវេទិកានេះ និងសូមជូនពរអោយអង្គវេទិកានេះទទួលបាននូវលទ្ធផលល្អៗសំរាប់យកទៅអនុវត្តនាពេលអនាគត ។ សូមអរគុណ!

# ការអប់រំបរិស្ថាន

*ដោយ លោក* ***នុប និមល*** *អនុប្រធាននាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាននៃក្រសួងបរិស្ថាន*

## ១-ភាពចាំបាច់នៃការអប់រំបរិស្ថាន

ការអប់រំបរិស្ថាន គឺជាការចាំបាច់ព្រោះបើគ្មានការអប់រំបរិស្ថានទេយើងមិនអាចបណ្តុះមនសិការយល់ដឹងបរិស្ថានដល់សាធារណជនបានឡើយហើយ ក៏មិនអាចចលនាសាធារណជនអោយចូលរួមការពារគាំពារ និងថែរក្សាបរិស្ថានបានដែរ ។ ការអប់រំបរិស្ថានត្រូវធានាអោយសាធារណជនយល់ដឹងពីអត្ថប្រយោជន៍នៃបរិស្ថានចំពោះការរស់នៅរបស់មនុស្ស និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមព្រមទាំងមានឥរិយាបថល្អចំពោះបរិស្ថាន និងធ្វើការកែប្រែអាកប្បកិរិយាខុសឆ្គងដែលធ្លាប់កើតមានកន្លងមក ។

*ខាងក្រោមជារូបភាពសមាជិកអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន : លោក ជុំ សំអួន លោក គាត ប៊ុនថាន និង កញ្ញា ពេជ្រ សុខជានី ជាមួយ ឯកឧត្តម សុិន វ័ណ្ឌី*







## ២-អនុសញ្ញា Tbilisi ស្តីពីការអប់រំបរិស្ថាន

ការអប់រំបរិស្ថានជាដំណើរដើម្បីឆ្ពោះទៅកាន់ស្ថានភាពមួយដែលប្រជាជនទូទាំងពិភពលោកមានការយល់ដឹងនិងការព្រួយបារម្ភពីបរិស្ថានទាំងមូលជាមួយបញ្ហាដែលពាក់ពន្ធ័ផ្សេងៗទៀត និងអោយប្រជាជនមានចំនេះដឹងឥរិយាបថ ការដឹងពីហេតុផលការតាំងចិត្ត និងជំនាញដើម្បីអនុវត្តដោយឡែកៗលើផ្នែកទាំងនេះ និងការបញ្ចូលគ្នាដើម្បីដោះស្រាយពីបញ្ហាបច្ចុប្បន្ន និង ការពារនូវបញ្ហានាពេលខាងមុខ ។ (UNESCO-UNEP1978) ។

ផ្នែកផ្សេងៗនៃការអប់រំបរិស្ថានសេចក្តីប្រកាស ធ្បីលីសី (Tbilisi) បានចែកគោលបំណងនៃការអប់រំបរិស្ថានជាផ្នែកផ្សេងៗដូចជា :

- **ការយល់ដឹង (តាមសម្បជញ្ញៈ)**: ដើម្បីជួយដល់បុគ្គល ក៏ដូចជាក្រុមដែលនៅក្នុងសង្គមទទួលបានការយល់ដឹង និងមានការយកចិត្តទុកដាក់ពីបរិស្ថានទាំងមូល និងបញ្ហាពាក់ព័ន្ធនឹងបរិស្ថាន ។

- **ចំណេះដឹង** : ដើម្បីជួយដល់បុគ្គល ក៏ដូចជាក្រុមដែលនៅក្នុងសង្គមឲ្យទទួលបាននូវបទពិសោធន៍ផ្សេងៗ និងទទួលបានការយល់ដឹងពីបរិស្ថាន និងបញ្ហារបស់វា ។

- **ឥរិយាបថ** : ដើម្បីជួយដល់បុគ្គលក៏ដូចជាក្រុមដែលនៅក្នុងសង្គមឲ្យទទួលបានទាំងគុណតំលៃ និងអារម្មណ៍លើការព្រួយបារម្ភណ៍ពីបរិស្ថាន និងការលើកហេតុផលដើម្បីឲ្យមានការចូលរួមយ៉ាងសកម្មនៅក្នុងការកែលំអ និងការពារបរិស្ថាន ។

- **បំណិនប្រសប់** : ដើម្បីជួយដល់បុគ្គលក៏ដូចជាក្រុមដែលនៅក្នុងសង្គមទទួលបានជំនាញសំរាប់ធ្វើការកំនត់ និងដោះស្រាយពីបញ្ហាបរិស្ថាន

- **ការចូលរួម** : ដើម្បីផ្តល់អោយបុគ្គល និងក្រុមដែលនៅក្នុងសង្គមនូវឱកាសដើម្បីអោយមានការចូលរួមយ៉ាងសកម្មនៅគ្រប់ថ្នាក់ក្នុងការងារឆ្ពោះទៅកាន់ដំណោះស្រាយលើបញ្ហាបរិស្ថាន ។ (UNESCO-UNEP 1978 p3)

## ៣-ផែនការអប់រំបរិស្ថាននៃបណ្តាប្រទេសក្នុងសមាគមអាស៊ាន :

ការអប់រំបរិស្ថាន គឺជាមធ្យោបាយដែលអាចធ្វើអោយប្រជាជនពង្រីកបានការយល់ដឹង ការចេះដឹង និងកង្វល់ពីបរិស្ថាន ហើយនិងយល់ពីគុណតម្លៃរបស់បរិស្ថានព្រមទាំងដំណើរកើតឡើងរបស់បរិស្ថានផងដែរ ។

ការអប់រំបរិស្ថានក៏មានគោលបំណងអោយប្រជាជនយកចំណេះដឹងដែលទទួលបានទៅអនុវត្តក្នុងកិច្ចគាំពារ អភិរក្ស និងប្រើប្រាស់ធនធានបរិស្ថានក្នុងរបៀបមួយប្រកបដោយចេរភាពសំរាប់ជាផលប្រយោជន៍ដល់មនុស្សបច្ចុប្បន្ន និងដល់អ្នកជំនាន់ក្រោយ ។

ទន្ទឹមនោះការអប់រំបរិស្ថានក៏ត្រូវបង្កើតអោយមានចំណេះដឹងជំនាញ ការមានអារម្មណ៍ជឿជាក់ព្រមទាំងការប្តេជ្ញាចិត្តក្នុងការបញ្ចេញសកម្មភាពជាបុគ្គល និងជាសមូហភាពដើម្បីដោះស្រាយលើបញ្ហាបរិស្ថានដែលនឹងទប់ស្កាត់មិនអោយបញ្ហាអាក្រក់ផ្សេងៗទៀតកើតមាន ។

ការយកចិត្តទុកដាក់ជាអាទិភាពរបស់បណ្តាប្រទេសក្នុងសមាគមន៍អាស៊ានគឺការងារអប់រំបរិស្ថាន តើត្រូវធ្វើយ៉ាងណាដើម្បីអោយការផ្សព្វផ្សាយរបស់អ្នកធ្វើការអប់រំថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិជ្រាបដល់កុមារកំពុងសិក្សានៅសាលា និងកុមារនៅក្រៅសាលា និងដល់មនុស្សពេញវ័យកំពុងបំរើការងារក្នុងជួររដ្ឋាភិបាលព្រមទាំងដល់ប្រជាជនគ្រប់ស្រទាប់វណ្ណៈក្នុងសង្គមដើម្បីទទួលបានចំណេះដឹងបរិស្ថានអោយបានទូលំទូលាយ ។

ផែនការអប់រំបរិស្ថានអាស៊ានត្រូវបានប្រើប្រាស់ជាគំរោងផែនការមួយដើម្បីពង្រឹងការអនុវត្តន៍លើសកម្មភាពអប់រំបរិស្ថាននៃបណ្តាប្រទេសក្នុងសមាគមអាស៊ានអោយបានព្រមៗគ្នាហើយផែនការអប់រំនោះរំពឹងថានឹងផ្តល់នូវភាពពិសិដ្ឋប្រកបដោយថាមពល និងកិច្ចសហការក្នុងការអនុវត្តន៍កម្មវិធីអប់រំបរិស្ថានសំរាប់បណ្តាប្រទេសជាសមាជិកនៃសមាគមអាស៊ាន ។



## ការអប់រំដោយគ្មានការអនុវត្ត ដូចជាត្រីដែលគ្មានទឹក

### ៤. ការអប់រំបរិស្ថាននៅកម្ពុជា ៖

**១-អ្នកអនុវត្ត ៖**

- ក្រសួងបរិស្ថាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- អង្គការសង្គមស៊ីវិលធ្វើការងារខាងបរិស្ថាន
- អង្គការអន្តរជាតិដែលជួយការងារបរិស្ថាន

**២-ការលំបាក ៖**

- ពុំមានថវិកាគ្រប់គ្រាន់សំរាប់ការងារអប់រំ
- ខ្វះគ្រូជំនាញការងារអប់រំបរិស្ថាន
- ខ្វះឯកសារជាភាសាជាតិ

**សំណូមពរ ៖**

ដើម្បីអោយការងារអប់រំបរិស្ថាននៅកម្ពុជាមានដំណើរប្រព្រឹត្តឡើងកាន់តែមានប្រសិទ្ធភាពសូមចូលរួមពិភាក្សាលើសំណួរទាំង ៧ ដែលបានដាក់ជូនសំរាប់សមាជិកអង្គវេទិកាពិភាក្សា ដូចមានក្នុងកម្មវិធីដែលបានចែកជូន ។

# ការអប់រំក្នុងប្រព័ន្ធ

បទបង្ហាញដោយ លោកស្រី **ថាច់ ធីសារ៉េន** អនុប្រធានការិយាល័យអភិវឌ្ឍកម្មវិធីសិក្សានៃនាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡា

### ១. ការអប់រំសំរាប់ទាំងអស់គ្នា

- ស្ថានភាពនៃការអប់រំនៅក្រោយសង្គ្រាម
- យុទ្ធសាស្ត្រការអប់រំសំរាប់ទាំងអសគ្នា
- ការអប់រំក្នុងប្រព័ន្ធ
- ការអប់រំក្រៅប្រព័ន្ធ
- គោលនយោបាយកម្មវិធីសិក្សាថ្មី

### ២. កម្មវិធីសិក្សាជាតិ

- ចំនេះដឹងកាន់តែខ្ពស់ផ្នែកអក្សរសាស្ត្រខ្មែរ និងគណិតវិទ្យា
- ការស្គាល់អត្តសញ្ញាណជាតិកាន់តែច្បាស់
- ការអភិវឌ្ឍការយល់ដឹងកាន់តែខ្លាំងពីសីលធម៌រស់នៅ និងការទទួលខុសត្រូវរបស់ពលរដ្ឋចំពោះប្រទេស
- បំនិនជីវិតប្រចាំថ្ងៃចាំបាច់សំរាប់ការចូលរួមក្នុងជីវភាពសហគមន៍មូលដ្ឋាន និងក្នុងសង្គមកម្ពុជា
- ការយល់ដឹងកាន់តែទូលំទូលាយពីពិភពលោក និងគោលការណ៍វិទ្យាសាស្ត្រ
- សមត្ថភាពកាន់តែខ្ពស់ក្នុងទំនាក់ទំនងជាភាសាបរទេស

### ៣. កម្មវិធីអប់រំបំនិនជីវិតតាមមូលដ្ឋាន

- រក្សាបំនិនតាមភូមិបញ្ញាអោយមានចេរភាព
- សិស្សមានសមត្ថភាពក្នុងការលើកកំពស់គុណភាពជីវិត
  ឧទាហរណ៍
  - ការផ្តល់ជាជំនាញផ្សេងៗ
  - ការអប់រំបរិស្ថានជាការភ្ជាប់លើកម្មវិធីបំនិនជីវិត

**១.សៀវភៅសិក្សា**

- បញ្ច្រាបខ្លឹមសារដែលទាក់ទងនឹងបរិស្ថានតាមមុខវិជ្ជាគោលផ្សេងៗភាសាខ្មែរ (សិក្សាសង្គម វិទ្យាសាស្ត្រ)
- មុខវិជ្ជាមួយដោយឡែក ៖ ផែនដីវិទ្យា (ថ្នាក់ទី៧-៩) ផែនដី និងបរិស្ថានវិទ្យា(ថ្នាក់ទី១០-១២)

**២.អំណានបន្ថែម**

- ឯកសារណែនាំសំរាប់អ្នកអប់រំបរិស្ថាន
- ឯកសារស្រាវជ្រាវ
- សៀវភៅរឿងមួយចំនួនដែលទាក់ទងនឹងធនធានបរិស្ថាន (សហការជាមួយ អង្គការម្ចប់បៃតង អង្គការសង្គ្រោះសត្វព្រៃ អង្គការស៊ីបា...ក្នុងការជួយពិនិត្យ និងវាយតំលៃ)
- ផ្ទាំងរូបភាពមួយចំនួនផលិតដោយអង្គការ UNESCO សំរាប់ ជាសំភារៈបង្រៀនផង ជាប័ណ្ណផ្សព្វផ្សាយផង





### ៣. វិធីសាស្ត្របង្រៀន

- ប្រើគោលវិធីសិស្សមជ្ឈមណ្ឌល
- មានសំភារៈឧបទ្ទេស
- អនុវត្តកុមារដើម្បីកុមារ រឺមិត្តដើម្បីមិត្ត
- ប្រព័ន្ធផ្សព្វផ្សាយ
- លេងល្បែងដើរតួ និទានរឿង សូត្រកំណាព្យ ច្រៀង...។

### ៤. សកម្មភាពអនុវត្តផ្ទាល់

- កែលំអបរិស្ថានសាលាអោយក្លាយជាបរិស្ថានសិក្សាកុមារមេត្រី
- ធ្វើពលកម្ម អនាម័យថ្នាក់រៀនសាលារៀន ទីសាធារណៈ
- ចូលរួមទិវាបរិស្ថាន និងការដាំដើមឈើ

### ៥. ផ្សេងៗ

- នៅតាមសហគមន៍ក៏មានការអប់រំអំពីបរិស្ថានដែរគឺធ្វើតាមរយៈការអប់រំក្រៅប្រព័ន្ធ
- ចាប់តាំងពី ឆ្នាំ២០០១នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមានបង្កើតដេប៉ាតឺម៉ង់បរិស្ថានវិទ្យា

### ៤. សន្និដ្ឋាន

- ប៉ុន្មានឆ្នាំចុងក្រោយនេះ ការអប់រំបរិស្ថាននៅតាមសាលារៀនក៏ដូចជាក្នុងស្រទាប់មហាជនទាំងអស់ដែរគឺអាចផ្តល់អោយប្រជាជនមាន ការយល់ដឹងច្រើនពីបញ្ហាបរិស្ថាន
- ប៉ុន្តែលទ្ធផលដែលទទួលបាននេះនៅពុំទាន់ដល់ចំនុចគោលដៅដែលក្រសួង អយក ចង់បាននៅឡើយព្រោះយើងនៅមានបញ្ហាចោទច្រើនក្នុងការអប់រំ បរិស្ថាន

  ខ-កង្វះធនធានមនុស្ស

  -ពេលវេលាសិក្សា និងសំភារៈ

  -សមត្ថភាព និងកំរិតជីវភាពគ្រួសារភាគច្រើននៅមានកំរិត

## សំភារៈ និង សកម្មភាពអប់រំបរិស្ថានដែលមានកន្លងមក

បទបង្ហាញដោយ លោក **គាត ប៊ុនថាន** ជំនាញការអប់រំបរិស្ថាននៃអង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន

### ១-ប្រភេទនៃការអប់រំបរិស្ថាន

- ការយល់ដឹង
- ចំនេះដឹង
- អាកប្បកិរិយា
- ជំនាញ
- ការចូលរួម

### ២-សំភារៈអប់រំបរិស្ថាន និង ឧទាហរណ៍

ព្រឹត្តិបត្រ ៖ វប្បធម៌ និងការនេសាទ (ការយល់ដឹង ចំនេះដឹង)

- គណៈកម្មការទន្លេមេគង្គ
  បដា និង ស្លាកសញ្ញាៈ សត្វព្រៃ ព្រៃឈើ (ការយល់ដឹង ចំនេះដឹង)
- ក្រសួងបរិស្ថាន
  សៀវភៅរឿងសំរាប់ក្មេងៗ ៖ រឿង ចេក និង ចូច (ការយល់ដឹង ចំនេះដឹង អាកប្បកិរិយា)
- អង្គការសង្រ្គោះសត្វព្រៃ
  សៀវភៅមេរៀន ៖ ដែនដី និងបរិស្ថានវិទ្យា (ការយល់ដឹង ចំនេះដឹង អាកប្បកិរិយា)
- នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួង អយក
  ឯកសារណែនាំ ៖ ឯកសារណែនាំពីការអប់រំបរិស្ថាន (ការយល់ដឹង ចំនេះដឹង ជំនាញ ការចូលរួម)
- អង្គការស្បៀងអាហារ និងកសិកម្ម
  ប៉ូស្ទ័រ ៖ ប្រភេទមច្ឆានៅកម្ពុជា (ការយល់ដឹង ចំនេះដឹង)
- នាយកដ្ឋានជលផល
  ចំរៀង ៖ តន្ត្រីធម្មជាតិ (ការយល់ដឹង ចំនេះដឹង ការចូលរួម)
- ក្រសួងបរិស្ថាន
  វិទ្យុៈ សំលេងអ្នកភូមិ (ការយល់ដឹង ចំនេះដឹង អាកប្បកិរិយា)
- អង្គការម្លប់បៃតង
  ទូរទស្សន៍ ៖ កម្មវិធីសំនួរ-ចំលើយបរិស្ថាន (ការយល់ដឹង ចំនេះដឹង ការចូលរួម)
- ក្រសួងបរិស្ថាន
  វីដេអូ ៖ បងប្អូនប្រុសពីរនាក់ (ការយល់ដឹង ចំនេះដឹង)



លោក គាត ប៊ុនថាន ជំនាញការអប់រំបរិស្ថាន
អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន



ក្រុម ១

- អង្គការ WWF
  ល្មោន ៖ ការការពារមច្ឆាជាតិ (ការយល់ដឹង ចំនេះដឹង អាកប្បកិរិយា ការចូលរួម)
- នាយកដ្ឋានសិល្បៈទស្សនីយភាព

### ៣- សកម្មភាពអប់រំបរិស្ថាន

ការបណ្តុះបណ្តាល ៖ វិទ្យាសាស្រ្តបរិស្ថាន (ការយល់ដឹ ចំនេះដឹង ជំនាញ ការចូលរួម)

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
  បណ្ណាល័យចល័ត ៖ (ការយល់ដឹង ចំនេះដឹង)
- អង្គការ WildAid
  ការធ្វើដីកំប៉ុស្ត ៖ ដីកំប៉ុស្តគោក កំប៉ុស្តទឹក (ការយល់ដឹង ចំនេះដឹង ជំនាញ ការចូលរួម)
- អង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍
  សួនបណ្តែតទឹក ៖ ដាំដំណាំ (ការយល់ដឹង ចំនេះដឹង ជំនាញ ការចូលរួម)
- អង្គការ អូស្មូស
  ក្លឹបបរិស្ថាន ៖ ការបណ្តុះកូនឈើ (ការយល់ដឹង ចំនេះដឹង ជំនាញ អាកប្បកិរិយា ការចូលរួម)
- អង្គការម្លប់បៃតង
  ការដាំកូនឈើ ៖(ការយល់ដឹង ចំនេះដឹង ជំនាញ ការចូលរួម)
- អង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍
  ការគ្រប់គ្រងសំណល់ ៖ ការកាត់បន្ថយ ការប្រើឡើងវិញ ការកែច្នៃឡើងវិញ (ការយល់ដឹង ចំនេះដឹង ជំនាញ ការចូលរួម)
- អង្គការ CSARO
  ទិវាសំខាន់ៗ ៖ ការតាំងពិព័រណ៍ទន្លេសាប (ការយល់ដឹង ចំនេះដឹង ការចូលរួម)
- អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល
  បណ្តាញការងារ ៖ ការប្រជុំបណ្តាញការងារថ្នាំពុល (ការយល់ដឹង ចំនេះដឹង ការចូលរួម)
- NGO Forum
  ការតស៊ូមតិ ៖ ច្បាប់ និងសិទ្ធិក្នុងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច (ការយល់ដឹង ចំនេះដឹង អកប្បកិរិយា ការចូលរួម)
- អង្គការ CLEC (Community Legal Education Centre)
- សកម្មភាពចេរភាពនៃប្រកបរបរចិញ្ចឹមជីវិត កសិកម្មសរីរាង្គ (ការយល់ដឹង ចំនេះដឹង ជំនាញ ការចូលរួម)
- អង្គការស្រែខ្មែរ

### ៤-ការសង្ខេបពីមេរៀនដែលបានរៀនសូត្រនៅកម្ពុជា សមត្ថភាព

- សមត្ថភាព ៖ អភិបាលកិច្ច និងសិទ្ធិក្នុងការប្រើប្រាស់ធនធានធម្មជាតិ និង ជីវៈចំរុះ
- នានាភាព ៖ ក្រុមគោលដៅ និង វិធីសាស្រ្ត
- សកម្មភាព ៖ ត្រូវការជំរើសដែលអាចធានាបានចេរភាព
- ការចូលរួម ៖ ក្រុមគោលដៅ និង គោលបំណង
- ការវាយតំលៃ ៖ សកម្មភាព និង សំភារៈ

## ក្រុម ១. ការចូលរួមនៅក្នុងការអប់រំបរិស្ថាន

ព័ត៌មានខាងក្រោមនេះបង្ហាញពីអ្នកដែលបានពាក់ព័ន្ធសំខាន់ៗក្នុងការអប់រំបរិស្ថាន ។ គួរចាប់អារម្មណ៍ថាការអះអាងរបស់ក្រុមគឺទៅលើតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាល និងមានតិចតួចបានលើកឡើងពីការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលដែលជាទូទៅបានលើកឡើងថា ពួកគេធ្វើទៅលើការអប់រំក្រៅប្រព័ន្ធ និងបានផ្តល់ផងដែរនូវការគាំទ្រផ្នែកបច្ចេកទេស និងសំភារៈទៅអោយរដ្ឋាភិបាល ។ ដំណោះស្រាយដែលល្អលើភាពលំអិតត្រូវបានផ្តល់លើតួនាទីរបស់រដ្ឋាភិបាលរួមជាមួយការចូលរួមដោយផ្ទាល់ពីក្រសួងរួមមាន ៖ ក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជននិង កីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធាន ទឹក និងឧតុនិយម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្មក្រសួងធម្មការ និងកិច្ចការសាសនា ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងទេសចរណ៍ ។ ជាពិសេសបញ្ជីក្រសួងដែលពាក់ព័ន្ធផ្ទាល់ និងប្រយោលទាំងនេះបង្ហាញពីការយល់ដឹងទូលំទូលាយនៃគ្រប់ផ្នែកទាក់ទងនឹងធម្មជាតិទាំងអស់នៃការអប់រំបរិស្ថាន ។






## ក្រុម ២. ការអប់រំបរិស្ថាន និងបោះពុម្ព ផ្សាយ

ការជ្រើសរើសសំភារៈដែលត្រូវបានភ្ជាប់នឹងការអប់រំបរិស្ថានត្រូវបានលើកបង្ហាញទុកជាសន្ទស្សន៍នៃការពង្រីកតួនាទីនៃការបោះពុម្ពផ្សាយព័ត៌មាននៅក្នុងការអប់រំបរិស្ថាននៅកម្ពុជា ។ សៀវភៅឯកសារណែនាំ ព្រឹត្តិបត្រ និងផ្ទាំងរូបភាពដែលបង្កើតជារូបភាពនៃការផ្សព្វផ្សាយនេះ ដោយឡែកក្រុមនេះនៅមិនទាន់បានលើកពីកាសែតនិងទស្សនាវដ្ដី ឡើយ ប្រហែលនេះមកពីយល់ថាក្រុមផ្សេងទៀតមានប្រធានបទដែលធ្វើការពិភាក្សាផ្ដោតលើសារព័ត៌មាន ។

## ក្រុម ៣. សកម្មភាព និងសំភារៈដែលត្រូវបានប្រើប្រាស់នៅសហគមន៍

សកម្មភាព និងសំភារៈអប់រំបរិស្ថានជាច្រើនដែលត្រូវបានប្រើប្រាស់ដោយផ្ទាល់ជាមួយសហគមន៍ ។ ការលើកបង្ហាញពីសកម្មភាពដែលត្រូវបានអនុវត្តទាក់ទងនឹង ការអប់រំបរិស្ថាននៅក្នុងសហគមន៍ជុំវិញប្រទេសកម្ពុជាខាងក្រោមមាន ការសង្កត់ធ្ងន់លើការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងការជំរុញការអប់រំបរិស្ថានដោយផ្ទាល់ជាមួយសហគមន៍ក្នុងនោះសកម្មភាពចំរុះត្រូវបានប្រើប្រាស់តាមរយៈការបញ្ចាំងវីដេអូជាវិធីសាស្ត្រមួយដែលមានគោលបំណងទូលាយសំរាប់ពង្រីកអត្ថន័យនៃការអប់រំបរិស្ថាននៅក្នុងសហគមន៍ ។

## ក្រុម ៤. ការអប់រំបរិស្ថាន និងការផ្សព្វផ្សាយព័ត៌មាន

ការផ្សព្វផ្សាយព័ត៌មានគឺជាវិធីសាស្ត្រដែលមានសារៈសំខាន់មួយនៅក្នុងការធ្វើអោយអត្ថន័យនៃការអប់រំបរិស្ថានជ្រាបទៅដល់ប្រជាជនកាន់តែច្រើន ។ ផ្នែកខាងក្រោមគឺជាការបង្ហាញខ្លះពីផ្នែកផ្សេងៗលើប្រភេទព័ត៌មានបច្ចុប្បន្នដែលបានបង្ហាញពីប្រធានបទបរិស្ថាន ។ គំរូសំខាន់ៗដែលផ្ដោតលើការផ្សព្វផ្សាយព័ត៌មានគឺ : ទូរទស្សន៍ វីដេអូ កាសែត តន្ត្រី និងវិទ្យុ ។




ការសំដែងល្ខោនបរិស្ថាន
រៀបចំដោយអង្គការ ការអប់រំស្ដីពីការរស់នៅជាមួយបរិស្ថាន
ក្រោមការឧបត្ថម្ភពី គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប









## ក្រុម ៥. សកម្មភាពដែលផ្តែកលើការអប់រំបរិស្ថាននៅកម្ពុជា

វាមានសារៈសំខាន់ដែរដែលក្រៅពីការនិយាយពីបរិស្ថានគេក៏មានសកម្មភាពបរិស្ថានដែលត្រូវបានគេអនុវត្តជាក់ស្តែង ។ ការបង្ហាញខាងក្រោមនឹងលើកពីសកម្មភាពទាំងនេះជាពិសេសទៅលើទិវាជាតិដែលមានការគាំទ្រពីរដ្ឋាភិបាលដូចជាទិវាសំខាន់ៗដែលរួមមានសកម្មភាពខ្លះដែលទាក់ទងនឹងបរិស្ថាន ។

## ឧបសគ្គក្នុងការអនុវត្តការអប់រំបរិស្ថាន

មានឧសគ្គកជាច្រើនដែលបានលើកឡើងដោយក្រុមពិភាក្សាផ្សេងៗ ទោះជាយ៉ាងណាឧបសគ្គដែលបានលើកឡើងជាទូទៅ គឺទាក់ទងនឹងភាពមានកំរិតនៃ ការយល់ដឹងរបស់ប្រជាជន ធនធានមនុស្ស ថវិកា និងសំភារៈ ហើយក៏មានលើកពីកង្វះខាតលើកិច្ចសហប្រតិបត្តិការ ការចែករំលែកព័ត៌មាន និងប្រសិទ្ធភាពនៃការចូលរួមក៏ត្រូវបានលើកឡើងដោយក្រុមមួយចំនួនថាជាឧបសគ្គនៃភាពក្រីក្រ ។ ការប្រើប្រាស់ភាសាក៏ត្រូវបានចាត់ទុកថាជាឧបសគ្គមួយដែលដំបូងគឺត្រូវបានបកប្រែជាភាសាខ្មែរ និងបញ្ចូលក្នុងកម្មវិធីសិក្សានិងទីពីរគឺថា ភាសាដែលបានប្រើប្រហែលជាមានកំរិតខ្ពស់ពេកសំរាប់អ្នកអានដូចដែលអនក្ខរកម្មគឺជាបញ្ហាចំបងមួយ ជាមួយគ្នានេះ ក្រមសីលធម៌បរិស្ថានក៏នៅមានកំរិតក្នុងចំនោមប្រជាជន ការអនុវត្តច្បាប់នៅមានកំរិត និងភាពពុករលួយក៏ត្រូវបានចាត់ទុកថាជាឧបសគ្គមួយដើម្បីធ្វើអោយការអប់រំបរិស្ថានមានប្រសិទ្ធភាពផងដែរ ។

## ការធ្វើអោយការអប់រំបរិស្ថានកាន់តែមានប្រសិទ្ធភាព

ដោយសារស្ថានភាពទូទៅរបស់ធម្មជាតិមានភាពទូលំទូលាយសំរាប់ធ្វើការអប់រំបរិស្ថាន ដូចនេះដំណោះស្រាយដែលបានលើកឡើងដោយក្រុមនីមួយៗដើម្បីធ្វើអោយការអប់រំនេះមានប្រសិទ្ធភាពមានលក្ខណៈផ្សេងៗគ្នា ។ ការលើកទឹកចិត្តឲ្យមានការចូលរួមបន្ថែមពីសំណាក់ប្រជាជនមូលដ្ឋានគឺជាគន្លឹះមួយដែលគួរយកចិត្តទុកដាក់ដូចជាការបង្កើតការងារថ្មីៗសំរាប់ប្រជាជនក្នុងតំបន់ និងប្រជាជនក្រីក្រ ។ ការបង្កើននូវកិច្ចសហប្រតិបត្តិការ និងសហការរវាងអ្នកពាក់ព័ន្ធទាំងអស់នោះលើបរិស្ថាន និងការកាត់បន្ថយអំពើពុករលួយដោយធ្វើការពង្រឹងការអនុវត្តច្បាប់ និងបង្កើនការគោរពច្បាប់ ។ ការសង្កត់ធ្ងន់ត្រូវបានគេផ្តែកលើគំរូការដើម្បីធ្វើអោយការផ្តល់ព័ត៌មានបរិស្ថានតាមរយៈការផ្សព្វផ្សាយព័ត៌មាន (ទូរទស្សន៍ វិទ្យុជាដើម) កាន់តែប្រសើរឡើងនូវគំរូការសំរាប់វិធីសាស្ត្រសំរាប់ធ្វើសកម្មភាពដឹកនាំដូចជាបណ្តុះបណ្តាលប្រជាជនមូលដ្ឋានលើការគ្រប់គ្រងធនធានធម្មជាតិ ដោយបង្កើតនូវកម្មវិធីវិជ្ជាជីវៈ បង្ហាញតួនាទីគំរូ សកម្មភាពពន្យល់បំភ្លឺ និង "ការរៀនសូត្រតាមរយៈការអនុវត្ត" ។ ក្រុមពិភាក្សាក៏បានលើកឡើងផងដែរថាវាមានសារៈសំខាន់ណាស់ក្នុងការធ្វើអោយសកម្មភាពនៃការអប់រំនេះមានលក្ខណៈសប្បាយ បង្កើតឯកសារជាភាសាខ្មែរអោយបានច្រើន និងប្រើប្រាស់ភាសាសាមញ្ញៗ ងាយយល់ធ្វើការជំរុញការលើកទឹកចិត្តដែលផ្តែកលើសកម្មភាពរបស់ប្រជាជនលើបរិស្ថានសកម្មភាពគោលដៅសំរាប់ក្រុមគោលដៅច្រើនស្វែងរកប្រភពជំនួយផ្សេងទៀត និងដើម្បីបង្កើតផែនការមានអនុភាពសំរាប់ភូមិនីមួយៗ ។

## ការពិភាក្សា និងសេចក្តីសង្ខេប

- មានអង្គការ និងស្ថាបន័ជាច្រើនធ្វើការងារអប់រំបរិស្ថាន ។
- អង្គការទាំងអស់មានវិធីសាស្ត្រអប់រំបរិស្ថានផ្សេងៗគ្នា ។
- ការអប់រំបរិស្ថាននៅជុំវិញយើង ។ ឧ. រៀងរាល់ថ្ងៃយើងឃើញការអប់រំបរិស្ថានទាំងនៅតាម ទូរទស្សន៍ វិទ្យុ និងនៅក្នុងសារព័ត៌មាន កាសែត ។
- មានឯកសារស្តីពីការអប់រំបរិស្ថានជាច្រើនដូចជាព្រឹត្តិបត្រ និងរបាយការណ៍ស្តីពីបរិស្ថាន ។
- មានគំរូអនុវត្តជាក់ស្តែងនៃការអប់រំបរិស្ថាន ដូចជាការចិញ្ចឹមសត្វ ការដាំដើមឈើ សួនដំណាំតាមផ្ទះ ការលែងត្រី ការគ្រប់គ្រងសំណល់ និងការប្រើចង្រ្កានសន្សំសំចៃថាមពលជាដើម ។
- មានឧបសគ្គជាច្រើនក្នុងការងារអប់រំបរិស្ថាន ប៉ុន្តែឧបសគ្គធំជាងគេគឺខ្វះនូវការវាយតំលៃ ។ បើគ្មានការវាយតំលៃយើងមិនដឹងថាឧបសគ្គណាខ្លះដែលជាឧបសគ្គសំខាន់ជាងគេនោះទេយើងទាំងអស់គ្នាត្រូវប្តេជ្ញាចិត្តធ្វើអោយការអប់រំបរិស្ថាននៅកម្ពុជាមានភាពប្រសើរឡើង ។



# បិទកម្មវិធី

## ការអប់រំដោយគ្មានការអនុវត្តន៍ គឺប្រៀបបាននឹងកាំបិតដែលទុកឱ្យច្រេះចាប់

ដើម្បីធ្វើអោយការអប់រំបរិស្ថាននៅកម្ពុជាឲ្យមានភាពប្រសើរឡើងយើងត្រូវ ៈ

- ធ្វើការរួមគ្នា
- ស្វែងរកជំរើស ឧទាហរណ៍មានអ្នកស្ម័គ្រចិត្តជាច្រើនដូចជាព្រះសង្ឃជាដើម
- ធ្វើសកម្មភាពអោយបានច្រើន
- ផ្លាស់ប្តូរអកប្បកិរិយា

## សន្ទរកថាបិទរបស់ ឯកឧត្តម ស៊ិន ខំណឺ អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន

គាំងនាមឲ្យថ្នាក់ដឹកនាំក្រសួងបរិស្ថាន និងក្នុងនាមខ្ញុំផ្ទាល់មានកិត្តិយស និងសេចក្តីសោមនស្សរីករាយជាអនេកដោយបានមកចូលរួមក្នុងពិធីបើកនិងបិទវេទិកាពិភាក្សាជាតិស្តីពី„ការអប់រំបរិស្ថាននៅកម្ពុជា" ដែលរៀបចំដោយអង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន ដោយមានការសហការជាមួយគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប និង ក្រសួងបរិស្ថានក្រោមការឧត្តម្ភថវិកាពីធនាគារអភិវឌ្ឍអាស៊ី ។ ខ្ញុំមានសេចក្តីរីករាយ និងសូមកោតសរសើរផងដែរពីលទ្ធផលដែលទទួលបានពីវេទិកាពិភាក្សាថ្នាក់ជាតិទៅលើ„ការអប់រំបរិស្ថាន" ថ្ងៃនេះ និងសូមថ្លែងអំណរគុណចំពោះភ្ញៀវកិត្តិយសទាំងអស់ដែលបានចូលរួមយ៉ាងសកម្ម និងបានធ្វើការពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ក្នុងគោលគំនិតទៅលើថាតើយើងត្រូវធ្វើការជំរុញការអប់រំបរិស្ថានប្រកបដោយប្រសិទ្ធភាពតាមវិធីណា ។ ព្រឹកមិញខ្ញុំបានស្តាប់បទអន្តរាគមន៍របស់ លោក នុប និមល អនុប្រធាននាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន នៃក្រសួង បរិស្ថាន អ្នកគ្រូ ថាច់ ធីសាវ៉ន អនុប្រធានការិយាល័យរៀបចំកម្មវិធីសិក្សានៃនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ និងលោក គាត ប៊ុនថាន ជំនាញការអប់រំបរិស្ថាននៃអង្គការ"ការអប់រំស្តីពី ការរស់នៅជាមួយបរិស្ថាន" ខ្ញុំមានការចាប់អារម្មណ៍និងពេញចិត្តណាស់ក្នុងការបង្ហាញអំពីគំនិតគន្លឹះសំខាន់ៗទាក់ទងដល់ការអប់រំបរិស្ថាននៅកម្ពុជាដូចជាការលើកឡើងពីបំនិនជីវិតប្រចាំថ្ងៃ និងរក្សាបំនិនតាមភូមិបញ្ញាឲ្យបានគង់វង្ស ការធ្វើអោយប្រជាពលរដ្ឋមានការកែប្រែអាកប្បកិរិយា និងសូមលើកឡើងពីសំណាងរបស់ប្រទេសយើងដោយមានរតនសម្បត្តិធំៗពីរគឺអង្គរវតដែលជាកេរតំណែលរបស់បុព្វបុរស និងបឹងទន្លេសាបដែលជាសម្បត្តិធម្មជាតិ ហើយជាងនេះគឺទន្លេមេគង្គដែលមានន័យថា"ម្តាយនៃទឹក" ដែលត្រូវការប្រើប្រាស់រៀងរាល់ថ្ងៃ ។ ខ្ញុំសូមបន្ថែមពីលើនេះទៀតថា ការអប់រំបរិស្ថាននៅកម្ពុជាមានតាំងពីសម័យដើមមកម្លេះ ដូចជាព្រះពុទ្ធបានយកធម្មជាតិដូចជាព្រៃឈើ និងសត្វព្រៃមកធ្វើជាបញ្ញាតិមុននឹងព្រះអង្គត្រាស់ដឹង ។ តែទោះជាយ៉ាងណា តាមរយៈអាកប្បកិរិយារបស់មនុស្សបានធ្វើអោយធនធានធម្មជាតិរេចរឹលជាលំដាប់ទោះជាសម្បត្តិទាំងនេះត្រូវបានបង្កើតឡើងយ៉ាងបរិបូរណ៍តាំងពីការកកើតផែនដីមកក៏ដោយ ។

ជាការពិតណាស់ដែលយើងមិនអាចប្តូរអតីតកាលបានប៉ុន្តែយើងអាចកសាងអនាគតមួយដែលមានភាពប្រសើរជាងនេះដូចជាតាមរយៈការអប់រំ យើងទាំងអស់គ្នាមានតួនាទីក្នុងការធ្វើអោយប្រទេសកម្ពុជាកាន់តែមានភាពភ្លឺស្វាងឡើងទាំងសំរាប់ពេលបច្ចុប្បន្ននិងអនាគត ។ ខ្ញុំនឹងនៅតែទន្ទឹងមើល និងទទួលយកនូវសកម្មភាពអប់រំបរិស្ថានដែលមានលក្ខណៈវិជ្ជមាននៅកម្ពុជា ហើយជឿជាក់ថាវេទិកា ពិភាក្សាថ្នាក់ជាតិដែលផ្តោតទៅលើ "ការអប់រំបរិស្ថាន" នៅថ្ងៃនេះគឺជាឧទាហរណ៍មួយនៃសកម្មភាពវិជ្ជមានដែលយើងនាំគ្នាមាន ក្តីសង្ឃឹមលើភាពសុខដុមរម្មនាទាពេលអនាគតកាលឆាប់ៗខាងមុខនេះ ។ ខ្ញុំសូមធ្វើការបញ្ជាក់ចំពោះមន្ត្រីរាជការ និងអង្គការក្រៅរដ្ឋាភិបាលរួមជាមួយអ្នកពាក់ព័ន្ធនានាមក ពីគ្រប់ខេត្ត-ក្រុង ដែលមានវត្តមាននៅទីនេះថា ខ្ញុំជឿជាក់ថាសកម្មភាពថ្ងៃនេះបានប្រព្រឹត្តឡើងដោយបានផ្តល់នូវទំនាក់ទំនងដ៏ជិតស្និតសំរាប់គ្រប់អ្នកចូលរួម និងអាចផ្តល់ជាឱកាសក្នុងការសហកាគ្នាទៅថ្ងៃមុខទៀត ។ ខ្ញុំក៏សូមធ្វើការរំលឹកដល់ភ្ញៀវកិត្តិយសទាំងអស់ថាយើងត្រូវការធ្វើការរួមគ្នា ដើម្បីលើកកំពស់ក្នុងការគ្រប់គ្រងបរិស្ថាននៅកម្ពុជាអោយកាន់តែប្រសើរឡើង ។ បន្ថែមលើនេះខ្ញុំក៏សូមធ្វើការកោតសរសើរផងដែរដល់លោក-លោកស្រីនាងកញ្ញាក្នុងការអនុវត្តសកម្មភាពកន្លងមកដើម្បីធ្វើការធានាដល់ការឈានទៅដល់ទិសដៅមួយនៃកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍការអប់រំបរិស្ថាន ដោយប្រកាន់លើគោលជំហរមួយថាសូមកុំរស់ដូចជាដើមត្នោតដែលដុះតែឯងដោយខ្វះសាមគ្គីភាព ។







អស់លោក-លោកស្រីជាទីរាប់អាន ថ្ងៃនេះយើងបានរៀនសូត្របន្ថែមពីអ្វីដែលពួកយើងទាំងអស់គ្នាកំពុងអនុវត្ត និងបានឆ្លងកាត់ការពិភាក្សាក្នុងគោលដៅបង្កើនប្រសិទ្ធភាពលើការអប់រំបរិស្ថាននៅកម្ពុជា ។ ខ្ញុំជឿជាក់ថា យើងទាំងអស់គ្នាប្រាកដជាទទួលបានមេរៀនច្រើនទាក់ទងពីការអប់រំបរិស្ថាននៅកម្ពុជាតាមរយៈការធ្វើការពិភាក្សាជាក្រុមនៅថ្ងៃនេះ និងអ្វីដែលសំខាន់បំផុតនោះខ្ញុំសង្ឃឹមថា លោក-លោកស្រី នាងកញ្ញានឹងអាចចែករំលែកបទពិសោធន៍នូវអ្វីដែលយើងបានរៀននៅថ្ងៃនេះដើម្បីធ្វើអោយសកម្មភាពអប់រំបរិស្ថានកាន់តែមានប្រសិទ្ធភាព ។ អ្វីដែលសំខាន់នោះខ្ញុំសូមធ្វើការលើកឡើងដដែលៗពីការពិតដែលថាអ្វីដែលយើងត្រូវការនោះគឺមិនត្រឹមតែការយល់ដឹងលើបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវជំរុញទៅលើសកម្មភាព និងឥរិយាបទនានាបន្ថែមទៀតដើម្បីជួយដល់ការគ្រប់គ្រង និងការពារបរិស្ថានសំរាប់ពេលបច្ចុប្បន្ន និងអនាគត ។

ជាថ្មីម្តងទៀត ខ្ញុំក៏សូមសំដែងនូវក្តីសោមនស្សរីករាយចំពោះភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងវេទិកាពិភាក្សាថ្នាក់ជាតិស្តីពី "ការអប់រំបរិស្ថាន" ជាពិសេសខ្ញុំសុំថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រីបរិស្ថានបុគ្គលិកអង្គការ "ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន" ដែលបានដុតដៃដុតជើងប្រឹងប្រែងខ្នះខ្នែងដើម្បីអោយអង្គវេទិកានេះទទួលបានជោគជ័យគួរជាទីគាប់ចិត្ត ។

ជាទីបញ្ចប់ខ្ញុំសូមជូនពរដល់ លោក លោកស្រី នាង កញ្ញា តំណាងក្រសួង ស្ថាប័ន និងអង្គការនានាដែលចូលរួមនៅថ្ងៃនេះ សូមអោយការធ្វើដំណើរត្រឡប់ទៅលំនៅដ្ឋានវិញប្រកបដោយសុវត្ថិភាព និងជួបតែនឹងសេចក្តីសុខគ្រប់ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភានៈ កុំបីឃ្លាងឃ្លាតឡើយ ។

ជាមួយគ្នានេះដែរ ខ្ញុំសូមអនុញ្ញាតប្រកាសបិទកម្មវិធីវេទិកាពិភាក្សាថ្នាក់ជាតិស្តីពី „ការអប់រំបរិស្ថាន" ចាប់ពីពេលនេះតទៅ ។ សូមអរគុណ!



# ករណីសិក្សា

## ~អង្គការអភិរក្សសត្វព្រៃ

អង្គការអភិរក្សសត្វព្រៃមានសកម្មភាពមួយចំនួន ដែលពាក់ព័ន្ធនឹងការអប់រំបរិស្ថានរួមមាន : សំភារៈបោះពុម្ពផ្សាយ សំភារៈចាក់ផ្សាយ ការបណ្តុះបណ្តាល និងសកម្មភាពអនុវត្តផ្ទាល់ ។ ខាងក្រោមនេះជាការសង្ខេបនូវសកម្មភាពមួយចំនួន :

**ការបោះពុម្ពផ្សាយ** : ពួកគេបានផលិតឯកសារល្អៗស្តីពីទន្សោងសាប សត្វស្លាប ថនិកសត្វ អណ្តើក និងតំបន់សំខាន់ៗសំរាប់ការអភិរក្សនៅក្នុងប្រទេសកម្ពុជា ។ ឯកសារណែនាំពីអត្តសញ្ញាណសត្វព្រៃក៏បានផលិតផងដែរ ។ ការបោះពុម្ពទាំងនេះក៏ត្រូវបានប្រើសំរាប់ការបណ្តុះបណ្តាល និងសកម្មភាពខទ្យានុរក្សផងដែរ ។ ពួកគេក៏បានឧបត្ថម្ភក្នុងការផលិតផ្ទាំងរូបភាពសត្វព្រៃរួមទាំងត្រីផ្សោតទន្លេមេគង្គ ជាមួយគ្នានេះពួកគេក៏ផលិតព្រឹត្តិបត្រប្រចាំខែដែលមានឈ្មោះថា „ព័ត៌មានសត្វស្លាបកម្ពុជា" ។

**ការបណ្តុះបណ្តាល** : ផ្តោតទៅលើការបណ្តុះបណ្តាលសមត្ថភាពខទ្យានុរក្សតំបន់ការពារជាសំខាន់ដើម្បីអាចបំពេញតួនាទីក្នុងកិច្ចការអភិរក្សអោយមានប្រសិទ្ធភាព ។ ពួកគេក៏ធ្វើការជាមួយ និងបណ្តុះបណ្តាលដល់ក្រុមអភិរក្សភូមិផងដែរ ។

**ការចាក់ផ្សាយ** : ពួកគេបានផលិតភាពយន្តឯកសារ និងខ្សែភាពយន្តខ្លីៗអំពីការអភិរក្សសត្វព្រៃសំរាប់សហគមន៍ ។ ពួកគេក៏មានគេហទំព័រ (www.wcs.org/international/Asia/Cambodia).



# ការពិនិត្យឡើងវិញ និង អនុសាសន៍

## ការធ្វើដំណើរដ៏វែងឆ្ងាយចាប់ផ្តើមឡើងដោយជំហានដំបូងក្នុងទិសដៅដែលត្រឹមត្រូវ

***សកម្មភាពអនុវត្តន៍ផ្ទាល់*** : ការងារភាគច្រើនរបស់ពួកគេផ្តោតទៅលើការប្រមូលទិន្នន័យ ដើម្បីជួយដល់ការគ្រប់គ្រង និងអភិរក្សសត្វព្រៃនៅកម្ពុជា ។ ពួកគេចូលរួមយ៉ាងសកម្មក្នុងការធ្វើផែនទីនៃការប្រើប្រាស់ដីធ្លី សត្វព្រៃ និងប្រភពធនធាន ហើយផ្សព្វផ្សាយព័ត៌មាននេះតាមរយៈរបាយការណ៍ សិក្ខាសាលា ការប្រជុំ និងការធ្វើបទខុទ្ទេសបង្ហាញ ទស្សនៈកិច្ចសិក្សាដែនការអភិរក្ស និងជួយអភិវឌ្ឍន៍គោលនយោបាយ ។ នៅក្នុងកំរិតមូលដ្ឋាន ពួកគេធ្វើការទៅលើការអភិវឌ្ឍនៃកិច្ចព្រមព្រៀងការប្រើប្រាស់ធនធានធម្មជាតិដោយមានការចូលរួម ។

***មេរៀន ឬបទពិសោធន៍ : មន្ត្រីអភិរក្សព្រៃកទាល់ លោក ស៊ុន វិសាល***

*ដើម្បីអនុវត្តគំរោងឲ្យមានប្រសិទ្ធភាព ជាការសំខាន់ត្រូវកសាងនូវទំនាក់ទំនងជាមួយសហគមន៍មូលដ្ឋាន ។ជាការប្រសើរមុននឹងដាក់ផ្លាកសញ្ញានៅក្នុងតំបន់ណាមួយត្រូវផ្សព្វផ្សាយ និងពន្យល់ពីគោលបំនងនៃការដាក់ផ្លាកសញ្ញាដល់សហគមន៍ ។ វិធីសាស្ត្រល្អមួយគឺត្រូវរៀបចំបណ្តុះបណ្តាលសហគមន៍មូលដ្ឋានអោយបានយល់ដឹងដើម្បីចូលរួមក្នុងសកម្មភាពគំរោង ។ ការរៀនសូត្រដោយអនុវត្តជាក់ស្តែងជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការធ្វើការជាមួយសហគមន៍ ។ បន្ទាប់ពីអនុវត្តសកម្មភាពជាការល្អត្រូវមានការវាយតំលៃតាមរយៈការចុះមើលការងារតាមមូលដ្ឋាន ការប្រជុំ និងការពិភាក្សាជាដើម ។ លើកទឹកចិត្តដល់អ្នកបរបាញ់សត្វអោយចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគំរោងដើម្បីអោយពួកគេយល់ដឹង ។*

# ការពិនិត្យឡើងវិញ

*ភាគច្រើនលទ្ធផលដែលគួរអោយកត់សំគាល់មួយចំនួនដែលទទួលបានពីវេទិការអប់រំបរិស្ថានថ្នាក់ជាតិ និងព័ត៌មានដែលប្រមូលបានសំរាប់របាយការណ៍នេះត្រូវបានរំលឹកឡើងវិញនៅក្នុងផ្នែកនេះក្នុងគោលបំណងដើម្បីស្វែងរកនូវអនុសាសន៍មួយចំនួនបន្ថែម ។*

*កម្ពុជាមានប្រវត្តិល្អទាំងក្នុងការងារអប់រំ និងការងារបរិស្ថាន ។ ព្រឹត្តិការណ៍នៅក្នុងអតីតកាលបានធ្វើអោយកម្ពុជាស្ថិតនៅដាច់ឆ្ងាយពីប្រទេសដទៃទៀតនៃពិភពលោកនៅពេលដែលបញ្ហាបរិស្ថានត្រូវបានគេលើកយកមកពិភាក្សានៅក្នុងកំរិតខ្ពស់បំផុតនោះ ។ ឥឡូវកម្ពុជាកំពុងតែឆ្លងកាត់រយៈពេលនៃការអភិវឌ្ឍយ៉ាងលឿន និងការផ្លាស់ប្តូរដែលកំពុងនាំទៅរកបញ្ហាបរិស្ថានដែលមានលក្ខណៈអវិជ្ជមានមួយចំនួន ។ ក្នុងការព្យាយាមកាត់បន្ថយបញ្ហាអវិជ្ជមានដល់បរិស្ថាន ការអប់រំបរិស្ថានកំពុងដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំនើរការនេះ ។*

*ដំបូងបង្អស់យើងត្រូវធ្វើការកត់សំគាល់ថាតើមានមនុស្សប៉ុន្មាននាក់ដែលកំពុងធ្វើការងារអប់រំបរិស្ថាននៅក្នុងប្រទេសកម្ពុជាដែលសកម្មភាពទាំងនេះកំពុងមានការលើកទឹកចិត្តដើម្បីមើលឃើញថាតើមានក្រសួង អង្គការ និងស្ថាប័ននានាប៉ុន្មានដែលធ្វើការក្រោមរូបភាពនៃការអប់រំបរិស្ថាន ។ ក្រុមទាំងអស់នេះមានវិធីសាស្ត្រផ្សេងៗគ្នាដោយសារគ្មានវិធីសាស្ត្រគំរូ និងការសំរបសំរួលថ្នាក់ជាតិសំរាប់ការអប់រំបរិស្ថាននៅមានកំរិត ។ ការអប់រំបរិស្ថានគឺទៅលើគ្រប់អ្វីៗទាំងអស់នៅជុំវិញយើង វាមានការពាក់ព័ន្ធទៅនឹងជីវិតយើងទាំងអស់គ្នា ។ មានកម្មវិធីព័ត៌មានជាតិស្តីពីបរិស្ថានដែលមាននៅក្នុងសារព័ត៌មាន ទូរទស្សន៍ និងវិទ្យុ ក្នុងនោះសារព័ត៌មានកាសែតទាំងឡាយកំពុងតែបង្កើនការផ្សព្វផ្សាយបញ្ហាបរិស្ថាន ។ មានសៀវភៅ របាយការណ៍ និង ប៉ូស្ទ័រជាច្រើនផងដែរដែលមានអត្ថន័យទាក់ទងនឹងបរិស្ថាន ។ យ៉ាងហោចណាស់សហគមន៍ជាច្រើនកំពុងតែទទួលបានក្នុងការបង្កើននូវការយល់ដឹងពីបរិស្ថាន ។ រដ្ឋាភិបាលកំពុងប្រើប្រាស់ទិវាជាតិផ្សេងៗដូចជា : ទិវាបរិស្ថាន រុក្ខទិវា*



ទិវាមច្ឆាជាតិ និងទិវាពលកម្មដើម្បីផ្សព្វផ្សាយពីបរិស្ថាន ។ គំរោងអនុវត្តន៍ជាក់ស្តែងពីការអប់រំបរិស្ថានដូចជាការចិញ្ចឹមសត្វ ការដាំដើមឈើ សួនដំណាំតាមផ្ទះ ការលែងត្រី ការគ្រប់គ្រងសំណល់ និងការប្រើចង្ក្រានសន្សំសំចៃថាមពលជាដើម ។

រៀងរាល់ថ្ងៃយើងឃើញសារបរិស្ថានទាំងឡាយ ប៉ុន្តែជាអកុសលខ្លឹមសារនេះតែឯងមិនមានឥទ្ធិពលគ្រប់គ្រាន់សំរាប់ផ្លាស់ប្តូរអាកប្បកិរិយាអវិជ្ជមានទាំងឡាយ ដូចនេះយើងត្រូវរកវិធីសាស្រ្តអោយកាន់តែមានប្រសិទ្ធភាព ដែលជាសំខាន់នោះយើងត្រូវធ្វើការអនុវត្តអោយបានច្រើន ។

***ការអប់រំដោយគ្មានការអនុវត្ត ដូចជាត្រីដែលគ្មានទឹក***

# អនុសាសន៍

*ដើម្បីដោះស្រាយនូវបញ្ហាខាងលើ ជាពិសេសដើម្បីពង្រឹងការអប់រំបរិស្ថាននៅកម្ពុជា ចាំបាច់ត្រូវបង្កើតនូវទិសដៅយុទ្ធសាស្រ្តមួយលើការអប់រំបរិស្ថាន (អាស៊ាន ២០០៣)*

វិធីសាស្រ្តយុទ្ធសាស្រ្តសំរាប់ការអប់រំបរិស្ថាននឹងគំរូវអោយធ្វើការនៅក្នុងតំបន់គោលដៅមួយចំនួន ។ ការផ្តល់អនុសាសន៍ផ្សព្វផ្សាយត្រូវបានផ្តោតលើក្រុមគោលដៅ ភាសា អត្ថន័យ ការពង្រឹក លទ្ធផល កិច្ចសហការ និងការវាយតំលៃ ។

## ក្រុមគោលដៅ

មានសកម្មភាពមួយចំនួនតូចដែលត្រូវបានរៀបចំឡើងសំរាប់ក្រុមគោលដៅខណៈដែលសកម្មភាពភាគច្រើនធ្វើសំរាប់អ្នកស្តាប់ជាទូទៅ ។ ភាគច្រើននៃអង្គការដែលធ្វើការទាក់ទងនឹងការអប់រំបរិស្ថានជាស្ថាប័នរដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាលដែលស្ថិតនៅក្រុងភ្នំពេញ ប៉ុន្តែ៨០ភាគរយនៃអត្រាប្រជាពលរដ្ឋគឺស្ថិតនៅក្រៅក្រុងភ្នំពេញ ។ ក៏មានការបញ្ជាក់មួយផងដែរទៅលើការប្រើប្រាស់ការបោះពុម្ពផ្សាយសំរាប់ការអប់រំបរិស្ថាន ។ ទោះជាយ៉ាងណាក៏អត្រាអក្ខរកម្មនៅក្រៅក្រុងភ្នំពេញនៅមានកំរិតទាបមានន័យថាសារបរិស្ថានមិនអាចជ្រាបទៅដល់ពួកគាត់បានច្រើនឡើយ ។ ហេតុផលមួយក្នុងចំនោមហេតុផលទាំងឡាយដែលវិធីសាស្រ្តនេះបានលើកឡើងគឺប្រហែលមកពីការខ្វះខាតនូវការវាយតំលៃលើសកម្មភាព និងសំភារៈអប់រំបរិស្ថាន ។ នៅពេលបង្កើតសកម្មភាព និងសំភារៈ ពួកយើងចាំបាច់ត្រូវពិចារណាល្អិតល្អន់ពីក្រុមគោលដៅលើអ្វីដែលគេចង់ធ្វើ ។

## ភាសា

អ្នកខ្លះនិយាយថាមិនមានព័ត៌មានបច្ចេកទេសបរិស្ថានគ្រប់គ្រាន់ជា ***ភាសាខ្មែរ*** ខណៈពេលដែលអ្នកខ្លះទៀតបញ្ជាក់ថាមានឯកសារជាច្រើននៅក្នុងការិល័យ ឬនៅក្នុងផ្ទះបុគ្គលមួយចំនួន និងមិនត្រូវបានយកមកប្រើប្រាស់ ។ មានការផ្តល់យោបល់ផងដែរអំពីវិធីសាស្រ្តដើម្បីធានាគុណភាពព័ត៌មាន-ឯកសារខ្លះមានព័ត៌មានផ្ទុយគ្នា ។ ជាទូទៅបញ្ហាមួយក្នុងចំនោមបញ្ហាទាំងឡាយគឺដោយសារតែខ្វះខាតនូវស្តង់ដាសំរាបការបកប្រែពាក្យ និងបច្ចេកស័ព្ទបរិស្ថាន ។ រហូតដល់មានស្តង់ដាសំរាប់ការបកប្រែទិន្នន័យបច្ចេកទេសនៅកម្ពុជានោះនឹងមានបញ្ហាមួយចំនួនក្នុងការទទួលយកគុណភាពខ្ពស់លើឯកសារជាភាសាជាតិ ។ យើងមិនអាចប្រើភាសាដែលមិនត្រឹមត្រូវ រឺជាហេតុផលដែលមិនអាចធ្វើទៅបានតែយើងត្រូវប្រុងប្រយ័ត្នជាមួយព័ត៌មានដែលយើងប្រើ និងថាតើត្រូវបកប្រែយ៉ាងដូចម្តេច ។

## អត្ថន័យ

***អត្ថន័យ*** នៃ "ការអប់រំបរិស្ថាន" មានការខុសប្លែកពីគ្នាទៅតាមអង្គការនីមួយៗ ហើយគួរតែត្រូវបានធ្វើសមយុទ្ធអោយទាន់ពេល ។ ការទទួលយករួមនៃទស្សនៈផ្សេងៗគ្នារវាងអ្នកពាក់ព័ន្ធ ទាំងឡាយតំរូវអោយមានការបញ្ជាក់ច្បាស់លាស់ដើម្បីបើកចំហនូវការជជែកពិភាក្សាគ្នាទៅលើការអប់រំបរិស្ថាន ។ តំរូវការផ្សេងៗត្រូវធ្វើយ៉ាងណាអោយមើលឃើញជាឱកាសជាជាងចំនុចខ្សោយ ប៉ុន្តែថាត្រូវធានាឲ្យបានថាការយល់ដឹងពីការអប់រំបរិស្ថានត្រូវបានធ្វើឡើងកាន់តែទូលំទូលាយ ។ យើងអាចធ្វើការផ្លាស់ប្តូរដោយយោងលើវិធីសាស្រ្តផ្សេងៗដើម្បីបង្កើនការយល់ដឹង និង ចំណេះដឹង និង ភាពកាន់តែសកម្មដែលផ្តោតលើការសង្កត់ធ្ងន់លើបញ្ហានៃការផ្លាស់ប្តូរអាកប្បកិរិយា ។





## ការផ្សព្វផ្សាយ

មកដល់ឥឡូវនេះការផ្តួចផ្តើមការអប់រំបរិស្ថានទាំងនេះធ្វើបានតែទៅលើប្រជាពលរដ្ឋមួយចំនួនប៉ុណ្ណោះ ។ កិច្ចប្រឹងប្រែងទាំងនេះតំរូវអោយមានការពង្រីកអោយបានគ្រប់តំបន់ក្នុងប្រទេស និងទៅដល់មនុស្សម្នាក់ៗ ។ កន្លងមកមានការប្រើប្រាស់រួចទៅហើយនូវសារព័ត៌មាន តែទោះជាយ៉ាងណា វិធីសាស្រ្តជាយុទ្ធសាស្រ្តផ្សព្វផ្សាយជាច្រើននឹងធ្វើឡើងដើម្បីបង្កើននូវការអប់រំបរិស្ថានជាតិ ។ ការពង្រីកការអប់រំបរិស្ថានចាំបាច់ត្រូវធ្វើអោយបានដោយអនុវត្តលើវិធីសាស្រ្តជាយុទ្ធសាស្រ្ត ប៉ុន្តែវិធីសាស្រ្តបែបនេះត្រូវពឹងអាស្រ័យលើធនធាន ។ យើងមិនអាចរង់ចាំតែធនធានហិរញ្ញវត្ថុ និងសមត្ថភាពទេ យើងត្រូវធ្វើអោយបាននូវអ្វីដែលយើងមាន ។នៅក្នុងវេទិកាថ្នាក់ជាតិស្តីពីការអប់រំបរិស្ថាន ព្រះសង្ឃបានស្នើអោយយើងប្រើវត្តអារាមដែលមានធនធានមនុស្សស្ម័គ្រចិត្តក្នុងការជួយផ្សព្វផ្សាយការអប់រំបរិស្ថាន ។ ពួកយើងចាំបាច់ត្រូវធ្វើការប្រើប្រាស់អោយកាន់តែប្រសើរនូវការគ្រប់គ្រងធនធានមានតំលៃទាំងអស់ដើម្បីពង្រីកអត្ថន័យ និងសកម្មភាពរបស់យើង ។

## លទ្ធផល

ភាគច្រើននៃសកម្មភាពអប់រំបរិស្ថានគឺផ្តោតទៅលើលទ្ធផលតាមរយៈ "ការយល់ដឹង" "ចំនេះដឹង" និង "អាកប្បកិរិយា" ជាមួយ "ជំនាញ" មួយចំនួនដែលផ្តោតតាមរយៈការបណ្តុះបណ្តាលនិងវិធីសាស្រ្តដែលមានកំរិតសំរាប់ "ការចូលរួម" ។ ការអប់រំបរិស្ថានពុំទាន់ត្រូវបានប្រើជាឧបករណ៍យុទ្ធសាស្រ្តសំរាប់ ទទួលបាន "លទ្ធផល" សំរេចនៅឡើយដោយសារកន្លងមកវាត្រូវបានប្រើប្រាស់ជាញឹកញាប់ដើម្បីសំរេចបាននូវលទ្ធផលចំពោះមុខប៉ុណ្ណោះដូចគ្នានឹងលទ្ធផលមួយដែលអាចមើលឃើញយើងចាំបាច់ត្រូវគិតពីមូលហេតុដែលយើងកំពុងធ្វើក្នុងការងារអប់រំបរិស្ថាន ។ តើលទ្ធផលរយៈពេលវែងអ្វីដែលយើងកំពុងព្យាយាមឲ្យសំរេចបាន ។ ជាមួយនឹងទស្សនៈដែលកាន់តែរឹងមាំនៃអ្វីដែលយើងចង់បានដើម្បីទទួលបានសំរាប់រយៈពេលវែង នោះសកម្មភាព និង សំភារៈរបស់យើងនឹងកាន់តែមានប្រសិទ្ធភាព?

## ការសំរបសំរួល

នៅកម្ពុជាសព្វថ្ងៃមានការកើនឡើងនូវតំរូវការសំរាប់ការសំរបសំរួលកាន់តែសកម្មលើសកម្មភាពអប់រំបរិស្ថាន ។ ក្រសួង ស្ថាប័ន និងអង្គការទាំងឡាយមាឱកាសច្រើនដើម្បីធ្វើការសហការយ៉ាងសកម្មជាមួយគ្នាដើម្បីធ្វើអោយការអប់រំបរិស្ថាននៅកម្ពុជាកាន់តែមានប្រសិទ្ធភាព ។ គោលបំនងនៃឯកសារនេះ គឺដើម្បីផ្សព្វផ្សាយ និងសំរបសំរួល និងធ្វើអោយប្រសើរឡើងនូវកិច្ចសំរបសំរួលលើការអភិវឌ្ឍសកម្មភាពទាំងឡាយដោយធ្វើការចងក្រងជាឯកសារនូវអ្វីដែលយើងបានដឹង ។ ជំហានបន្ទាប់គឺសំរាប់អ្នកអប់រំបរិស្ថានទាំងអស់ដើម្បីស្វែងរកកិច្ចសហការគ្នាទៅវិញទៅមកយ៉ាងសកម្មទៅលើសកម្មភាពដែលពាក់ព័ន្ធគ្នា ។ ជាជាងការធ្វើការត្អូញត្អែរពីកង្វះខាតនៃការសំរបសំរួល ចូរយើងធ្វើការនាំមុខដោយធ្វើជាគំរូ និងធ្វើការងារជាមួយគ្នា ។

## ការវាយតំលៃ

មានឧបសគ្គជាច្រើនសំរាប់ការអប់រំបរិស្ថានដែលត្រូវដោះស្រាយ ប៉ុន្តែឧបសគ្គមួយដែលធំជាងគេ និងសំខាន់ជាងគេគឺការខ្វះនូវ**ការវាយតំលៃ** ។ ដើម្បីអោយការអប់រំបរិស្ថានកាន់តែមានប្រសិទ្ធភាពជាការសំខាន់ត្រូវធ្វើការវាយតំលៃ ។ កិច្ចពិភាក្សាអ្នកចូលរួមជាច្រើនបានសួរពីរបៀបដែលធ្វើអោយការអប់រំបរិស្ថានមានប្រសិទ្ធភាព ។ គ្មានការវាយតំលៃ យើងមិនដឹងថាតើឧបសគ្គណាខ្វះដែលសំខាន់ជាងគេនោះទេ ។ ការអប់រំបរិស្ថានមានការលំបាកដើម្បីធ្វើការវាយតំលៃហើយវាតំរូវអោយមានកិច្ចប្រឹងប្រែងរួមគ្នាដើម្បីធ្វើការវាយតំលៃពីសំភារៈ និងសកម្មភាពផ្សេងៗដែលអាចធ្វើការវាយតំលៃដោយប្រៀបធៀប ។ ជាមួយនឹងការវាយតំលៃត្រូវបានបង្កើនយើងនឹងមានឱកាសដើម្បីធ្វើអោយការអប់រំបរិស្ថានកាន់តែមានប្រសិទ្ធភាព ។

## ការតាំងចិត្ត

យើងត្រូវមាន**ការតាំងចិត្ត**ដើម្បីធ្វើអោយការអប់រំបរិស្ថាននៅកម្ពុជាមានភាពប្រសើរឡើង ។ ទោះជាយ៉ាងណាដើម្បីធ្វើអោយសកម្មភាពនេះមានភាពប្រសើរឡើងនៅកម្ពុជាយើងត្រូវៈ



ធ្វើការរួមគ្នាក្នុងកិច្ចសហការមួយ និងផ្សព្វផ្សាយនូវជំរើសវិជ្ជមាន ។ ការសំខាន់បំផុតយើងមិនត្រូវគ្រាន់តែធ្វើការជជែកគ្នាទេតែយើងត្រូវធ្វើវាដោយខ្លួនយើងផ្ទាល់ ។ វិធីល្អបំផុតដើម្បីធ្វើការផ្លាស់ប្តូរឥរិយាបថរបស់អ្នកដទៃ គឺយើងត្រូវធ្វើការនាំមុខដោយធ្វើជាគំរូជាមុន ។

## ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនៅកម្ពុជាអោយឈានទៅមុខ

គំនិតនៃការអភិវឌ្ឍដែលប្រកបដោយចេរភាព គឺជាដំណើរដ៏វែងឆ្ងាយ និងមានភាពស្មុគស្មាញ ។ សកម្មភាពរបស់យើងមានសេដ្ឋកិច្ច សង្គម ទំនាក់ទំនងរវាងវប្បធម៌ និងបរិស្ថាន ។ ដូចដែលការអភិវឌ្ឍដែលមានលក្ខណៈចេរភាព គឺជាការអនុវត្តដែលគំរូវអោយមានការតាំងចិត្តដ៏ពិតប្រាកដ ការកែប្រែ និងការយល់ដឹងពីវប្បធម៌ ។ ការអប់រំបរិស្ថានជាយុទ្ធវិធីនៅក្នុងដំណើរឆ្ពោះទៅកាន់ការអភិវឌ្ឍដែលប្រកបដោយចេរភាព ។ ការបញ្ចូលវិធីសាស្ត្របែបយុទ្ធសាស្ត្រ និងការសហការទៅក្នុងការអប់រំបរិស្ថាននឹងជួយនៅក្នុងការបង្កើនប្រសិទ្ធភាពអោយមានកំរិតខ្ពស់ ។ នៅកំឡុងឆ្នាំ ២០០៤ ADB បានធ្វើការគាំទ្រដល់ការបង្កើតយុទ្ធសាស្ត្រអប់រំបរិស្ថានសំរាប់តំបន់បឹងទន្លេសាបរបស់អង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន ។ យុទ្ធសាស្ត្រនេះបានបង្ហាញពីឥទ្ធិពលនៃការអប់រំបរិស្ថានក្នុងការពង្រឹងការអភិវឌ្ឍដោយចេរភាព និងការកាត់បន្ថយភាពក្រីក្រ ។ យុទ្ធសាស្ត្រនេះក៏បានបង្ហាញថាការតាំងចិត្តរបស់សង្គមចំពោះលទ្ធផលនៃចេរភាពនៅក្នុងរយៈពេលខ្លីចាំបាច់ត្រូវធ្វើការវាយតំលៃជាថ្មីនៅគ្រប់កំរិត ។ យុទ្ធសាស្ត្រនៃការអប់រំបរិស្ថានត្រូវបានបង្កើតដោយរួមបញ្ចូលនូវគ្រប់បញ្ហានៃចេរភាព និងបញ្ហាជាចំពោះមួយចំនួនដែលកំពុងកើតឡើងនៅជុំវិញ បឹងទន្លេសាប និងប្រជាជនដែលរស់ពឹងផ្អែកលើវា ។ យុទ្ធសាស្ត្រនេះធ្វើឡើងដើម្បីស្វែងរកតុល្យភាពនៅក្នុងរូបភាពបរិស្ថានជាមួយនឹងការអភិរក្ស សិទ្ធមនុស្ស និងសន្តិភាព បន្តផ្តល់ការទ្រទ្រង់អាហារ ការថែរក្សាសុវត្ថិភាព និងសុខភាព និងបន្តការរីកដុះដាលដីវចំរុះអភិបាលកិច្ចល្អ និងសេដ្ឋកិច្ចក្នុងតំបន់ ។ ទំហំពិតប្រាកដនៃបញ្ហាទាំងនេះបង្ហាញថាវាមានសារៈសំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្រទៅលើចំនុចតូចជាបឋមជាមួយការផ្តោតលើការប្រើប្រាស់ចំនេះដឹងមុន និងក្រោយដើម្បីបង្កើតសកម្មភាពអនុវត្ត ដើម្បីការអភិវឌ្ឍប្រកបដោយចេរភាព ។ គោលបំណងចំបងនៃយុទ្ធសាស្ត្រនេះគឺដើម្បីធ្វើការជំរុញការអប់រំបរិស្ថានដោយចាត់ទុកថាជាស្នូលនៃការស្វែងរកជាទូទៅនៃការអភិវឌ្ឍដែលប្រកបដោយចេរភាពនៅក្នុងតំបន់បឹងទន្លេសាប ។ ការគំរូវឲ្យបង្កើតការស្រាវជ្រាវបែបសាកសួរពីទស្សនៈក្នុងតំបន់បញ្ហាបរិស្ថានត្រូវបានសន្និដ្ឋានថាអាចយកជាការបានដោយយោងលើគោលបំនង ៥គឺ ៖

១. បង្កើតខ្សែរយៈ និងបណ្តាញការងារ ផ្លាស់ប្តូរ និងពិភាក្សាជាមួយបណ្តាអ្នកពាក់ព័ន្ធនៅការអប់រំបរិស្ថាន
២. ផ្តល់ពេល និងឱកាសដើម្បីបង្កើត និងជំរុញសកម្មភាពឆ្ពោះទៅកាន់ការអភិវឌ្ឍដែលប្រកបដោយចេរភាព
៣. បង្កើនគុណភាព និងសមត្ថភាពនៃការរៀនសូត្រ និងការបង្រៀននៅក្នុងផ្នែកនៃការអប់រំបរិស្ថាន
៤. ធ្វើការកែច្នៃការអប់រំបរិស្ថានឆ្ពោះទៅកាន់ ការអភិវឌ្ឍប្រកបដោយចេរភាពសេដ្ឋកិច្ច និងការប្រកបរបរចិញ្ចឹមជីវិត
៥. ពង្រីកឱកាស និងជំនាញនៃការចូលរួមជាសាធារណៈនៅក្នុងសង្គមស៊ីវិល ។

យុទ្ធសាស្ត្រនេះសំដៅអនុវត្ត និងផ្សារភ្ជាប់ជាមួយការផ្តួចផ្តើមជាវិជ្ជមាន និងជាអាទិភាពនៃរដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាល និងធ្វើការភ្ជាប់ជាសំខាន់ជាមួយគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប និងយុទ្ធសាស្ត្រអាងទន្លេសាប ។ វិធីសាស្ត្រសំខាន់ៗទាំង ៥ ត្រូវបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រ ដែលយុទ្ធសាស្ត្រទាំងនេះអាចជួយនៅក្នុងការឈានទៅដល់ការសំរេចបាននូវគោលបំណងខាងលើដែលផ្តោតលើ ៖

១.ការបង្កើតឆន្ទះល្អ និងភាពជាដៃគូ
២.គំនិតរិះគន់ និងការកែប្រែ
៣.ការយល់ដឹងជាសាធារណៈ និងការកសាងទស្សនៈ
៤.ការអប់រំក្នុងប្រព័ន្ធ និងការបណ្តុះបណ្តាល
៥.ការភ្ជាប់ការអនុវត្តទៅនឹងគោលនយោបាយ

វិធីសាស្ត្រទាំងនេះសំដៅដើម្បីបង្កើតផ្លូវ និងចក្ខុវិស័យសំរាប់ការអភិវឌ្ឍ ដោយចេរភាពនៅកម្ពុជា យើងលើកវាឡើងដោយចាត់ទុកថាជា "វិធីសាស្ត្រឈានទៅមុខ" ។






# ករណីសិក្សា

## ៖អង្គការមូលនិធិពិភពលោកសំរាប់អភិរក្សធម្មជាតិ

អង្គការមូលនិធិពិភពលោកសំរាប់អភិរក្សធម្មជាតិប្រើប្រាស់វិធីសាស្ត្រសំរាប់ការអប់រំបរិស្ថានរួមមាន ៖ សំភារៈ បោះពុម្ពផ្សាយ សំភារៈចាក់ផ្សាយ ការបណ្តុះបណ្តាល និងការអនុវត្តសកម្មភាព ។ ខាងក្រោមនេះជាការសង្ខេបនូវវិធីសាស្ត្រមួយចំនួន

***ការបោះពុម្ពផ្សាយ*** បានផលិតជាផ្ទាំងរូបភាព និងមានកិច្ចសហការជាមួយអង្គការដទៃទៀតស្តីពីសកម្មភាពឧទ្យានុរក្ស ។ សហការជាមួយអង្គការអុកស្វាមអាមេរិច និងមជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់ដើម្បីបង្កើតវិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ។ របាយការណ៍ និងករណីសិក្សាជាច្រើនត្រូវបានបង្កើតឡើងដើម្បីលើកយកទិន្នន័យស្រាវជ្រាវគោលគំនិតសំខាន់ៗពីគំរោងបង្កើតជាអេកូថ្នាក់តំបន់ និងផ្តល់ជាមូលដ្ឋានគ្រឹះសំរាប់ការវាយតំលៃ និងផ្តល់ព័ត៌មានដែលមានសារៈប្រយោជន៍ទៅលើការគ្រប់គ្រងធនធានដោយមានការចូលរួមពីសហគមន៍ ។ អង្គការនេះក៏បានសហការជាមួយ អង្គការម្ចប់បៃតង អង្គការសង្គ្រោះសត្វព្រៃ និងអង្គការស្បៀងអាហារ និងកសិកម្មដើម្បីបង្កើតជាឯកសារណែនាំសំរាប់អ្នកអប់រំបរិស្ថាន ។

***ការបណ្តុះបណ្តាល*** ពួកគេបានរៀបចំវគ្គបណ្តុះបណ្តាលសំរាប់បុគ្គលិកមន្ត្រីរដ្ឋាភិបាល ឧទ្យានុរក្ស សហគមន៍មូលដ្ឋាន និងក្រុមដែលពាក់ព័ន្ធដទៃទៀតទៅលើប្រធានបទដូចជាការគ្រប់គ្រងល្អ ការប្រើប្រាស់ច្បាប់ ការចិញ្ចឹមជីវិតដោយមានជំរើស ការគ្រប់គ្រងព្រៃឈើ ការប៉ាន់ប្រមាណ និងការគូសផែនទីធនធាន ការស្រាវជ្រាវ ការវិភាគ និងជំនាញការប្រមូលឯកសារ ។

***ការចាក់ផ្សាយ*** អង្គការបានផលិតជាឯកសារភាពយន្តមួយចំនួនជាពិសេសនោះ អង្គការមូលនិធិពិភពលោកសំរាប់អភិរក្សសត្វព្រៃ-សហរដ្ឋអាមេរិច ក៏បានផលិតជាខ្សែវីដេអូដែលមានឈ្មោះថា បងប្អូនប្រុសទាំងពីរ ។ ពួកគេក៏បានគេហទំព័រ (www.wwfindochina.org)

***សកម្មភាពអនុវត្ត*** ឧទ្យានុរក្សទាំងឡាយត្រូវបានបណ្តុះបណ្តាល និងផ្គត់ផ្គង់បរិក្ខារ សំរាប់ការចូលរួមក្នុងការប៉ាន់ប្រមាណ ការចុះល្បាត និងការប្រតិបត្តិច្បាប់ ការគ្រប់គ្រងព្រៃឈើ និងការគូសផែនទីធនធានជីវចំរុះ ។ សកម្មភាពសហគមន៍រួមមាន កិច្ចព្រមព្រៀងសហគ្រប់គ្រង ការប្រកបមុខរបរចិញ្ចឹមជីវិតដោយមានជំរើស និងប្រកបដោយចេរភាព ការធ្វើផែនការ ប្រើប្រាស់ដីធ្លីដោយមានការចូលរួម ចំណេះដឹងប្រពៃណី (ការចិញ្ចឹមជីវិតតាមលក្ខណៈប្រពៃណី) ការប្រើប្រាស់អនុផលព្រៃឈើ ធ្វើការងារជាមួយក្រុមដែលមានឥទ្ធិពលទាំងឡាយ ដូចជាព្រះសង្ឃជាដើម ។ បានបង្កើតផែនការសកម្មភាពការគ្រប់គ្រងព្រៃឈើ និងសហគមន៍ ។ ក្រុមផ្សព្វផ្សាយច្បាប់ព្រៃឈើបានបកប្រែ និងធ្វើអោយងាយយល់ពីច្បាប់ព្រៃឈើដើម្បីអោយប្រជាពលរដ្ឋតាមមូលដ្ឋានទទួលបានការយល់ដឹងពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ ។ អង្គការនេះក៏ធ្វើការជាមួយបណ្តាញការងារការប្រើប្រាស់ដីធ្លីរបស់ជនជាតិដើមផងដែរ ។

***មេរៀន ឬ បទពិសោធន៍ បុគ្គលិកបច្ចេកទេស លោក អ៊ូ រតនៈ និង លោក ដួង គង់***

ការអនុវត្តគំរោងអោយមានប្រសិទ្ធភាពវាស្ថិតនៅលើការចូលរួមរបស់សហគមន៍មូលដ្ឋាន និងដៃគូការងារតាមតំបន់គោលដៅ ។ សមត្ថភាពរបស់សហគមន៍មូលដ្ឋាននៅមានកំរិតនៅឡើយ ដូចនេះជាការសំខាន់ត្រូវចេះប្រើពាក្យពេចន៍ និងបច្ចេកទេសសាមញ្ញជាមួយពួកគាត់ ។ សកម្មភាពទាំងអស់គួរតែធ្វើការវាយតំលៃដើម្បីដឹងពីការរីកចំរើន និងរកឃើញនូវចំនុចខ្លាំង និងចំនុចខ្សោយនៃការអនុវត្តគំរោងកម្មវិធី ។ កសាងទំនាក់ទំនងល្អជាមួយសហគមន៍តាមរយៈការស្នាក់នៅជាមួយពួកគាត់ ការហូបចុកជាមួយពួកគាត់ និងការពិភាក្សាជាមួយពួកគាត់ជាដើម ហើយជាពិសេសមិនត្រូវមានការរើសអើងចំពោះពួកគាត់ឡើយ ។ ផ្តល់ឱកាសអោយឧទ្យានុរក្ស និងដៃគូការងារអនុវត្តការងារដោយខ្លួនពួកគេ ហើយបុគ្គលិកបច្ចេកទេសគ្រាន់តែផ្តល់យោបល់ និងត្រួតពិនិត្យ និងជួយតាមក្រោយ ។ ការដែលមានជំនាញសំរបសំរួលល្អវាមានសារៈសំខាន់ណាស់ក្នុងការធ្វើការជាមួយសហគមន៍ ។

ADDIN EN.REFLIST

ADB (2001). Participatory Poverty Assessment: Cambodia. Asian Development Bank, Manila.

ADB (2002). Tonle Sap Environmental Management Project. Asian Development Bank, Manila.

ADB (2005). Tonle Sap Basin Strategy. Asian Development Bank. HYPERLINK http://adb.org/projects/tonle_sap/default.asp

ASEAN (2002). ASEAN Environmental Education Action Plan 2000-2005: Mid-Term Review and Partnerships for Implementation Meeting. ASEAN.

Cambodia (2003). Cambodian Millennium Development Goals Report: 2003. Ministry of Planning, Kingdom of Cambodia.

Cambodian National Mekong Committee. Tonle Sap Biosphere Reserve.

DANIDA (2004). Annual Report 2003:4 – Environmental Management in the Coastal Zone, Cambodia. Ministry of Environment & DANIDA.

ETAP (1999). Environmental Education in Cambodia: Project Termination Report of the UNDP-funded Environmental Technical Advisory Programme (ETAP) 1995-98. United Nations Development Programme.

ADDIN EN.REFLIST Fien, J. (2002). Education for Sustainability: Lessons Learnt from a Decade of Innovation from Rio to Johannasburg. Discussion Paper - Version 3. UNESCO, UNESCO: 48.

Fien, J. and A. Gough (1996). Environmental Education. Studying Society and Environment: A Handbook for Teachers. R. Gilbert. South Melbourne, Macmillan Education Australia.

Gough, S. (2002). "Right Answers or Wrong Problems? Towards a Theory of Change for Environmental Learning." The Trumpeter: Journal of Ecosophy 18(1): 15.

Halsey, A. H., H. Lauder, et al., Eds. (2001). Education: Culture, Economy and Society. New York, Oxford University Press.

Hamm, C. M. (1989). Philosophical Issues In Education: An Introduction. New York, The Falmer Press.

Hungerford, H., R. Peyton, et al. (1980). "Goals for curriculum development in environmental education." Journal of Environmental Education 11(3): 42 - 47.

Innes-Brown, M. (2002). Stability in Diversity: Educational, Economic and Political Potential in Cambodia Leading upto and following the 1998 CPP-Funcinpec Alliance. Perth, Curtin University of Technology: 10.

O'Brien, N., Ed. (1999). Environment: Concepts and Issues - A focus on Cambodia. UNDP/ETAP Reference Guide Book. Phnom Penh, UNDP/ETAP.

UNESCO-UNEP (1978). "The Tbilisi Declaration." Connect III(1).

# ឧបសម្ព័ន្ធ ១ ~

## សាវតាគំរោង ~ គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប និង ឋបនីយជីវមណ្ឌលបឹងទន្លេសាប

### គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប

គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបដំណើរការក្រោមទឹកប្រាក់ ២០លានដុល្លា ដោយមានការចូលរួមឧបត្ថម្ភថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី ភ្នាក់ងារអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ដែលបានអនុម័តនៅឆ្នាំ២០០២ ក្នុងនោះ គំរោងទាំងមូលមានបីផ្នែក ការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ ការរៀបចំសហគមន៍ និងការអភិរក្សជីវៈចំរុះនៅឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ ភាគច្រើននៃគំរោងបឹងទន្លេសាបត្រូវបានផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ីដែលមាន១០,៩លានដុល្លា ជាប្រាក់កំចីជាមួយការផ្តល់អោយដោយរដ្ឋាភិបាលកម្ពុជាចំនួន ៣,៥លានដុល្លា ជារូបិយវត្ថុក្នុងស្រុក (ប្រមាណ១,៦កោដ្ឋរៀល) ជំនួយបរិស្ថានពិភពលោករបស់អង្គការសហប្រជាជាតិបានផ្តល់បន្ថែមនូវចំនួនទឹកប្រាក់ ៣,៩លានដុល្លា ជាជំនួយឥតសំណង ហើយកម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិបានផ្តល់ជាប្រាក់ជំនួយឥតសំណងចំនួន ៦២៣.០០០ដុល្លា ។ ដើម្បីធ្វើឲ្យប្រសើរឡើងផ្នែកច្បាប់ និងការគ្រប់គ្រងជលផលទឹកសាប ធនាគារអភិវឌ្ឍអាស៊ីបានផ្តល់បន្ថែមជាមួយទឹកប្រាក់ ៥៤០,០០០ដុល្លាក្នុងទំរង់ជាជំនួយឥតសំណងលើ ផ្នែកបច្ចេកទេស ។

ដូចគ្នានៅនឹងឋបនីយជីវមណ្ឌលបឹងទន្លេសាប គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបក៏ឋិតនៅក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គ ដែលមានតំណាងមកពី ១០ក្រសួងផ្សេងៗ គ្នា ។ ក្នុងនោះមាន ឯកឧត្តម **កុល វឌ្ឍនា** ដែលជាអនុរដ្ឋលេខាធិការនៃគណៈកម្មាធិការជាតិទន្លេមេគង្គនេះ គឺជារដ្ឋលេខាធិការនៃគំរោងនេះ ។ អនុរដ្ឋលេខាបីទៀត គឺបណ្ឌិត **នៅ បោនន័រ** អនុប្រធាននាយកដ្ឋានការពារ និងអភិរក្សធនធានធម្មជាតិនៃក្រសួងបរិស្ថាន លោក**សម នៅ** អនុប្រធាននាយកដ្ឋានជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោក **អាំង នរិន្ទ** ប្រធាននាយកដ្ឋានអភិរក្ស និងគ្រប់គ្រងធនធានទឹក នៃក្រសួងធនធានទឹក និងឧតុនិយម ។

## ជីវមណ្ឌលបឹងទន្លេសាប

ឋិតនៅក្រោមកម្មវិធីដែលបានចាប់ផ្តើមនៅឆ្នាំ១៩៧០ អង្គការសហប្រជាជាតិសំរាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធ៌ម (UNESCO) បានកំនត់បឹងទន្លេសាប និងទំនាបលិចទឹកនៅជុំវិញជា"ជីវមណ្ឌលបឹងទន្លេសាប" នៅឆ្នាំ១៩៩៧ ។តំបន់នេះមានទំហំប្រមាណ ១,៥លានហិចតា គ្របដណ្តប់លើផ្ទៃបឹង និងតាមដងផ្លូវជាតិលេខ៥ និងលេខ៦ ។ នៅឆ្នាំ២០០៥ ជីវមណ្ឌលនេះជាជីវមណ្ឌលមួយក្នុងចំណោមជីវមណ្ឌលទាំង៤៨២ ក្នុងប្រទេសចំនួន១០២ ប្រទេស ។

ជីវមណ្ឌលបឹងទន្លេសាបឋិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការជាតិទន្លេមេគង្គដែលមានអនុរដ្ឋលេខាធិការនៃគណៈកម្មាធិការនេះជាប្រធាន និងអនុប្រធានបីនាក់ទៀតមកពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ។ ក្រសួងទាំងបីក៏បានចូលរួមគ្រប់គ្រងនៅក្នុងគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបដោយមានការចូលរួមឧត្ថម្ភថវិកាដោយ ធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលកម្ពុជា និងភ្នាក់ងារអង្គការសហប្រជាជាតិ ។

***ជីវមណ្ឌលនេះរាប់បញ្ចូលទាំងផ្ទៃបឹងព្រៃលិចទឹក និងវាលស្មៅលិចទឹកពិសេសនៅប៉ែកខាងកើតប្រាំង ។*** នៅរដូវវស្សាផ្ទៃបឹងកើនឡើងដល់ ១,៦លានហិចតា ដែលទំហំនេះធំកើនឡើងប្រមាណ ៦ដងនៃទំហំនៅរដូវប្រាំងដែលមានត្រឹមតែ២៥០.០០០ហិកតា ។ បរិមាណទឹកស្ទើរតែ២/៣ នៃបឹងនេះបានមកពីទន្លេមេគង្គ និង ១/៣ទៀតបានពីអាងស្តុកផ្សេងៗក្នុងនោះមានស្ទឹងសែន និងស្ទឹងពោធិ៍សាត់ជាដើម។ ប្រហែលជា ១០% នៃតំបន់គ្របដណ្តប់ដោយដើមឈើខ្ពស់ៗពិសេសនៅតាមស្ទឹង និងតំបន់ដីសើម ។

***ព្រៃលិចទឹករបស់បឹងទន្លេសាបសំបូរដោយប្រភេទព្រៃគុម្ពោធ និង ព្រៃរនាមជាងគេនៅក្នុងតំបន់អាស៊ីទាំងមូល ។*** នៅឆ្នាំ ១៩៩៧ ត្រូវបានប៉ាន់ប្រមាណថាអាចលាតសន្ធឹងលើផ្ទៃ ៣៥០.០០០ហិកតា ដែលប្រហែលជា១/៣នៃតំបន់ទាំងមូល ។ ព្រៃលិចទឹកមានសារៈសំខាន់យ៉ាងខ្លាំងសំរាប់ត្រី ពពួកសត្វស្លាបទឹក និងពពួកល្មូន ។

***ជីវមណ្ឌលមានតំបន់ស្នូលពគឺ ព្រែកទាល់ដែលឋិតក្នុងខេត្តបាត់ដំបង តំបន់ស្នូលបឹងឆ្មារ និងស្ទឹងសែនឋិតនៅខេត្តកំពង់ធំ ។*** ពពួកសត្វស្លាបទឹកប្រមាណជា១០០ប្រភេទត្រូវបានគេរកឃើញនៅក្នុងតំបន់ស្នូលទាំងបី ដែលមានទំហំសរុបប្រមាណជា៤២០០ហិកតា ។ មានប្រភេទត្រីប្រមាណជាង ៤០០ប្រភេទក៏ត្រូវបានគេឃើញមាននៅក្នុងតំបន់នេះដែរហើយក៏រួមបញ្ចូលទាំងក្រពើ អណ្តើក ស្វា ភេ និង ពស់ប្រលិត។ តំបន់ស្នូលទាំងនេះមានទំហំ ២១.៣៤២ហិចតា សំរាប់តំបន់ស្នូលព្រែកទាល់ ១៤.៥៦០ហិចតា សំរាប់តំបន់ស្នូល បឹងឆ្មារដែលត្រូវបានគេរាប់បញ្ចូលផងដែរថាជាតំបន់ដីសើមអន្តរជាតិដោយអនុសញ្ញារ៉ាមសារដែលមានសារៈសំខាន់ទាំងសំរាប់សត្វស្លាបទឹកធំៗធ្វើការពងកូននិងកន្លែងសំរាប់រកចំណី ដែលសត្វស្លាបទាំងនេះមាន មួយចំនួនជាប្រភេទដែលកំពុងរងការគំរាមកំហែងលើពិភពលោក ។ សំរាប់តំបន់ស្នូលស្ទឹងសែនមានទំហំ ៦.៣៥៥ហិកតា និងសំបូរដោយពពួកប្រភេទព្រៃលិចទឹកកំរ ។ ក្រសួងបរិស្ថានបានធ្វើការប៉ាន់ប្រមាណថាមានប្រជាជនតិចជាង ២០.០០០នាក់រស់នៅក្នុងតំបន់ស្នូលទាំងនេះដោយក្នុងនោះមានប្រមាណ ១០.០០០នាក់នៅក្នុងតំបន់ព្រែកទាល់ ២.០០០នាក់ នៅបឹងឆ្មារ និងប្រហែលជា៧.០០០នាក់ នៅក្នុងតំបន់ស្នូលស្ទឹងសែន ។

***តំបន់ទ្រនាប់គ្របដណ្តប់លើផ្ទៃបឹង និងលាតសន្ធឹងទៅដល់ព្រំប្រទល់ព្រៃលិចទឹកដែលនៅខាងក្រៅ ។*** វាលាតសន្ធឹងធំនៅក្នុងខេត្តបាត់ដំបង និងគ្របដណ្តប់នៅក្នុងខេត្តកំពង់ធំ និងពោធិ៍សាត់និងភាគខ្លះនៃខេត្តកំពង់ឆ្នាំង ។ ដោយមិនរាប់បញ្ចូលតំបន់ស្នូលទាំងបីតំបន់ទ្រនាប់នេះមានទំហំ ៥៤១.៤៨២ហិចតា ហើយក៏ត្រូវបានកំនត់ដោយព្រះរាជក្រិត្យថាជាតំបន់ប្រើប្រាស់ច្រើនយ៉ាង (ផ្នែកមួយនៃតំបន់ការពារ) នៅក្នុងឆ្នាំ១៩៩៣ ។នៅក្នុងតំបន់នេះមានភូមិបណ្តែតទឹកប្រមាណ៦០ភូមិដែលមានប្រជាជនប្រហែល ៧០.០០០នាក់ ។

***អន្តរតំបន់ពទ្ធ័ជុំវិញដោយផ្លូវជាតិលេខ ៥ និងលេខ ៦ ក្នុងខេត្តបាត់ដំបង ពោធិ៍សាត់ និងសៀមរាប និងឋិតនៅជុំវិញតំបន់ទ្រនាប់ ។*** វាលាតសន្ធឹងរហូតដល់ផ្លូវធំពីរនៅក្នុងខេត្តកំពង់ឆ្នាំងនិងកំពង់ធំដែលរាប់ពីភាគខាងត្បូងខេត្តកំពង់ឆ្នាំងរហូតដល់ស៊ីសុផុននៅភាគខាងជើង ។ តំបន់នេះលាតសន្ធឹងលើផ្ទៃប្រមាណ ៨៩៩.៦០០ហិកតា ដោយរាប់បញ្ចូលទាំងចំណែកក្រុងមួយចំនួនក្នុងខេត្តពោធិ៍សាត់ និងខេត្តសៀមរាប ប៉ុន្តែមិនឋិតនៅក្នុងខេត្តកំពង់ធំឡើយ ។ ចំនួនប្រជាជនមានប្រមាណជាង ១,៦លាននាក់រស់នៅក្នុងអន្តរតំបន់នេះ ។

***ការនេសាទគឺជាសកម្មភាពចំបងប៉ុន្តែវាលទំនាបលិចទឹកក៏ត្រូវបានគេប្រើសំរាប់ធ្វើស្រែ និងដាំដុះពពួកបន្លែផ្សេងទៀតផងដែរ ។*** គោលដៅចំបងរបស់ជីវមណ្ឌលគឺដើម្បីសិក្សា និងជំរុញលើចំនេះដឹងមូលដ្ឋានរបស់ប្រជាជនលើអេកូឡូស៊ី ។

***កម្ពុជាគឺជាផ្នែកមួយនៃបណ្តាញជីវមណ្ឌលតំបន់អាស៊ីអាគ្នេយ៍ ដែលចាប់ដំណើរការតាំងពីឆ្នាំ ១៩៩៨ ។*** សមាជិកផ្សេងទៀតមានប្រទេសចិន ឥណ្ឌូនេស៊ី ជប៉ុន ឡាវ ម៉ាឡេស៊ី ភូមា ហ្វីលីពីន ថៃ និងវៀតណាម ។ ការិយាល័យ UNESCO នៅទីក្រុងហ្សាកាតាបានបង្កើតជាគេហទំព័រសំរាប់បណ្តាញការងារដែលត្រូវបានគេស្គាល់ថាSeaBRnet ។ កម្ពុជា និងអង្គការយូនេស្កូបានរៀបចំការប្រជុំលើកទី៣សំរាបបណ្តាញក្នុងតំបន់នៅក្នុងខេត្តសៀមរាប នៅឆ្នាំ ២០០៣ ដោយមានជំនួយពីប្រទេសជប៉ុនការរៀបចំប្រជុំលើទី៤ត្រូវបានរៀបចំឡើងនៅប្រទេសថៃក្នុងឆ្នាំ២០០៥ ។

**ការគ្រប់គ្រងទូទៅសំរាប់ថបនីយជីវមណ្ឌលបឹងទន្លេសាប និង គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបឋិតនៅក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គ ។** គណៈកម្មាធិការនេះធ្វើការផ្តល់យោបល់ដល់ទីប្រឹក្សាគណៈរដ្ឋមន្ត្រីលើការអភិវឌ្ឍការគ្រប់គ្រង និងការអភិរក្សធនធានទឹក និងធនធានផ្សេងទៀតដែលទាក់ទងនឹងទន្លេមេគង្គនៅក្នុងកិច្ចសហប្រតិបត្តិការជាមួយអជ្ញាធរខេត្ត-ក្រុងក៏ដូចជាភ្នាក់ងាររដ្ឋាភិបាល ។ គណៈកម្មាធិការជាតិទន្លេមេគង្គតំណាងអោយ១០ក្រសួងដែលក្រសួងទាំងនោះមានដូចជា ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងការបរទេស និងសហប្រតិបត្តការណ៍អន្តរជាតិ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងផែនការណ៍ ក្រសួងដែនដីនគររូបនីយកម្ម និងរៀបចំដែនដី ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍជនបទ និងក្រសួងទេសចរណ៍ ។

**ពេលដែលសន្និសិទ UNESCO អំពាវនាវឲ្យមានកម្មវិធីសំរាប់បង្កើតតំបន់ដីគោក និងតំបន់ឆ្នេរសំរាប់តំណាងឲ្យប្រព័ន្ធអេកូឡូស៊ីសំខាន់ៗលើពិភពលោក ។** UNESCO ចាប់ផ្តើមកំនត់ទ្រង់ទ្រាយនៅឆ្នាំ១៩៧០ ពេលដែលភ្នាក់ងារមានទីតាំងនៅទីក្រុងប៉ារីសបានបង្កើត "កម្មវិធីមនុស្ស និងជីវមណ្ឌល" បង្កើតបានជាតំបន់ការពារដែលត្រូវបានស្គាល់ថាជាថបនីយជីវមណ្ឌល ។ នៅឆ្នាំ១៩៩៥បានធ្វើសន្និសិទអន្តរជាតិមួយនៅទីក្រុងស៊ីវិលបានយល់ព្រមលើយុទ្ធសាស្ត្រសំរាប់ថបនីយជីវមណ្ឌល និងគំរោងផែនការបណ្តាញពិភពលោកនៃថបនីយជីវមណ្ឌលនៅឆ្នាំ១៩៩៦ ។

**ដោយត្រូវបានកំនត់ដោយរដ្ឋាភិបាល ថបនីយត្រូវបានទទួលស្គាល់ជាអន្តរជាតិ ប៉ុន្តែត្រូវឋិតក្រោមការត្រួតពិនិត្យរបស់បណ្តាប្រទេសដែលជាម្ចាស់ថបនីយនោះ ។** UNESCO ធ្វើការពណ៌នាពីថបនីយថាជា "ទីពិសោធន៍សំរាប់ការរស់នៅ" សំរាប់សាកល្បងលើសមាហរណកម្មការគ្រប់គ្រងដី ទឹក និងជីវចំរុះ ។ ថបនីយនីមួយៗត្រូវបានរំពឹងថានឹងជួយថែរក្សាទេសភាព ស្ថានប្រពន្ធ័ នានាភាពនៃប្រភេទ និងនានាភាពនៃសែនស្របពេលជាមួយនឹងការផ្គត់ផ្គង់សំរាប់ការអភិវឌ្ឍរបស់មនុស្ស និងសេដ្ឋកិច្ច ។ តួនាទីទីពាគឺដើម្បីជួយដល់ការស្រាវជ្រាវ ការត្រួតពិនិត្យ ការអប់រំ និងការផ្លាស់ប្តូរព័ត៌មាន ។ ថបនីយមិនបានគ្របដណ្តប់ដោយ អនុសញ្ញាអន្តរជាតិទេ ប៉ុន្តែត្រូវតែមានការជួបគ្នាដើម្បីធ្វើលក្ខខណ្ឌនិកៈអនុញ្ញាតអោយពួកគេបំពេញតួនាទីទាំងបីខាងលេនេះ ។

**ថបនីយនីមួយៗមានតំបន់ស្នូលមួយ តំបន់ទ្រនាប់ និងអន្តរតំបន់ ។** តំបន់ស្នូលនៃថបនីយជីវមណ្ឌលគួរត្រូវបង្កើតដោយស្របច្បាប់ និងផ្តល់នូវការពារយូរអង្វែងលើទេសភាព ប្រពន្ធ័អេកូឡូស៊ី និងប្រភេទផ្សេងៗដែលតំបន់នោះមាន ។ ជាមធ្យតាតំបន់ស្នូលមិនអនុញ្ញាតឲ្យមានសកម្មភាពមនុស្សឡើយលើកលែងតែការស្រាវជ្រាវ ការត្រួតពិនិត្យ និងការប្រើប្រាស់ជាលក្ខណៈប្រពៃណីដែលធ្វើឡើងដោយប្រជាជនក្នុងតំបន់ប៉ុណ្ណោះ ។ តំបន់ទ្រនាប់ដែលនៅជុំវិញតំបន់ស្នូលអាចមាន ការស្រាវជ្រាវដើម្បីគ្រប់គ្រងលើការដាំដុះតាមបែបធម្មជាតិ ដីដំណាំ ព្រៃឈើ និងជលផលដើម្បីបង្កើនទិន្នផលស្របពេលដែលយើងធ្វើការអភិរក្សជីវចំរុះ និងធម្មជាតិឲ្យបានច្រើនតាមដែលអាចទៅរួច ។ តំបន់ទាំងនេះអាចត្រូវបានប្រើផងដែរសំរាប់ការអប់រំការបណ្តុះបណ្តាលទេសចរណ៍ និងការបង្កើតថ្មីៗ អន្តរតំបន់លាតសន្ធឹងបន្ទាប់ពីតំបន់ទ្រនាប់ដែលតំបន់នេះអាចមានលំនៅដ្ឋានមនុស្ស ការធ្វើកសិកម្ម និងសកម្មភាពផ្សេងទៀត ។ តំបន់ ស្នូលភាគច្រើនជាដីសាធារណៈប៉ុន្តែក៏អាចជាកម្មសិទ្ធឯកជន រឺគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាលផងដែរ ។ មានករណីជាច្រើនដែលដីនៅក្នុងតំបន់ទ្រនាប់ និងអន្តរតំបន់ជាកម្មសិទ្ធិរបស់សហគមន៍ រឺកម្មសិទ្ធិឯកជន ។

**ថបនីយជីវមណ្ឌលមួយចំនួនគឺជាឧទ្យានជាតិ កន្លែងរក្សាលក្ខណៈធម្មជាតិ និងជាកន្លែងដែលមានការទទួលស្គាល់ជាអន្តរជាតិដោយអនុសញ្ញាបេតិកភ័ណ្ឌពិភពលោក និងអនុសញ្ញារ៉ាមសារ ។** សហគមន៍មូលដ្ឋាន និងការពាក់ពន្ធ័នៅក្នុងកសិកម្ម រុក្ខាកម្ម និងជលផលត្រូវបានមើលឃើញដោយអង្គការUNESCO ថាជាផលប្រយោជន៍ចំបងសំរាប់ថបនីយជីវមណ្ឌលដោយស្របជាមួយអ្នកវិទ្យាសាស្ត្រ រដ្ឋាភិបាល និងពិភពលោកទាំងមូល ។

**ដើម្បីក្លាយជាថបនីយជីវមណ្ឌលបាន តំបន់នោះត្រូវជា "តំណាងអោយជីវៈភូមិសាស្ត្រចំបងក្នុងតំបន់" ដោយរួមជាមួយតំបន់ទេសភាព ស្ថានប្រពន្ធ័ រឺប្រភេទសត្វ និងរុក្ខជាតិ រឺនានាភាពដែលចាំបាច់សំរាប់ធ្វើការអភិរក្ស ។** តំបន់នោះត្រូវមានទំហំគ្រប់គ្រាន់សំរាប់កំនត់ជាផ្លូវការថាជាតំបន់ស្នូលដើម្បីធ្វើការការពារក្នុងរយៈពេលវែង ការកំនត់ច្បាស់លាស់ ទៅលើតំបន់ទ្រនាប់ និងអន្តរតំបន់ ។ អាជ្ញាធរសាធារណៈជន សហគមន៍ក្នុងតំបន់ និងផ្នែកឯកជនគួរមានការចូលរួមក្នុងការធ្វើផែនការ និងគ្រប់គ្រងថបនីយជីវមណ្ឌលជាមួយគ្នានេះក្នុងករណីដែលតំបន់ធម្មជាតិនេះឋិតនៅជាប់នឹងព្រំប្រទល់ប្រទេសពីរ រឺច្រើនផ្សេងគ្នា អង្គការ UNESCO ជំរុញអោយដែលមានថបនីយដែលមានព្រំប្រទល់ជាប់គ្នានេះទទួលនូវការគ្រប់គ្រងរួមគ្នា ។

**ទីប្រឹក្សាគណៈកម្មាធិការ UNESCO ពិនិត្យលើគ្រប់ការកំណត់លើគ្រប់ថបនីយ និងធ្វើអនុសាសន៍ទៅកាន់ក្រុមប្រឹក្សាអន្តរជាតិដែលតែងតែជួបប្រជុំរាល់២ឆ្នាំម្តង ។** ក្រុមប្រឹក្សាដែលបានបង្កើតឡើងនៅទីក្រុងប៉ារីសក្នុង ឆ្នាំ២០០០ នេះមានសមាជិក៣៤នាក់ហើយធ្វើការចូលរួមបោះឆ្នោតជ្រើសរើសប្រធានម្នាក់ និងអនុប្រធាន៥នាក់ ។ នៅឆ្នាំ២០០៤-២០០៥ ប្រទេសម៉ិចស៊ិចកូ រួមជាមួយ ប្រទេសអូស្ត្រាលី ហ្គាណា កូរេខាងត្បូង រុស្ស៊ី និងប្រទេសទុនីសាជាអនុប្រធាន ។ សមាជិក UNESCO ដែលមិនមានតំណាងនៅក្នុងក្រុមប្រឹក្សានេះអាចបញ្ជូនអ្នកអង្កេតការណ៍ដើម្បីចូលរួមប្រជុំបាន ជាមួយគ្នានេះភ្នាក់ងារអង្គការសហប្រជាជាតិ ដូចជាកម្មវិធីបរិស្ថានរបស់អង្គ

ការសហប្រជាជាតិ អង្គការស្បៀងអាហារ និងកសិកម្ម អង្គការ ផែ្ទសមុទ្រពិភពលោក និងអង្គការសុខភាពពិភពលោកក៏អាចចូលរួមផងដែរ ។ ក្រុមប្រឹក្សាអន្តរជាតិនៃសហព័ន្ធវិទ្យាសាស្រ្តក្រុមប្រឹក្សាវិទ្យាសាស្រ្តសង្គមអន្តរជាតិ និងសហព័ន្ធអភិរក្សពិភពលោកអាចដើរតួនាទីជាអ្នកផ្តល់មតិដល់ក្រុមប្រឹក្សានេះបាន ។

# ឧបសម្ព័ន្ធ ២-
# ទស្សនៈទាននៃការអប់រំបរិស្ថាន

## និយមន័យនៃការអប់រំបរិស្ថាន

វាមានលក្ខណៈប្រសើរជាងក្នុងការគិតពីការអប់រំថាជាឧត្តមគតិដែលគ្មាននរណាម្នាក់អាចទទួលបានគ្រប់ជ្រុងជ្រោយ ព្រោះគ្មាននរណាម្នាក់អាចដឹងគ្រប់រឿងនោះឡើយ ។ ចុងបញ្ចប់ផ្សេងទៀតនៃភាពមិនអាចបែងចែកវាបញ្ជាក់ច្បាស់ថាមានមនុស្សមួយចំនួនតូចមិនយល់ទាល់តែសោះពីនិយមន័យនេះ ដូចនេះស្ទើរតែគ្រប់គ្នាមានការយល់ដឹងខ្លះៗដោយសារយើងធ្លាប់បានរៀនសូត្រ(Hamm 1989) ។

### *សេចក្តីប្រកាស* Tbilisi

សេចក្តីប្រកាសនេះនៅតែត្រូវបានចាត់ទុកថាជាទស្សនៈទានគោលសំរាប់ការអប់រំបរិស្ថាន និង និយមន័យ ទិសដៅ និងផ្នែកផ្សេងៗសំរាប់ការអប់រំបរិស្ថានការអប់រំបរិស្ថានជាដំណើរឆ្ពោះទៅកាន់ស្ថានភាពមួយដែលប្រជាជនទូទាំងពិភពលោកមានការយល់ដឹង និងការព្រួយបារម្ភពីបរិស្ថានទាំងមូលរួមជាមួយបញ្ហាដែលពាក់ព័ន្ធផ្សេងៗទៀត និងឲ្យប្រជាជនមានចំនេះដឹង ឥរិយាបទ ការដឹងពីហេតុផល ការតាំងចិត្តនិងជំនាញដើម្បីអនុវត្តដោយឡែកៗលើផ្នែកទាំងនេះ និងការបញ្ចូលគ្នាដើម្បី ដោះស្រាយពីបញ្ហាបច្ចុប្បន្ន និងការពារនូវបញ្ហានាពេលខាងមុខ (UNESCO - UNEP 1978) ។

បន្ថែមលើនេះ អនុសញ្ញា Tbilisi បានផ្តល់នូវផ្នែក៥នៃគោលបំណងនៃការអប់រំបរិស្ថានដូចជា

- ***ការយល់ដឹង(តាមសម្បជញ្ញៈ)*** : ដើម្បីជួយដល់បុគ្គលក៏ដូចជាក្រុមដែលនៅក្នុងសង្គមទទួលបានការយល់ដឹង និងមានការយកចិត្តទុកដាក់ពីបរិស្ថានទាំងមូល និងបញ្ហាពាក់ព័ន្ធនឹងបរិស្ថាន ។
- ***ចំណេះដឹង*** : ដើម្បីជួយដល់បុគ្គលក៏ដូចជាក្រុមដែលនៅក្នុងសង្គមឲ្យទទួលបាននូវបទពិសោធន៍ផ្សេងៗ និងទទួលបានការយល់ដឹងពីបរិស្ថាន និងបញ្ហារបស់វា ។
- ***ឥរិយាបទ*** : ដើម្បីជួយដល់បុគ្គលក៏ដូចជាក្រុមដែលនៅក្នុងសង្គមឲ្យទទួលបានទាំងគុណតំលៃ និងអារម្មណ៍លើការព្រួយបារម្ភពីបរិស្ថាន និងការលើកហេតុផលដើម្បីឲ្យមានការចូលរួមយ៉ាងសកម្មនៅក្នុងការកែលំអរ និងការពារបរិស្ថាន ។
- ***បំណិនប្រសប់*** : ដើម្បីជួយដល់បុគ្គលក៏ដូចជាក្រុមដែលនៅក្នុងសង្គមទទួលបានជំនាញសំរាប់ធ្វើការកំនត់ និងដោះស្រាយពីបញ្ហាបរិស្ថាន ។
- ***ការចូលរួម*** : ដើម្បីផ្តល់អោយបុគ្គល និងក្រុមដែលនៅក្នុងសង្គមនូវឳកាសដើម្បីអោយមានការចូលរួមយ៉ាងសកម្មនៅគ្រប់ជាន់ថ្នាក់ក្នុងការងារឆ្ពោះទៅកាន់ដំណោះស្រាយលើបញ្ហាបរិស្ថាន (UNESCO-UNEP 1978 p3) ។

ទោះបីមានការបំភ្លឺនៅក្នុងគំរោងផែនការដែលផ្តល់ដោយសេចក្តីប្រកាស Tbilisi ក៏កង្វះខាតនៃកិច្ចព្រមព្រៀងលើនិយមន័យនៃការអប់រំបរិស្ថានត្រូវបានគេព្រួយបារម្ភសំរាប់ពេលខ្លះ ។ ជាការពិតវិធីនៃការបែងចែកសកម្មភាពអប់រំបរិស្ថាន គឺឋិតក្នុងទំរង់នៃការអប់រំ "អំពី នៅក្នុង និង ដើម្បី" រឺ "អំពី មកពី និងដើម្បី" បរិស្ថាន និងបង្ហាញនូវទំរង់ទាំងនេះ ដូចខាងក្រោម :

- ការអប់រំ **អំពី** បរិស្ថានផ្តល់អោយអ្នកសិក្សានូវចំនេះអនុវត្តលើបរិស្ថាន និងផលប៉ះពាល់ដែលបណ្តាលពីមនុស្សទៅលើវា ។
- ការអប់រំ **មកពី (នៅក្នុង)** បរិស្ថានសំដៅលើការប្រើប្រាស់បរិស្ថានធម្មជាតិជាឧបករណ៍បច្ចេកទេស ដែលជាកន្លែងពិសោធន៍ធម្មជាតិដើម្បីផ្តល់នូវចំនេះដឹង និងឯកទេសសំរាប់ការពារបរិស្ថាន ។ វាជួយអភិវឌ្ឍន៍លើគុណតំលៃ និងបង្កើតអោយមានឥរិយាបទជាវិជ្ជមាន ។
- ការអប់រំ **ដើម្បី** បរិស្ថានបង្កើតអោយមានមនៈសិកា និងការព្រួយបារម្ភខ្លាំងពីបរិស្ថានមានជីវិត និងជំរុញឲ្យមានការទទួលខុសត្រូវដើម្បីធ្វើការការពារ និងថែរក្សាវា ។ គោលបំណងនៅក្នុងផ្នែកនេះ គឺដើម្បីអភិវឌ្ឍឥរិយាបទ និងកំរិតនៃការយល់ដឹងដែលផ្តល់ឥទ្ធិពលអោយប្រជាជនធ្វើការអនុវត្តនូវសកម្មភាពរួបរួមដែលនឹងមានផលប្រយោជន៍ជាវិជ្ជមានដល់ផែនដី ។

## ការអប់រំបរិស្ថាន និងការកាត់បន្ថយភាពក្រីក្រ

ភាពក្រីក្រ និងគុណភាពនៃជីវិតជាបញ្ហាពីរសំខាន់ដែលទាក់ទងនឹងការអប់រំបរិស្ថាន ។ គុណភាពជីវិតមានន័យថាមនុស្សមានតំរូវការផ្សេងៗគ្នា និងស្ថិតនៅបរិបទផ្សេងៗគ្នា ហើយការរស់នៅរបស់មនុស្សទាំងអស់មានតំរូវការផ្សេងៗគ្នា ដែលពួកគេស្វែងរកដើម្បីបំពេញតំរូវការទាំងនោះ ។ តំរូវការជាមូលដ្ឋានអាចរួមបញ្ចូលជាចាំបាច់ទាំងទឹកដែលមានសុវត្ថិភាព និងអាហាររូបត្ថម្ភដែលសារធាតុចិញ្ចឹមគ្រប់គ្រាន់ សេវាកម្មសុខភាព និងអនាម័យជាមូលដ្ឋានសន្តិសុខ និងសុវត្ថិភាពបរិស្ថាន ។ ភាគច្រើននៃតំរូវការទាំងនេះអាចទទួលបានដោយសារប្រាក់ចំណូល ចំពោះតំរូវការដទៃទៀតអាចទទួលបានដោយសារយន្តការគាំទ្រតាមរយៈរដ្ឋាភិបាលផ្នែកឯកជនឬសាធារណៈ ។ ជាគោលការណ៍បញ្ហានៃតំរូវការត្រូវផ្សារភ្ជាប់នឹងការអប់រំបរិស្ថាន និងការលុបបំបាត់ភាពក្រីក្រ ។ ចំពោះប្រជាពលរដ្ឋក្រីក្រអាចមានដំណោះនឹងការរកចំណូល (ទាំងរូបិយវត្ថុ ឬនៅ

ក្នុងទំរង់នេះ) ជាផ្លូវមួយដើម្បីទទួលបានតំរូវការពិតរបស់ពួកគេ ។ បើសិនជាបញ្ហានេះ តំរូវឲ្យមានការបំផ្លិចបំផ្លាញបរិស្ថាននោះប្រជាពលរដ្ឋនឹងមិនគិតពីផលប្រយោជន៍យូរអង្វែងរបស់បរិស្ថានឡើយ ព្រោះពួកគេអត់បាយហូបថ្ងៃនេះ ។

ការប៉ាន់ស្មានទុកជាមុនថាការយល់ដឹងពីបរិស្ថាននឹងនាំឲ្យមានការផ្លាស់ប្តូរហើយប្រជាពលរដ្ឋនឹងធ្វើការជ្រើសរើសការរស់នៅក្នុងស្ថានភាពដែលប្រកបដោយចេរភាពដោយប្រើចំណេះដឹងរបស់ពួកគេ ។ កត្តាទាំងពីរនេះគឺជារឿងដែលនៅមិនទាន់មានភាពប្រាកដនៅឡើយ ។ ប្រជាពលរដ្ឋជាច្រើនបានយល់ដឹងពីហេតុផលផ្សេងៗដែលសហគមន៍ និងរដ្ឋាភិបាលជ្រើសរើសយក ការបំផ្លិចផ្លាញព្រៃឈើទោះបីជាពួកដឹងថានឹងមានផលវិបាកកើតឡើងក៏ដោយ ។ នេះហើយជាមូលហេតុដែលតំរូវឲ្យធ្វើការអប់រំបរិស្ថានដល់ប្រជាពលរដ្ឋអំពីបរិស្ថាន និងគុណតំលៃបរិស្ថាន ។ វាក៏តំរូវឲ្យមានការបង្ហាញផងដែរចំពោះការកែលំអធនធានបរិស្ថានដើម្បី សហគមន៍អាចបង្កើតនូវចំណូលទាំងពេលបច្ចុប្បន្ន និងអនាគតដើម្បីដោះស្រាយតំរូវការជានិរន្តរ៍ ។ វាតំរូវឲ្យមានការរៀបចំការអប់រំបរិស្ថានដែលអាចមានភាពប្រែប្រួលមួយដោយចាប់ផ្តើមពីរចនាសម្ព័ន្ធធនធាន និងគោលបំណងដែលមានស្រាប់ ។ ជំរើសដែលល្អមួយគឺការអប់រំបរិស្ថានត្រូវចាប់ផ្តើមចេញពីសហគមន៍ ។ ចំណេះដឹងបុរាណអាចនៅខ្វះសមត្ថភាពក្នុងការដោះស្រាយបញ្ហាបរិស្ថានថ្មីៗនេះ ប៉ុន្តែវាជាចំនុចចាប់ផ្តើមសំរាប់ការបង្កើតនូវចំណេះដឹងថ្មី ដែលចំណេះដឹងថ្មីនេះគួរតែឆ្លងកាត់ការអនុវត្តជាក់ស្តែង ឬការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ ។

# ឧបសម្ព័ន្ធ ៣-

## អង្គការពាក់ព័ន្ធ

ផ្នែកខាងក្រោមនេះនឹងលើកឡើងពីអង្គការខ្លះដែលធ្វើការនៅកម្ពុជាដែលចាត់ទុកថាមានការពាក់ព័ន្ធនឹងការអប់រំបរិស្ថាន ហើយបញ្ជីនេះបានចងក្រងតាមរយៈការជួបប្រជុំ និងតាមរយៈការប្រមូលទិន្នន័យផ្សេងទៀត ។ ទិន្នន័យមួយចំនួនបានប្រមូលពីគណៈកម្មាធិការប្រតិបត្តិកម្ពុជា (CCC) ក្នុងនោះព័ត៌មានខ្លះនៅជាព័ត៌មានចាស់ និងដូចជាមិនទាន់សុក្រិតនៅឡើយហើយក៏មានអង្គការពាក់ព័ន្ធខ្លះទៀតដែលយើងមិនបានលើកឡើង ប៉ុន្តែសង្ឃឹមថា ការចងក្រងព័ត៌មាននេះអាចចាត់ទុកថាជាកាតាលីករសំរាប់ ការប្រមូលព័ត៌មាននៅពេលខាងមុខលើស្ថានភាពនៃការអប់រំបរិស្ថាននៅកម្ពុជា ។

### អង្គការ ACAPE

ACAPE បានអនុវត្តគំរោងទឹកស្អាតនៅកម្ពុជាចាប់ពីឆ្នាំ១៩៨៨ និងបង្កើតក្រុមបណ្តុះបណ្តាលជំនាញនៅឆ្នាំ១៩៩១ ។ វាត្រូវបានបង្កើតក្នុងរូបភាពជាអង្គការក្រៅរដ្ឋាភិបាលនៅឆ្នាំ១៩៩៥ និងមានបទពិសោធន៍ទៅលើផ្នែកអនាម័យ និងការផ្គត់ផ្គង់ទឹកនៅសហគមន៍ គំរោង ACAPE ដែលពាក់ព័ន្ធនឹងបរិស្ថាន គឺ ទឹក និងអនាម័យ ។ គោលបំនងគំរោងនេះគឺ „ដើម្បីផ្គត់ផ្គង់ទឹកស្អាតសំរាប់បរិភោគទៅដល់ប្រជាជនជនបទដោយធ្វើការគិតផងដែរពីទីតាំងស្ថានីយផ្គត់ផ្គង់ទឹក ការបំពាក់សំភារៈ ការបណ្តុះបណ្តាលលើការប្រើប្រាស់ និងថែទាំរួមទាំងអនាម័យក៏ដូចជាដើម្បីផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជន សព្វថ្ងៃពួកគេផ្តោតលើការងារនៅក្នុងខេត្តបន្ទាយមានជ័យ កំពង់ធំ កំពង់ស្ពឺ ពោធិ៍សាត់ កំពត និងខេត្តកណ្តាល ។

***លោក រស់ សារឿន : នាយកអង្គការ***
ទូរស័ព្ទ: ០២៣ ៨០២ ១៣១
អ៊ីម៉ែល: acape@forum.org.kh
#២៨២, ផ្លូវ នរប្រើត សង្កាត់ទឹកថ្លា ខណ្ឌមិត្តភាព ក្រុងភ្នំពេញ

### អង្គការចូលរួមអភិរក្សអង្គរ - APDO

APDO ត្រូវបានបង្កើតឡើងនៅខែមេសា ឆ្នាំ២០០០ដោយក្រុមដែលជាអតីតអ្នកស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ (UNV) ដើម្បីបន្តការសំរបសំរួលសកម្មភាពសហគមន៍ ។ អង្គការនេះចេញពីគំរោងកម្មវិធីអ្នកស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិដើម្បីការចូលរួមនៅក្នុងសហគមន៍ប្រកបដោយចេរភាពនៅក្នុងខឡានអង្គរ ។ គំរោង APDO ដែលទាក់ទងនឹងការអប់រំបរិស្ថានគឺការអភិវឌ្ឍធនធានមនុស្សប្រកបដោយចេរភាព ។ គោលបំនងរបស់គំរោងនេះគឺ "ដើម្បីពង្រឹងសមត្ថភាពអ្នកនៅជនបទដើម្បីកាត់បន្ថយភាពក្រីក្រ និងគាំទ្រដល់ភូមិនូវការជំនឿចិត្តសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម វប្បធម៌ និងបរិស្ថាន" ។ សព្វថ្ងៃពួកគេផ្តោតការងារនៅក្នុងខេត្តសៀមរាប ។

***លោក តឹក សាកាន : នាយកអង្គការ***
អ៊ីម៉ែល:apdo@camintel.com
website: www.apdoangkor.org
០៦៣០ ក្រុម១២ ភូមិវត្តបូរ ឃុំសាលាកំរើក ខេត្តសៀមរាប

### អង្គការ បណ្តុះកុមារ

អង្គការបណ្តុះកុមារត្រូវបានផ្តួចផ្តើមដោយអង្គការក្រៅរដ្ឋាភិបាលបារាំងមួយហៅថា Partage និងបានដំណើរការតាំងពី ខែសីហាឆ្នាំ១៩៩៩ ។អង្គការនេះធ្វើការដើម្បីគាំទ្រលើថ្នាក់មតេយ្យ និងបឋមសិក្សា ។ អង្គការបណ្តុះកុមារមានលំដាប់នៃគំរោងអប់រំដូចជាការសង់សាលា ការជួសជុលរបង និងអាគារសាលាអនាម័យ (បង្គន់ស្រះអាងទឹក) អនាម័យផ្ទាល់ខ្លួនដូចជាការបណ្តុះបណ្តាលលើការអបរំសុខភាពសំរាប់សិស្ស និងគ្រូជាមួយសកម្មភាពធ្វើសួនបន្លែ និងការអនុវត្ត លើបរិស្ថានសាលារៀន ។ ពួកគេផ្តោតការងារ នៅក្នុងខេត្តពោធិ៍សាត់ កណ្តាល កំពង់ស្ពឺ និងខេត្តតាកែវ ។

***លោក គង់ សារុំ : នាយកអង្គការ***
ទូរស័ព្ទ: ២១៦ ០២៣ ហ្វេក ២១៥ ៥៩១
អ៊ីម៉ែល: bondoskomar@camnet.com.kh
ផ្ទះលេខ៦ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១
ខណ្ឌចំការមន ក្រុងភ្នំពេញ

## អង្គការ ព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ~ BFD

អង្គការនេះបង្កើតដោយលោក អ៊ឹនដាប៉ាណូ ប៊ីក លោក ហេង មន្នីចិន្តា និងក្រុមព្រះសង្ឃនៅឆ្នាំ១៩៩០នៅជំរុំសាយធូ (ព្រំដែនកម្ពុជាថៃ)។ អ្នកទាំងនេះបានឃើញពីតំលៃវិស័យព្រះពុទ្ធសាសនាជាវិធីសាស្រ្តសំរាប់ស្តារសន្តិភាព និងបង្រួបបង្រួមជាតិ ការអភិវឌ្ឍសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម ការអភិវឌ្ឍ សតិបញ្ញា ការអភិវឌ្ឍ ភាពឆ្លាតវៃ និងតុល្យភាព ចេរភាពនៃផ្នែកឯកជន សង្គម និងធម្មជាតិ។ ការិយាល័យអន្លង់វិលនៅខេត្តបាត់ដំបង បានក្លាយជាការិយាល័យកណ្តាលរបស់អង្គការនេះ។ ទិសដៅរបស់ពួកគេ គឺដើម្បីទទួលបានការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រជាជនកម្ពុជានិរវេតាមរយៈគំរោងបណ្តុះបណ្តាលផ្តល់ព្រឹក្សា និងការចូលរួម។ គំរោងរបស់អង្គការនេះ ដែលទាក់ទងខ្លាំងនឹងការអប់រំបរិស្ថានគឺបរិស្ថាន និងសិទ្ធមនុស្ស។ សព្វថ្ងៃពួកគេផ្តោតការងារនៅក្នុង ខេត្តបាត់ដំបង បន្ទាយមានជ័យ ភ្នំពេញ ប៉ៃលិន សៀមរាប កំពង់ធំ និងខេត្តព្រះវិហារ។

***លោក ហេង មុន្នីចិន្តា : នាយកអង្គការ***

*ទូរស័ព្ទ: ០៥៣ ៣៧០ ០៤១*
*អ៊ីម៉ែល:* bfdkhmer@camintel.com
website: www.bfdkhmer.org
*វត្តអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង*

## អង្គការ ព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ខេត្តកំពង់ធំ ~ BFDK

ព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍខេត្តកំពង់ធំបានបង្កើតឡើងនៅឆ្នាំ១៩៩៧ និងបានចុះឈ្មោះជាអង្គការក្រៅរដ្ឋាភិបាលនៅឆ្នាំ ២០០០។ ការងាររបស់គេផ្តោតលើសកម្មភាពសំរបសំរួលដែលនាំទៅរកការកាត់បន្ថយភាពក្រីក្រនៅតំបន់គោលដៅ។ តំបន់គោលដៅរបស់គេគឺបណ្តាឃុំនៅខេត្តកំពង់ធំ និងក្នុងការិយាល័យកណ្តាលដែលមានទីតាំងនៅទីរួមខេត្តកំពង់ធំ និងគំរោងសព្វថ្ងៃដែលទាក់ទងនឹង ការអប់រំបរិស្ថានរួមមាន កសិកម្មសរីរាង្គ និងសហគមន៍ព្រៃឈើ។ លោក លីខុម បានចាប់ផ្តើមសកម្មភាពនៅ វីរ យើរ នៅឆ្នាំ១៩៩៧ រួមនឹងការបង្កើតក្រុមសង្គ្រោះនៅក្នុងភូមិបី ធានាគារស្រូវ និងវត្តដែលមានការបំបួសដើមឈើ។ គំរោងអង្គការនេះដែលទាក់ទងខ្លាំងជាមួយ ការអប់រំបរិស្ថានគឺសហគមន៍ព្រៃឈើ កសិកម្មសុខភាពបឋម ក្រុមជួយខ្លួនឯង វិមជ្ឈការសមាគមន៍ ក្រុមយុវជន និងព្រះសង្ឃ។ ការងាររបស់គេ បច្ចុប្បន្នធ្វើនៅខេត្តកំពង់ធំ។

***លោក លី ខុម : នាយកអង្គការ***

*ទូរស័ព្ទ: ០១២ ៧៣៤ ៤៦៧*
*អ៊ីម៉ែល: ០១២៧៣៤៤៦៧*@mobitel.com.kh
*ផ្លូវជាតិលេខ ៦ ខេត្តកំពង់ធំ*

## សហគមន៍អភិវឌ្ឍសេដ្ឋកិច្ច ~ CED

សហគមន៍អភិវឌ្ឍសេដ្ឋកិច្ចគឺជា អង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តក្រចេះ។ អង្គការនេះបានចុះឈ្មោះជាមួយ ក្រសួងមហាផ្ទៃនៅឆ្នាំ ២០០៣។ សព្វថ្ងៃវាគ្របដណ្តប់លើតំបន់គោលដៅនៃភូមិចំនួន ៧ភូមិ ១៦ឃុំ និង៤ស្រុក នៃខេត្តក្រចេះ។ គោលបំណងរបស់គេគឺ ដើម្បីធ្វើអោយប្រសើរឡើងនូវការកសាងសមត្ថភាពនៃការការពារធម្មជាតិ និងអប់រំប្រជាជនស្តីពីព្រៃឈើ សត្វព្រៃ ជលផល និងការគាំទ្រសហគមន៍ព្រៃឈើ និងការការពារធម្មជាតិ សហគមន៍អភិវឌ្ឍសេដ្ឋកិច្ចនេះបានបង្កើតកម្មវិធីរួមមាន ការអប់រំក្នុងប្រព័ន្ធ ការអប់រំសុខភាព និងការបញ្ចូលការថែទាំសត្វនិងកសិកម្ម។ កម្មវិធីផ្សេងទៀតមានការការពារធនធានធម្មជាតិ និងការកសាងសមត្ថភាពនៅថ្នាក់ទីប្រឹក្សាឃុំ និងប្រជាជនក្នុងសហគមន៍។

***យស ភារី : ក្រុមសំរបសំរួល***

*អ៊ីម៉ែល :* cedcam@camintel.com
*ផ្លូវ ៣ ត្រពាំងព្រីង ខេត្តក្រចេះ*

## សមាគមថែរក្សាបរិស្ថាន និងវប្បធម៌~CEPA

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌បានបង្កើតឡើងនៅឆ្នាំ ១៩៩៥ និងត្រូវបានចុះឈ្មោះជា អង្គការក្រៅរដ្ឋាភិបាលនៅឆ្នាំ ១៩៩៦។ គោលបំណងគឺ "ដើម្បីផ្តល់លើវគ្គបណ្តុះបណ្តាលលើគោលគំនិតនៃការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិសំរាប់ការចូលរួមពីមហាវិទ្យាល័យ អង្គការក្រៅរដ្ឋាភិបាលនិងស្ថាប័នរដ្ឋ"។ តំបន់គោលដៅមាននៅក្រុងភ្នំពេញ និងខេត្តស្ទឹងត្រែងដែលការិយាល័យធំឋិតនៅក្រុងភ្នំពេញ។ គំរោងបច្ចុប្បន្នដែលទាក់ទងនឹងការអប់រំបរិស្ថានគឺ សហគមន៍ព្រៃឈើ សហគមន៍នេសាទ បណ្តាញគំរោងសេសាន កម្មវិធីតស៊ូមតិសំរាប់ទន្លេដោយផ្អែកលើ ការគ្រប់គ្រងគំរោងបណ្តុះបណ្តាលសកម្មជនបរិស្ថាន និងគំរោងការប្រកបរបរចិញ្ចឹមជីវិតដែលប្រកបដោយចេរភាព។ ការងាររបស់គេផ្តោតនៅក្នុងក្រុងភ្នំពេញ និង ខេត្តស្ទឹងត្រែង។

***លោក ទេព ប៊ុណ្ណារិទ្ធិ : ប្រធានសមាគម***

*ទូរស័ព្ទ/ទូរសារ: ០២៣*
*៣៦៩ ១៧៩/៧២០ ០៦២*
*អ៊ីម៉ែល:* cepa@online.com.kh
website: http://www.cepa-cambodia.org/
*ផ្ទះលេខ ៤០ ផ្លូវ ៣៥២ សង្កាត់បឹងកេងកង ខណ្ឌចំការមន ក្រុងភ្នំពេញ*

## មជ្ឈមណ្ឌលសហគមន៍អប់រំច្បាប់~CLEC

អង្គការនេះជាអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់នូវសេវាកម្មច្បាប់ផ្សេងៗដូចជាការអប់រំ ការតស៊ូមតិ និងសេវាច្បាប់ជាច្រើនទៀតទៅកាន់ប្រជាជនកម្ពុជា។ វាបានបង្កើតឡើងនៅឆ្នាំ១៩៩៦ក្នុងនាមជាមជ្ឈមណ្ឌលធនធានច្បាប់ដើម្បីលើកកំពស់តួនាទីច្បាប់ យុត្តិធម៌ និងប្រជាធិបតេយ្យនៅកម្ពុជា។ ចាប់ពីឆ្នាំ១៩៩៦-២០០១

អង្គការនេះដំណើរការក្នុងនាមជាមហាវិទ្យាល័យច្បាប់សានហ្វ្រានស៊ីស្កូដែលផ្តល់ថវិកាដោយ USAID ។ នៅឆ្នាំ២០០២វាបានក្លាយជាអង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ ។ អង្គការនេះបច្ចុប្បន្នកំពុងចាប់ដំណើរការលើគំរោងធំមួយ ដើម្បីទទួលនូវការគស្ទឹមតិតាមផ្លូវច្បាប់របស់សាធារណៈជនជាពិសេសទៅលើផ្នែកធនធានដី និងធនធានធម្មជាតិ ។ គោលបំណងរបស់ពួកគេគឺ "ដើម្បីកសាងសមត្ថភាពនៃការប្រើប្រាស់ធនធានដី និងធនធានធម្មជាតិតាមផ្លូវច្បាប់សំរាប់ប្រជាជនកម្ពុជា" ។ គំរោងដែលទាក់ទងខ្លាំងនឹងការអប់រំបរិស្ថានគឺធនធានដី និងធនធានធម្មជាតិ ។បច្ចុប្បន្នគេផ្តោតការងាររបស់ពួកគេនៅក្នុងខេត្តរតនគិរី និងមណ្ឌលគិរី ។

**លោក យេង វីរៈ : នាយកអង្គការ**
ទូរស័ព្ទ: ២១១ ៧២៣
អ៊ីម៉ែល: clec@online.com.kh
គេហទំព័រ : http://www.bsigpond.com.kh
ផ្ទះលេខ៥៦ ផ្លូវ៣០៦ សង្កាត់បឹងកេងកង១ ក្រុងភ្នំពេញ

## អង្គការសហគមន៍កែច្នៃឡើងវិញ និងអនាម័យ_CSARO

អង្គការនេះបានបង្កើតនៅឆ្នាំ១៩៩៧ នៅទីក្រុងភ្នំពេញដោយក្រុមដែលគិតគូរពីស្ថានភាពបរិស្ថាន និងការរស់នៅរបស់ជនក្រីក្រនៅក្នុងទីប្រជុំជន ។ គោលបំណងរបស់ពួកគេគឺ "ដើម្បីធ្វើអោយប្រសើរឡើងនូវស្ថានភាពនៃការតាំងទីលំនៅរបស់គ្រួសារកម្ពុជានៅក្នុងទីក្រុងភ្នំពេញដោយលើកកំពស់លើស្តង់ដារអនាម័យសុខភាព និងបរិស្ថាន និងដោយធ្វើការផ្តល់ឱកាសដល់សង្គមថ្មី និងសេដ្ឋកិច្ចសំរាប់អ្នកទាំងនោះនៅក្នុងការគ្រប់គ្រងសំណល់រឹង" ។ គំរោងរបស់អង្គការនេះដែលពាក់ព័ន្ធខ្លាំងជាមួយការអប់រំបរិស្ថាន គឺធនធានធម្មជាតិ និងបរិស្ថាន ។ ពួកគេធ្វើការផ្តោតនៅក្នុងក្រុងភ្នំពេញ ។

**លោកហេង យូគូវ៉ា : ប្រធានកម្មវិធី**
ទូរស័ព្ទ/ទូរសារ: ០២៣ ២១១ ១១៦
អ៊ីម៉ែល: csaro@online.com.kh
គេហទំព័រ : http://bigpond.com.kh
៧១ ផ្លូវ៣៦៨/១៦៣ សង្កាត់ទួលស្វាយព្រៃ១ ខ័ណ្ឌចំការមន

## សមាគមអភិវឌ្ឍន៍កម្ពុជា_DAC

គណៈកម្មាធិការអចិន្ត្រៃយ៍ ៥រូបបានចាប់ផ្តើមនៅឆ្នាំ១៩៩៨ និងចុះឈ្មោះនៅក្នុងក្រសួងមហាផ្ទៃនៅឆ្នាំ១៩៩៩ ។ សមាគមន៍នេះបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំ យុវជន និងកីឡាលើកិច្ចសហការសំរាបការអប់រំក្រៅប្រព័ន្ធ ។ គោលបំនងរបស់គេគ "ដើម្បីផ្តល់ការបណ្តុះបណ្តាល ការអប់រំវិជ្ជាជីវៈលើបរិស្ថាន ប្រជាធិបតេយ្យ និងសិទ្ធមនុស្ស" ។ គំរោងដែលទាក់ទងខ្លាំងនឹងការអប់រំបរិស្ថានមាន បរិស្ថាន និងធនធានធម្មជាតិ ។ ពួកគេផ្តោតការងារនៅខេត្តពោធិ៍សាត់ ។

**លោកស្រី ប៉ូ ទៀង : ប្រធានសមាគម**
ទូរស័ព្ទ: ០១៦ ៥៥៥ ១៨៤/០១២៩២៣ ៦៨២
អ៊ីមែល: potiengdac@yahoo.com
គីឡូ ៦ ផ្លូវលេខ ២១៨/១៨៣ សង្កាត់បឹងព្រលិត ខ័ណ្ឌ ៧ មករា ក្រុងភ្នំពេញ

## កម្មវិធីអភិវឌ្ឍន៍សំរាប់សិស្សខ្មែរ_DPDS

កម្មវិធីអភិវឌ្ឍន៍សំរាប់សិស្សខ្មែរត្រូវបានបង្កើតឡើងដោយអ្នកជំនាញនៅក្នុងផ្នែកការអប់រំ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយការអប់រំសុខភាព និងសិទ្ធិកុមារ ។ ពួកគេមានចំណាប់អារម្មណ៍លើការគាំទ្រកុមារ និងយុវជនដែលមានលទ្ធភាពតិចតួចនៅក្នុងការទទួលបានសិទ្ធិ ។ វាត្រូវបានចុះឈ្មោះជាមួយអជ្ញាធរខេត្ត និងក្រសួងមហាផ្ទៃនៅឆ្នាំ២០០០ ។ គោលបំណងរបស់ពួកគេគឺ ដើម្បីចូលរួមនៅក្នុងការអប់រំ និងការការពារបរិស្ថាន" ។ គំរោងកម្មវិធីអភិវឌ្ឍន៍សំរាប់សិស្សខ្មែរដែលទាក់ទងខ្លាំងជាមួយ ការអប់រំបរិស្ថានរួមមាន សហគមន៍ព្រៃឈើនិងការការពារបរិស្ថាន ។

**លោក ឡូវ ប៊ុនលៀង : នាយកគំរោង**
ទូរស័ព្ទ/ទូរសារ: ០៩២ ៩៣២ ៦៥៤
អ៊ីម៉ែល: dpkspur@yahoo.com
ផ្ទះលេខ៨៤៤ ភូមិផ្សារចាស់ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់

## អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន_EPDO

អង្គការអភិវឌ្ឍ និងការពារបរិស្ថានត្រូវបានបង្កើតនៅឆ្នាំ១៩៩៨ ជាមួយការគាំទ្រពីអង្គការជាតិ និងអន្តរជាតិនៅក្នុងខេត្តពោធិ៍សាត់ និងប្រជាជនដែលចែករំលែកគោលបំណងនៃការចូលរួមលើកទឹកចិត្តលើសមាជិកសហគមន៍នៅក្នុងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ និងចែករំលែកទៅដល់ប្រជាជនក្រីក្រនៅតាមទីជនបទ ។ នៅ៥ឆ្នាំមុនអង្គការអភិវឌ្ឍ និងការពារបរិស្ថានបានបង្កើនបទពិសោធន៍នៅក្នុងការងារអភិវឌ្ឍដែលទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ ។ គោលបំនងរបស់ពួកគេគឺ "ដើម្បីជំរុញកម្មវិធីនៅក្នុងតំបន់ផ្សេងទៀតនៅក្នុងតំបន់នានា ក្នុងខេត្តពោធិ៍សាត់ និងក្នុងប្រទេសកម្ពុជាទាំងមូលតាមរយៈ ការចែករំលែកចំណេះដឹង និងបទពិសោធន៍ជាមួយអ្នកធ្វើការនៅក្នុងតំបន់ និងអ្នកធ្វើការអភិវឌ្ឍដែលមានការចាប់អារម្មណ៍លើការងារ នៃអភិបាលកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ" ។ គំរោងរបស់អង្គការអភិវឌ្ឍ និងការពារបរិស្ថានដែលទាក់ទងនឹង ការអប់រំបរិស្ថានរួមមានសហគមន៍អភិវឌ្ឍព្រៃឈើ សុវត្ថិភាពការអភិវឌ្ឍ ការប្រកបរបរជីវិត និងការចូលរួមរបស់ប្រជាជននៅក្នុងលទ្ធិប្រជាធិបតេយ្យ ។ សព្វថ្ងៃពួកគេផ្តោតការងារនៅក្នុងខេត្តពោធិ៍សាត់ ។

**លោក អួត សំរិត : នាយកអង្គការ**
ទូរស័ព្ទ: ០១២ ៩៦២ ៦៣៥
ទូរសារ: ០៥២ ៩៥១ ៦៦៥
អ៊ីម៉ែល: epdopur@yahoo.com
ផ្ទះលេខ១០៨ ភូមិពាលនាក់ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់

## សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល_FACT

សម្ព័នភាពដើម្បីអភិរក្សធនធានជលផលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣ ដោយក្រុមមួយនៃសមាជិក អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារលើបញ្ហាជលផល និងបរិស្ថានជុំវិញបឹងទន្លេសាប ។

វាត្រូវបានបង្កើតក្នុងនាមជាផ្នែកមួយរបស់ក្រុមការងារផ្នែកជលផល របស់ NGO Forum និងត្រូវបានការគាំទ្របន្ថែមពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដូចជា Oxfam, the NGO Forum និងមូលនិធិយុត្តិធម៌បរិស្ថាន ។ នៅខែមករា ឆ្នាំ២០០៤ អង្គការសម្ព័នភាពដើម្បីអភិរក្សធនធានជលផលបានផ្តាច់ពី NGO Forum ។ សម្ព័នភាពដើម្បីអភិរក្សធនធានជលផលផ្តោតការងាររបស់គេលើបញ្ហាជលផល និងត្រួតពិនិត្យលើកំណែទំរង់គោលនយោបាយ ។ គំរោងរបស់សម្ព័នភាពដើម្បីអភិរក្សធនធានជលផលដែលទាក់ទងនឹងការអប់រំបរិស្ថានរួមមាន ការឃ្លាំមើលបឹងទន្លេសាប និងគំរោងផ្សេងៗ (ធនធានធម្មជាតិ និងបរិស្ថាន) ។ ការងាររបស់ពួកគេផ្តោតនៅជុំវិញបឹងទន្លេសាប និងនៅតាមតំបន់ឆ្នេរ ។

***លោក ម៉ក់ សិទ្ធិរិទ្ធ នាយកអង្គការ***

ទូរស័ព្ទ: ០២៣ ៩៩២ ០៤៤
អ៊ីម៉ែល: factpp@camnet.com.kh
គេហទំព័រ : www.fact.org.kh
ផ្ទះលេខ៧១ ផ្លូវ៥៩២ សង្កាត់បឹងកេងកង២ ខណ្ឌទួលគក ក្រុងភ្នំពេញ

## អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ_FAO

អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិជាទីភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិសំរាប់ស្បៀងអាហារ និងកសិកម្ម ។ គោលបំណងរបស់អង្គការស្បៀងអាហារ និងកសិកម្មនេះគឺដើម្បីលើកកំពស់កំរិតអាហាររូបត្ថមសំរាប់បង្កើននូវ ផលិតភាពកសិកម្ម ធ្វើឲ្យប្រសើរឡើងនូវការរស់នៅរបស់ប្រជាជនជនបទ និងចែករំលែកនូវការលូតលាស់សេដ្ឋកិច្ចពិភពលោក ។ គំរោងភាគច្រើនរបស់អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិដែលទាក់ទងនឹងការអប់រំបរិស្ថានរួមមាន ទិវាស្បៀងអាហារពិភពលោក ការបញ្ចូលការគ្រប់គ្រងសត្វល្អិត និងការគ្រប់គ្រងធនធានធម្មជាតិ ។ ផ្នែកដែលទាក់ទងខ្លាំងគឺសកម្មភាពអង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិដែលមានទីតាំងនៅខេត្តសៀមរាបដែលធ្វើការផ្តោតលើការអប់រំបរិស្ថាន និងបឹងទន្លេសាប ។ ពួកគេផ្តោតការងាររបស់គេជាមួយតំបន់គាលដៅជាក់លាក់ ។

***ទូរស័ព្ទ: ០២៣ ២១៦ ៥៦៦***

អ៊ីម៉ែល: fao@un.org.kh
គេហទំព័រ : http://www.fao.org
ផ្ទះលេខ៥ ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ក្រុងភ្នំពេញ

## អង្គការអនាគតកុមារកម្ពុជា_FCC

អង្គការអនាគតកុមារកម្ពុជាត្រូវបានបង្កើតឡើងនៅខែមករា ឆ្នាំ២០០០ក្នុងខេត្តសៀមរា និងត្រូវបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៅក្នុងខែសីហា ឆ្នាំ២០០០ ។ វាត្រូវបានបង្កើតឡើងក្នុងគោលបំណងបង្កើត និងបង្ហាញសិល្បៈស្បែកប្រើសិល្បៈខ្មែរបុរាណ និងជាពិសេសផ្តលការអប់រំកុមារ ។ គោលបំណងរបស់ពួកគេគឺ "ផ្តល់ការបណ្តុះបណ្តាលការអប់រំដល់កុមារលើសិល្បៈ និងវប្បធម៌" ។ គំរោងរបស់អង្គការអនាគតកុមារកម្ពុជា ដលទាក់ទងនឹងការអប់រំរួមមានល្ខោនស្បែកតូច និងការអប់រំដៃតូច និងការអប់រំតាមរយៈល្ខោនស្បែក ។ សព្វថ្ងៃគេផ្តោតការងាររបស់ពួកគេនៅក្នុងខេត្តសៀមរាប ។

***លោក ឃី មឿង : នាយកអង្គការ***

ទូរស័ព្ទ: ០១២ ៩២០ ៥០៦
អ៊ីម៉ែល: anakotkomar@hotmail.com
គេហទំព័រ : ww.h6.dion.ne.jp/fcc
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

## សហពន្ធ័អភិរក្សពិភពលោក_IUCN

សហពន្ធ័អភិរក្សពិភពលោកចាប់ផ្តើមការងាររបស់គេនៅឆ្នាំ១៩៤៨ ជាមួយគោលបំណងជាសកលដើម្បីលើកទឹកចិត្ត និងជួយដល់សង្គមនៅទូទាំងពិភពលោក ដើម្បីអភិរក្សបូរណៈភាពធម្មជាតិ និងជីវៈចំរុះនិងធានានូវគ្រប់ ការប្រើប្រាស់ធនធានធម្មជាតិអោយមានសមភាព និងចេរភាពអេកូឡូស៊ី ។ សហពន្ធ័ អភិរក្សពិភពលោកបានធ្វើការនៅកម្ពុជាចាប់ពីឆ្នាំ១៩៩២ ។ គោលបំណងរបស់ពួកគេគឺ ដើម្បីបង្កើតកម្មវិធីចេរភាពដីសើមសំរាប់ខេត្តស្ទឹងត្រែងដើម្បីអភិរក្សព្រៃកោងកាងនៅកម្ពុជាដើម្បីលើកកំពស់ការបកស្រាយ និងការយល់ដឹងលើលទ្ធផលនៃគណៈកម្មការពិភពលោកលើទំនប់វារីអគ្គិសនី និងដើម្បីបង្ហាញពី ការអភិវឌ្ឍ សេដ្ឋកិច្ចសង្គម និងតំបន់ការពារនៅក្នុងប្រទេសទាំងបួននៃតំបន់មេគង្គខាងក្រោម គំរោងរបស់សហពន្ធ័អភិរក្សពិភពលោកដែលទាក់ទងច្រើនជាមួយការអប់រំបរិស្ថានគឺ ការអភិរក្សបរិស្ថាន ។ ការងាររបស់គេគឺធ្វើនៅថ្នាក់ជាតិហើយពួកគេក៏មានសកម្មភាពតាមតំបន់ផងដែរ ។

***លោក ម៉ៅ កុសល : អ្នកសំរបសំរួលការបណ្តុះបណ្តាលពីដីសើមជាតិ***

ទូរស័ព្ទ: ០២៣ ២២២ ៣១១
ទូរសារ: ០២៣ ២១១ ៩៤៤
អ៊ីមែល: iucncambodia@online.com.kh
ផ្ទះលេខ២១ ផ្លូវ៣០៦ សង្កាត់បឹងកេងកង
ខណ្ឌចំការមន ក្រុងភ្នំពេញ

## អង្គការទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន_JICA

អង្គការទីភ្នាក់ងារសហប្រតិបត្តការអន្តរជាតិជប៉ុនបានបង្កើតការិយាល័យរបស់ខ្លួននៅកម្ពុជានៅឆ្នាំ១៩៩៣ ចាប់ពីពេលនោះមកបានអនុវត្តប្រកបដោយភាពរីជ្ជមានមួយចំនួនលើសហប្រតិបត្តិការបច្ចេកទេស និងប្រាក់ជំនួយលើសកម្មភាពដែលពាក់ព័ន្ធ។ គោលបំណងគន្លឹះមួយរបស់ពួកគេគឺ "ដើម្បីចូលរួមនៅក្នុងការគ្រប់គ្រងធនធានបរិស្ថាន" ។ គំរោងរបស់អង្គការទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ដែលទាក់ទងខ្លាំងនឹងបរិស្ថានគឺ ការគ្រប់គ្រងបរិស្ថាន ។ ពួកផ្តោតការងាររបស់ពួកគេបច្ចុប្បន្នធ្វើ ការគ្របដណ្តប់នៅក្នុងប្រទេសទាំងមូល ។

**លោក ជីរុ ជីតាពារែសិ តំណាងអង្គការ JICA នៅកម្ពុជា**

ទូរស័ព្ទៈ ០២៣ ២១២ ១៨២/០២៣ ២១១ ៦៧៣/
២១៧ ១២៩
ទូរសារៈ ០២៣ ២១១ ៦៧៥/០១៥ ៩១៣ ៦៣៩
អ៊ីម៉ែលៈ jica@online.com.kh
គេហទំព័រ : www.jica.org.kh
ផ្ទះលេខ៨៤០/៨៤៨E០ វិថីព្រះមុន្នីវង្ស
ខណ្ឌចំការមន ក្រុងភ្នំពេញ

## អង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន_L&L

អង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថានគឺជាអង្គការដែលមិនគិតកំរៃ និងជាអង្គការក្រៅរដ្ឋាភិបាលមួយដែលជំរុញលើការយល់ដឹងឲ្យកាន់តែទូលាយ និងធ្វើសកម្មភាពឆ្ពោះទៅកាន់ចេរភាពមនុស្សជាតិ និងបរិស្ថានតាមរយៈការពង្រឹងការអប់រំ និងការពិភាក្សា ។ អង្គការនេះទើបតែក្លាយជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយនៅឆ្នាំ២០០៥ នេះ ។ គោលបំណងរបស់គេគឺ "ដើម្បីបង្កើនការអភិរក្សនិងការយល់ដឹងពីបរិស្ថានតាមរយៈការអប់រំ ការបណ្តុះបណ្តាលការតស៊ូមតិ និងសេវាកម្មបរិស្ថានផ្សេងទៀតដើម្បីគាំទ្រលើការប្រើប្រាស់ដោយសមភាព និងចេរភាពលើធនធានធម្មជាតិសំរាប់ផលប្រយោជន៍កម្ពុជា" ។

អង្គការការអប់រំស្តីពីការរស់នៅជាមួយបរិស្ថានបច្ចុប្បន្នផ្តោតការងាររបស់គេទៅលើយុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិ ។ យុទ្ធនាការនេះត្រូវបានបង្កើតឡើងដោយក្រសួងបរិស្ថានដោយទុកជាផ្នែកមួយរបស់គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ។ នៅក្នុងយុទ្ធនាការនេះមានកម្មវិធីចំនួន៧គឺ

១, ធ្វើការពិនិត្យលើស្ថានភាពនៃការអប់រំបរិស្ថាន និងព័ត៌មានដែលមាន
២, ការកំនត់ក្រុមគោលដៅ
៣, ការអប់រំ និងផ្តល់ការយល់ដឹងដល់សហគមន៍
៤, ការអប់រំក្នុងប្រព័ន្ធ
៥, ការបោះពុម្ពផ្សាយពីសារៈសំខាន់បរិស្ថានបឹងទន្លេសាប
៦, ការត្រួតពិនិត្យ និងការវាយតំលៃ
៧, វេទិកាពិភាក្សាថ្នាក់ជាតិ ។

ការិយាល័យអង្គការនេះឋិតនៅទីក្រុងភ្នំពេញ និងពួកគេបានប្រមូលឯកសារបរិស្ថាន និងសំភារៈអប់រំបរិស្ថានអន្តរជាតិជាពិសេសទាក់ទងនឹងសកម្មភាពរបស់គេនៅក្នុងប្រទេសផ្សេងទៀត ។ បច្ចុប្បន្នពួកគេធ្វើការងារនៅក្នុងខេត្ត៥ នៅជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ បាត់ដំបង និងខេត្តសៀមរាប) ហើយអង្គការនេះក៏មានសកម្មភាពថ្នាក់ជាតិផងដែរ ។

**លោក គាត ប៊ុនថាន : មន្ត្រីអប់រំបរិស្ថាន**
**លោក ជុំ សំអូន : មន្ត្រីផ្នែកសារព័ត៌មាន**

ទូរស័ព្ទៈ ០២៣ ២២៤ ០៥៣
អ៊ីម៉ែលៈ livelearn@online.com.kh
គេហទំព័រ : http://www.idea.org.au/liveandlearn/
ផ្ទះលេខ៣៦៤ ផ្លូវមន្នីវង្ស ខណ្ឌចំការមន ក្រុងភ្នំពេញ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ_MAFF

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្វើការជាមួយក្រសួងបរិស្ថានដែលជាទីភ្នាក់ងារសំខាន់មួយសំរាប់សកម្មភាពនានាដែលទាក់ទងនឹងបរិស្ថាន ។ អ្វីដែលទាក់ទងនឹងការអប់រំបរិស្ថាននោះគឺនាយកដ្ឋានផ្សព្វផ្សាយកសិកម្មដែលបានធ្វើការបណ្តុះបណ្តាលបុគ្គលិកនៅក្នុងនាយកដ្ឋានព្រៃឈើ និងនាយកដ្ឋានជលផល ។ ដោយមានការបញ្ចូលគ្នាក្រុមនេះបានក្លាយជាក្រុមធំក្នុងជួរបុគ្គលិករដ្ឋាភិបាលដើម្បីឆ្ពោះទៅកាន់ការអប់រំបរិស្ថានទោះជាយ៉ាងណាពួកគេកំពុងឋិតនៅក្រោមការប្រើប្រាស់ដើម្បីឈានទទួលបានគោលបំណងខាងលើ ។

ទូរស័ព្ទៈ ០២៣ ២១១ ៣៥១
ទូរសារៈ ០២៣ ២១៧ ៣២០
អ៊ីម៉ែលៈ maff@everyday.com.kh
គេហទំព័រ : http://www.maff.gov.kh/
ផ្ទះលេខ២០០ មហាវិថីនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន ក្រុមភ្នំពេញ

## នាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន_MoE

នាយកដ្ឋានអប់រំ ព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន ឋិតនៅក្រោមក្រសួងបរិស្ថាន ។ តួនាទីរបស់នាយកដ្ឋាននេះគឺ "ដើម្បីផ្សព្វផ្សាយ និងផ្តល់ចំណេះដឹងពីបរិស្ថានដល់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេសទៅដល់សិស្ស និងគ្រូ មន្ត្រីជួរការ និងមិនជួរការ ព្រះសង្ឃ នយោជិក និងនយោជក និងប្រជាជនទូទៅតាមរយៈគោលបំណងផ្សេងៗ នៃប្រព័ន្ធអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធដើម្បីធានាថាធនធានធម្មជាតិ បាននឹងកំពុងគ្រប់គ្រង និងអភិរក្សដោយចេរភាពដែលឆ្លើយតបនឹងគោលនយោបាយ និងការគ្រប់គ្រងបរិស្ថានល្អ" ។ ពួកគេធ្វើការឋិតនៅក្នុងថ្នាក់ជាតិ ។

**លោក ស៊ុំ សាវុធ : ប្រធាននាយកដ្ឋាន**

ផ្ទះលេខ ៤៨ ផ្លូវសម្តេចព្រះសីហនុ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន ក្រុងភ្នំពេញ

## ការិយាល័យបណ្តុះបណ្តាល និង អប់រំបរិស្ថាន_MoE

ការិយាល័យបណ្តុះបណ្តាល និងអប់រំបរិស្ថានបានបង្កើតនៅឆ្នាំ១៩៩៨ និងជាផ្នែកមួយនៃនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងនៅក្នុងក្រសួងបរិស្ថាន ។ តួនាទីសំខាន់របស់វាគឺ „ដើម្បីផ្តួចផ្តើមសំរបសំរួល និងអនុវត្តលើកម្មវិធីអប់រំបរិស្ថាន និងសហការជាមួយស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ផ្នែកជំនួញ និងផ្នែកសាសនា និងសហគមន៍ក្នុងតំបន់ ។ ការងាររបស់គេមានលក្ខណៈជាតិ ។

**លោក រត្ន័ សិទ្ធ : ប្រធានការិយាល័យ**

ទូរស័ព្ទៈ ០២៣ ២១៦ ០១៩
ទូរសារៈ ០២៣ ២១២ ៥៤០
អ៊ីម៉ែលៈ eetoffice@yahoo.com
ផ្ទះលេខ ៤៨ ផ្លូវសម្តេចព្រះសីហនុ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន ក្រុងភ្នំពេញ

## មហាវិទ្យាល័យគរុកោសល្យ_MoEYS

មហាវិទ្យាល័យគរុកោសល្យគឺជាស្ថាប័នរដ្ឋដែលឋិតនៅក្រោមក្រសួងអប់រំ យុវជន និងកីឡា ។ មហាវិទ្យាល័យនេះមានគោលបំណង „ដើម្បីផ្តល់ការបណ្តុះបណ្តាលលើវិធីសាស្រ្តបង្រៀនទៅដល់សិស្សដែលទើបទទួលបរិញ្ញាបត្រដើម្បីពួកគេក្លាយជាគ្រូដ៏វការ” ។ បញ្ហាបរិស្ថានគឺត្រូវបានគេបញ្ចូលទៅក្នុងកម្មវិធីប្រចាំឆ្នាំដើម្បីផ្តល់ចំណេះដឹងគ្រឹះពីបរិស្ថានដល់សិស្សក្នុងគោលបំណងបញ្ចូលចំនេះដឹងនេះទៅក្នុងមុខវិជ្ជាជំនាញលើការបង្រៀនរបស់ពួកគេ ។ ការរួមបញ្ចូលកម្មវិធីអប់រំបរិស្ថាន ទៅក្នុងកម្មវិធីសិក្សានៅមហាវិទ្យាល័យគរុកោ-សល្យនេះគឺដើម្បីចែករំលែកដល់ការអភិវឌ្ឍធនធានមនុស្ស និងដើម្បីអភិរក្ស និងការពារបរិស្ថាន ។ ការងាររបស់គេឋិតក្នុងថ្នាក់ជាតិ ។

## ក្រសួងធនធានទឹក និងឧត្ដុនិយម_MoWRAM

ក្រសួងធនធានទឹក និងឧតុនិយម ធ្វើការរួមជាមួយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទីភ្នាក់ងារសំខាន់ៗសំរាប់សកម្មភាពនានាដែលទាក់ទងនឹងបរិស្ថាន ។ចំនុចដែលទាក់ទងនឹងការអប់រំបរិស្ថានគឺការពង្រីកសកម្មភាពដែលពួកគេកំពុងអនុវត្តឲ្យបានទូទាំងប្រទេស ។

ទូរស័ព្ទ: ០២៣ ៧២៤ ៣២៧/៨៨២ ១៦០
អ៊ីម៉ែល: mowram@cambodia.gov.kh
គេហទំព័រ : www.mowram.gov.kh
ផ្ទះលេខ៤៧ វិថីនរោត្តម ក្រុងភ្នំពេញ

## អង្គការ មូលបៃតង_Mlup Baitong

មូលបៃតងគឺ ជាអង្គការមួយក្នុងចំនោមអង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជាដែលផ្តោតលើការអប់រំបរិស្ថាន ។ អង្គការនេះបានបង្កើតដំបូងក្នុងនាមជាគំរោងមួយរបស់អង្គការក្រៅរដ្ឋាភិបាលអង់គ្លេសនៅឆ្នាំ ១៩៩៨ និងក្លាយជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនៅឆ្នាំ ២០០១ ។ គោលបំណងរបស់ពួកគេគឺ „ដើម្បីបង្កើនការអភិរក្ស និងការយល់ដឹងបរិស្ថានតាមរយៈការអប់រំ ការបណ្តុះបណ្តាល ការតស៊ូមតិ និងសេវាកម្មបរិស្ថានមួយចំនួនទៀតដើម្បីគាំទ្រដល់ការប្រើប្រាស់ធនធានធម្មជាតិដោយសមភាព និងចេរភាពសំរាប់ផលប្រយោជន៍ប្រទេសកម្ពុជា” ។ មូលបៃតងធ្វើការលើកម្មវិធី ១,កម្មវិធីគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ ២,កម្មវិធីបណ្តុះបណ្តាល និងអប់រំបរិស្ថាននៅសហគមន៍ និង ៣,កម្មវិធីសហគមន៍បរិស្ថាន ។ គំរោងបច្ចុប្បន្នរបស់អង្គការនេះដែលទាក់ទងទៅនឹង ការអប់រំបរិស្ថានគឺ គំរោងសហគមន៍ព្រៃឈើនៅខេត្តកំពង់ស្ពឺ គំរោងទេសចរណ៍ធម្មជាតិ គំរោងយេនឌ័រ និងបរិស្ថាន គំរោងព្រះពុទ្ធសាសនា និងបរិស្ថាន គំរោងសួនច្បារតាមផ្ទះ និងដាំដើមឈើ គំរោង សាលាក្លឹបបរិស្ថាន (Eco Club) មជ្ឈមណ្ឌលធនធានសំរាប់អប់រំបរិស្ថាន គំរោងតស៊ូមតិ និងវិទ្យុស្តីពីបរិ-ស្ថាន ។ ការិយាល័យកណ្តាលរបស់អង្គការនេះឋិតក្នុងក្រុងភ្នំពេញ ហើយពួកគេមានការប្រមូលសំភារៈអប់រំបរិស្ថាន និងឯកសារល្អៗ ។ បច្ចុប្បន្នគេផ្តោតការងារនៅក្នុងខេត្តកំពង់ស្ពឺ កំពង់ធំ និងសកម្មភាពថ្នាក់ជាតិខ្លះផងដែរ ។

**លោក វ៉ា មឿន : នាយកអង្គការ**
ទូរស័ព្ទ: ០២៣ ២១៤ ៤០៩
អ៊ីម៉ែល: mlup@online.com.kh
គេហទំព័រ : http:www.mlup.org
ផ្ទះលេខ ៣៧ ផ្លូវ ១១៣ សង្កាត់បឹងកេងកង២
ខណ្ឌចំការមន ក្រុងភ្នំពេញ

## វេទិកាអង្គការក្រៅរដ្ឋាភិបាលកម្ពុជា_NGO Forum

វេទិកាអង្គការក្រៅរដ្ឋាភិបាលកម្ពុជាកើតចេញពីយុទ្ធនាការអន្តរជាតិមួយដែលចាប់ផ្តើមនៅឆ្នាំ១៩៨៦ដើម្បីបញ្ចប់ការរឹបអូសជំនួយកម្ពុជា ។ ចំនុចផ្តោតរបស់គេចេញពីបញ្ហាអន្តរជាតិមកជាបញ្ហាជាតិ ការយកចិត្តទុកដាក់លើគោលនយោបាយ និងការគ្រប់គ្រងប្រកបដោយចេរភាពលើធនធានធម្មជាតិ ។ គោលបំណងគឺ "ដើម្បីអោយអង្គការក្រៅរដ្ឋាភិបាលធ្វើការសហការដើម្បីធ្វើអោយប្រសើរលើការអភិរក្ស និងការប្រើប្រាស់ប្រកបដោយចេរភាពដើម្បីផ្តល់ផលប្រយោជន៍ដល់ ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជន" ។ គំរោងវេទិកាអង្គការក្រៅរដ្ឋាភិបាលកម្ពុជាដែលទាក់ទងនឹងការអប់រំបរិស្ថានមាន ការយល់ដឹងពីបរិស្ថាន គំរោងទន្លេសេសាន និងការប្រកបរបរចិញ្ចឹមជីវិតនៅ ។ ពួកគេផ្តោតលើថ្នាក់ជាតិសំរាប់ការងាររបស់ពួកគេទាក់ទង និងព្រៃឈើ ។

**លោក រ៉ូសែល ភីតឺសិន : អ្នកតំណាងនៅក្នុងប្រទេស**
**អ្នកនាង ស៊ីន ស៊ីនិត : អ្នកតំណាងរង**
ទូរស័ព្ទ: ០២៣ ៩៨៦ ២៦៩
Web: http://www.ngoforum.org.kh/
ផ្ទះលេខ៩-១១ ផ្លូវ៤៧៦ សង្កាត់ទួលទំពូង១ ក្រុងភ្នំពេញ

## អង្គការ អូស្មូស_Osmose

អង្គការ អូស្មូស ត្រូវបានដំណើរការតាំងពីឆ្នាំ ១៩៩៩ ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ។ គោលបំនងរបស់គេគឺ ធ្វើការអប់រំ ផ្សព្វផ្សាយ និងអភិរក្សធនធានធម្មជាតិនៅជុំវិញបឹងទន្លេសាប ។ សកម្មភាពភាពរបស់ពួកគេធ្វើការផ្តោតលើការអប់រំទាំងផ្នែកនៃការអប់រំក្នុង និងក្រៅប្រព័ន្ធ រួមជាមួយ ការចុះអនុវត្តផ្ទាល់ ការផ្តោតលើទេសចរណ៍ធម្មជាតិ និងការអភិវឌ្ឍមូលដ្ឋានដោយសង្កត់ធន់លើកុមារក្រីក្រ ការអប់រំពីស្តីពីសុខភាព ផ្តល់ជាសំភារៈអប់រំបរិស្ថាន ផ្តល់វិជ្ជាជីវៈ ការគ្រប់គ្រងសំណល់ និងការបង្កើតសួនបណ្តែតទឹក ។ អង្គការអូស្មូសមានកម្មវិធីអប់រំបរិស្ថានសំរាប់សាលាបណ្តែតទឹក និងសាលាទូទៅផងដែរ ។ អង្គការនេះធ្វើការងាររបស់គេនៅក្នុងខេត្តសៀមរាប និងបាត់ដំបង ។ ការិយាល័យកណ្តាលរបស់គេឋិតនៅក្នុងខេត្តសៀមរាប ។

ទូរស័ព្ទ : ០៦៣ ៩៦៣ ៧១០/០១២ ៨៣២ ៨១២
អ៊ីម៉ែល : osmose@bigpond.com.kh
មជ្ឈមណ្ឌលសំរាំសនា ខេត្តសៀមរាប

## អង្គការព្រហ្មវិហារធម៌_PVT

អង្គការព្រហ្មវិហារធម៌បានបង្កើតឡើងនៅខែមករា ឆ្នាំ ២០០០ នៅស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។ អង្គការព្រហ្មវិហារធម៌ធ្វើការបង្កើនស្តង់ដានៃការរស់នៅរបស់ប្រជាជនតាមរយៈការធ្វើរូបចំលាក់ចិញ្ចឹមសត្វ ការដាំបន្លែ និងដើមឈើ ។ គោលបំណងរបស់អង្គការនេះគឺ "ដើម្បីចូលរួមក្នុងការគ្រប់គ្រងបរិស្ថាន និងការអភិវឌ្ឍសហគមន៍" ។ គំរោងរបស់អង្គការព្រហ្មវិហារធម៌ដែលទាក់ទងនឹងបរិស្ថានមានសហគមន៍ព្រៃឈើ កសិកម្មសិទ្ធិមនុស្ស ក្លឹបយុវជននិងអេដស៍ ។ គេផ្តោតការងាររបស់គេនៅក្នុងខេត្តពោធិ៍សាត់ ។

***លោក ខួន ណារីន : នាយកអង្គការ***

*ទូរស័ព្ទ: ០១២ ៥៨១ ០២២*
*អ៊ីម៉ែល:* pst-khounnarin.promvihearthor@cambodiacic.org
*ពាលនាក២ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់*

## អង្គការអភិវឌ្ឍន៍បរិស្ថាន និងសហគមន៍ជនបទ_RCEDO

អង្គការអភិវឌ្ឍបរិស្ថាន និងសហគមន៍ជនបទបានចុះឈ្មោះជាមួយក្រសួងមហាផ្ទៃនៅឆ្នាំ១៩៩៨ និងបានចុះឈ្មោះជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានៅឆ្នាំ២០០៣ ។ អង្គការអភិវឌ្ឍន៍បរិស្ថាន និងសហគមន៍ជនបទបានធ្វើការជាដៃគូនៃទំនាក់ទំនងជនបទនៅក្នុងតំបន់ទីប្រជុំជន និងតំបន់ដាច់ស្រយាលក្នុងខេត្តភាគឦសាន្តនៃប្រទេសកម្ពុជា ។ គោលបំណងគឺ "ដើម្បីផ្តល់ការធ្វើអណ្តូងទឹកនៅក្នុងខេត្តសៀមរាប និងឧត្តរមានជ័យ" ។ គំរោងរបស់អង្គការអភិវឌ្ឍន៍បរិស្ថាន និងសហគមន៍ជនបទដែលទាក់ទងនឹងការអប់រំមានការជីកអណ្តូង (ទឹក និងអនាម័យក្នុងខេត្តសៀមរាប) ការបញ្ចូលជំនាញសុវត្ថិភាពទឹកស្អាត ការអប់រំសុខភាព ។ គេផ្តោតការងាររបស់គេនៅក្នុងខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ ។

***លោក សម សិរីវឌ្ឍនា : នាយកអង្គការ***

*ទូរស័ព្ទ: ០៥៤ ៩៥៨ ៨៧០/០១២ ៨៣២ ៨៧០*
*អ៊ីម៉ែល:* rcedobmc@forum.org.kh
*ផ្ទះ ៥៩ ភូមិស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ*

## Room to Read

គោលបំណងរបស់ Room to Read ត្រូវបានផ្តល់ដល់កុមារដែលឋិតក្រោមឯកសិទ្ធិជាមួយឱកាសដើម្បីបង្កើននូវអំណោយយូរអង្វែងលើការអប់រំ ។ ដើម្បីបង្ហាញពីភាពខ្វះខាតលើរចនាសម្ព័ន្ធនៃការអប់រំដែលប្រឈមមុខនឹងកុមារកម្ពុជាប្រមាណ៦លាននាក់អង្គការ Room to Read បានចាប់ផ្តើមបង្កើតបណ្ណាល័យ និងបន្ទប់កុំព្យូទ័រនៅឆ្នាំ២០០២ ។ Room to Read បានបង្កើតបណ្ណាល័យដែលអាចអានបានពីភាសានៅក្នុងសាលា និងមជ្ឈមណ្ឌលសហគមន៍ ។ ពួកយើងបានចេញផ្សាយសៀវភៅជាភាសាខ្មែរ មជ្ឈមណ្ឌលជៀវភាសាខ្មែរ និងកញ្ចប់បរិច្ចាកសៀវភៅកុមារពីអ្នកនិពន្ធសហរដ្ឋអាមេរិក ។ បណ្ណាល័យរបស់យើងផ្តោតនៅក្នុងក្រុងភ្នំពេញ ខេត្តបាត់ដំបង និងខេត្តសៀមរាប ។ យើងក៏មានសង់ជាសាលាបង្កើតបន្ទប់ភាសា និងកុំព្យូទ័រនៅសាលាបឋមសិក្សា និងផ្តល់អាហាររូបករណ៍រយៈពេលវែងដល់កុមារី ។ ចំណងជើងមួយរបស់ពួកគេមានបញ្ចូលអត្ថន័យបរិស្ថានទៅក្នុងការរៀនសូត្រដើម្បីអានគឺ "ព្រៃឈើ....ជីវិតរបស់អ្នក..."

*អ៊ីម៉ែល:* Cambodia@roomtoread.org
Web: http://www.roomtoread.org/cambodia.html

## សាកលវិទ្យាល័យភូមិន្ទភ្នំពេញ_RUPP

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានដេប៉ាតឺម៉ង់វិទ្យាសាស្ត្របរិស្ថានដែលជាវិទ្យាស្ថានមួយសំរាប់អប់រំបរិស្ថាននៅកម្ពុជា ។ ដេប៉ាតឺម៉ង់នេះត្រូវបានបង្កើតឡើងនៅចុងឆ្នាំ១៩៩៩ និងបន្ទាប់មកវាត្រូវបានអនុញ្ញាតិដោយការចេញសេចក្តីប្រកាសពីក្រសួងអប់រំ យុវជន និងកីឡានៅឆ្នាំ២០០១ ។ វាផ្តល់នូវកំរិតបរិញ្ញាប័ត្រដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញក្នុងរយៈពេល៤ឆ្នាំដោយផ្តោតជាសំខាន់លើការគ្រប់គ្រងបរិស្ថាន ។ ជាមួយនឹងបទពិសោធន៍ដែលបានពីការអនុវត្តកម្មវិធីនេះរយៈពេល៥ឆ្នាំកន្លងមក សាកលវិទ្យាល័យភូមិន្ទភ្នំពេញកំពុងធ្វើផែនការដើម្បីបែកកម្មវិធីទៅតាមផ្នែកនីមួយៗការគ្រប់គ្រងធនធានធម្មជាតិ និងការសិក្សាពីបរិស្ថានទីក្រុង ។ បន្ថែមលើនេះទៀតដេប៉ាតឺម៉ង់នេះមានគោលបំណងនឹងធ្វើអោយប្រសើរឡើងនូវសមត្ថភាពនៅតាមមហាវិទ្យាល័យនៅក្នុងការបង្រៀន ការស្រាវជ្រាវអនុវត្តសកម្មភាពចុះទៅដល់មូលដ្ឋានជាមួយភ្នាក់ងាររដ្ឋាភិបាលនិងភ្នាក់ងារក្រៅរដ្ឋាភិបាលផ្សេងៗ ។ ជាមួយការគាំទ្រពីអង្គការ DANIDA សាកលវិទ្យាល័យ Roskilde និង AIT (វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ានដែលមានទីតាំងនៅប្រទេសថៃ) ដេប៉ាតឺម៉ង់នេះបានបង្កើតកម្មវិធីត្រួតពិនិត្យបរិស្ថានដែលមាន៣៣មុខវិជ្ជា ។ ក្រៅពីការបង្កើតកម្មវិធីសិក្សាដេប៉ាតឺម៉ង់បរិស្ថានបានអនុវត្តនូវវគ្គបណ្តុះបណ្តាលមួយចំនួនដូចជាការគ្រប់គ្រងសំណល់រឹង មូលដ្ឋាននៃការធ្វើផែនការគ្រប់គ្រងបរិស្ថានសំរាប់បុគ្គលិកផ្លូវការរបស់រដ្ឋាភិបាលនៅក្នុងប្រទេស ។ ជាងនេះទៀតដេប៉ាតឺម៉ង់នេះបានអនុវត្តគំរោងស្រាវជ្រាវមួយចំនួនដែលទាក់ទងនឹងប្រព័ន្ធគ្រប់គ្រងធនធានជលផលនៅបឹងទន្លេសាប (ផ្នែកមួយនៃបឹងទន្លេសាប) ។

***កញ្ញា វ៉ា ដានី : ប្រធានដេប៉ាតឺម៉ង់***
***លោក សៀក សូផាត : អនុប្រធាន***

*ទូរស័ព្ទ: ០១១ ៨៧៦ ០៣៧ ០១៦ ៥០៦ ៨៨៨*
*អ៊ីម៉ែល:*vadany@hotmail.com, usepam@everyday.com.kh
*បន្ទប់ ១១២ អគារសាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិថីសហព័ន្ធរុស្ស៊ី ក្រុងភ្នំពេញ*

## អង្គការសង្រ្គោះសត្វព្រៃ_SCW

អង្គការសង្រ្គោះសត្វព្រៃជាអង្គការមួយក្នុងចំនោមអង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជាដែលផ្តោតលើការអប់រំបរិស្ថាន ។ អង្គការនេះចាប់បង្កើតដំបូង និងក្លាយជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនៅខែមករា ឆ្នាំ២០០០ ។ គោលបំណងរបស់ពួកគេគឺ „ដើម្បីអភិរក្ស

និងការពារសត្វព្រៃ និងជំរករបស់វាតាមរយៈកម្មវិធីអប់រំបរិស្ថាន" ។ គំរោងរបស់អង្គការសង្គ្រោះសត្វព្រៃមាន ការយល់ដឹងពីបរិស្ថាន ការចេញផ្សាយការយល់ដឹងពីបរិស្ថាន និងដីវ៉ៃ ការបណ្តុះបណ្តាលថ្នាក់មូលដ្ឋានលើសិទ្ធិនៃការប្រកបរបរចិញ្ចឹមជីវិត និងសិទ្ធិលើធនធាន និងវិធីសាស្ត្រនៃការរួមបញ្ចូលការប្រកបរបរចិញ្ចឹមជីវិត ។ កម្មវិធីគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ ។ ការិយាល័យអង្គការនេះឋិតនៅទីក្រុងភ្នំពេញ និងពួកគេមានការប្រមូលនូវឯក-សារបរិស្ថាន និងសំភារៈសំរាប់អប់រំបរិស្ថានល្អៗ ។ ពួកគេធ្វើការផ្តោតនៅក្នុងខេត្តកំពត កោះកុង ពោធិ៍សាត់ ស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ឧត្តរមានជ័យ ហើយក៏មានសកម្មភាពថ្នាក់ជាតិខ្លះទៀត ។

### កញ្ញា លីម សូលីន : នាយិការអង្គការ

ទូរស័ព្ទៈ ០២៣ ២១១ ២៦៣
ទូរសារៈ ០២៣ ២២២ ០៣៦
អ៊ីម៉ែលៈ wildlife@online.com.kh
គេហទំព័រ : www.cambodiaswildlife.org
ផ្ទះលេខ២៧២ ផ្លូវ១៩៧/សង្កាត់បឹងព្រលិត ខណ្ឌ៧មករា ក្រុងភ្នំពេញ

## សមាគមសេវាកម្មសមណៈគ្មានព្រំដែន_SEA

SEA ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣ នៅវត្តសង្កែក្នុងទីរួមខេត្តបាត់ដំបង ។ សមាគមន៍នេះត្រូវបានចុះឈ្មោះនៅក្រសួងមហាផ្ទៃនៅឆ្នាំ២០០៤ ។ សមាគមន៍នេះត្រូវបានបង្កើតឡើងដើម្បីការចែករំលែកការផ្តល់អោយ និងការស្តារឡើងវិញនូវសុវត្ថិភាព និងសន្តិភាពជូនកម្ពុជាដោយធ្វើការផ្លាស់ប្តូរគំនិត អាកប្បកិរិយា និងការផ្តល់នូវសេវាកម្មបរិច្ចាកនៅក្នុងសាមគ្គីភាព និងដោយពង្រីកនូវសេចក្តីស្រលាញ់ដល់មនុស្សជំនាន់ចាស់ និងជំនាន់ថ្មីដែលមានជំងឺផ្លូវចិត្តដោយផ្តល់នូវទ្រព្យសម្បត្តិ យោបល់ គំនិត ពលកម្មដើម្បីជួយគ្នា និងដើម្បីដោះស្រាយបញ្ហា ។គោលបំណងរបស់សមាគមន៍នេះគឺ "ដើម្បីកាត់បន្ថយ និងការពារការបំពុល និងការបំផ្លាញបរិស្ថាន និងបន្ទាប់មកធ្វើការកែប្រែចំណេះដឹងលើការការពារបរិស្ថានអោយកាន់តែប្រសើរឡើង" ។

### លោក ផាន សុខហឿត-ប្រធានសមាគមន៍

ទូរស័ព្ទៈ ០១២ ៦៤៧ ៥៤១
ទូរសារៈ ០៣៥ ៨៥២ ៤៤៨
អ៊ីម៉ែលៈ phansokhoeut@yahoo.com
វត្តស្ទឹងសង្កែ ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង

## អង្គការ SIPAR

SIPARជាជំនួយឯកជនមួយដើម្បីជួយក្នុងការកសាងប្រទេសនៅអាស៊ីអាគ្នេយ៍ ។ ចាប់ពីឆ្នាំ១៩៩១អង្គការនេះបានបង្កើតបណ្ណាល័យចំនួន៧០ ។ បណ្ណាល័យចល័តនេះធ្វើដំណើរជុំវិញទីក្រុងភ្នំពេញក្នុងនោះបណ្ណារក្សត្រូវបានកំពុងបំពាក់បំប៉នចាប់ពីឆ្នាំ២០០០មក ។ កម្មវិធីសំរាប់ចេញផ្សាយសៀវភៅជាភាសាខ្មែរត្រូវបានបង្កើតក្នុងគោលបំណងផ្តល់នូវសៀវភៅដែលមានគុណភាពអប់រំល្អដែលចំណាយថវិការតិច ។ ក្រុមសៀវភៅដែលឋិតក្រោមចំណងជើង "ខ្ញុំចង់ដឹង..."មាន ជីវិតនៅជុំវិញបឹងទន្លេសាប ធម្មជាតិស្រុកយើង ដំណើរឡើងតាមដងទន្លេមេគង្គលើ យល់ដឹងពីភាគខាងត្បូង និងសមុទ្រកម្ពុជា លំហដំណើរផ្សងព្រេងគ្មានព្រំដែន ។ នៅខែកុម្ភៈ ឆ្នាំ២០០៣អង្គការនេះចេញសៀវភៅរឿងព្រះអង្គម្ចាស់តូចជាភាសាខ្មែរដោយមានការចូលរួមពីដេប៉ាតឺម៉ង់សិក្សាភាសាបារាំងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ ទិសដៅរបស់អង្គការនេះគឺដើម្បីជំរុញការអាននៅទូទាំងប្រទេសកម្ពុជា ។

ទូរស័ព្ទៈ ០២៣ ៩៨៧ ៩០៨
អ៊ីម៉ែលៈ siparpp@online.com.kh
ផ្ទះលេខ៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ

## អង្គការ ស្រែខ្មែរ

អង្គការ ស្រែខ្មែរនៅក្នុងការទទួលស្គាល់សិទ្ធិកសិករដើម្បីរៀនសូត្រប្រើប្រាស់ និងគ្រប់គ្រងធនធានសហគមន៍របស់គាត់ផ្ទាល់ និងចូលរួមក្នុងការសំរេចចិត្តក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់គាត់ដែលត្រូវបានផ្តល់អោយកសិករនូវឱកាសដើម្បីបង្កើនចំណេះដឹង និងពង្រឹងសមត្ថភាពក្នុងការដឹកនាំ និងគ្រប់គ្រងជីវិតរបស់ពួកគេតាមរយៈវិធីសាស្ត្រនៃការចូលរួមរៀនសូត្រដែលអាចកសាងនូវការយល់ដឹងពីទំនាក់ទំនងគោលរវាងកសិកម្ម បរិស្ថាន និងសង្គមជនបទ ។ អង្គការស្រែខ្មែរធ្វើការសហការជិតស្និតជាមួយក្រុមកសិករស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតដោយផ្អែកលើតំលៃនៃភាពស្មោះត្រង់ សមធម៌ ការលើកទឹកចិត្ត សមធម៌យេនឌ័រ និងការទទួលខុសត្រូវ ។

### លោក ប៉ូឡូ : នាយកអង្គការ

ទូរស័ព្ទៈ ០២៣ ២១០ ២១៧/០១២ ៩៤៤ ២៤០
អ៊ីម៉ែលៈ ipm.cambodia@bigpond.com.kh

## ស្ត្រីសន្តិភាពដើម្បីបរិស្ថាន_SSP

ស្ត្រីសន្តិភាពដើម្បីបរិស្ថានត្រូវបានកើតចេញជារូបរាងនៅខែកក្កដាឆ្នាំ២០០០ និងត្រូវបានចុះឈ្មោះនៅក្រសួងមហាផ្ទៃនៅឆ្នាំ២០០២ ។ អង្គការនេះចាប់ផ្តើមដោយការបង្រៀនសមាជិកសហ-គមន៍ពីការរស់នៅក្នុងតំបន់ព្រៃសម្បទាននៅ ខេត្តក្រចេះ មណ្ឌលគិរី និងខេត្តស្ទឹងត្រែងអំពីច្បាប់ព្រៃឈើជាពិសេសអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់ព្រៃសម្បទានដែលបានចែងក្នុងច្បាប់ ។ គោលបំណងរបស់អង្គការនេះគឺ „ដើម្បីអប់រំសមាជិកសហគមន៍ពីសារៈសំខាន់នៃព្រៃឈើ និងច្បាប់ព្រៃឈើ" ។ គំរោងរបស់អង្គការស្ត្រីដើម្បីសន្តិភាពដែលទាក់ទងនឹងការអប់រំបរិស្ថានគឺការអភិវឌ្ឍសហគមន៍ព្រៃឈើ ។ អង្គការនេះផ្តោតការងារបច្ចុប្បន្ននៅក្នុងខេត្តក្រចេះ មណ្ឌលគិរី និងខេត្តស្ទឹងត្រែង ។

### លោកស្រី អួច គីមណារី - អ្នកសំរបសំរួល

ទូរស័ព្ទៈ ០១២ ៦៧០ ១៨៨
អ៊ីម៉ែលៈ sp_org@yahoo.com
អូឬស្សី១ ខេត្តក្រចេះ

## អង្គការសហប្រជាជាតិសំរាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌_UNESCO

UNESCO គឺជាភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិសំរាប់ការអប់រំវប្បធម៌ វិទ្យាសាស្ត្រ និងទំនាក់ទំនង ។ UNESCO ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៥ "ដើម្បីជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងចំនោមរដ្ឋទាំង១៩០ទៅលើវិស័យអប់រំ វិទ្យាសាស្ត្រ វប្បធម៌ និងទំនាក់ទំនង "ប្រទេសកម្ពុជាបានចូលជាសមាជិក UNESCO នៅឆ្នាំ១៩៥១ ។ UNESCO វិធីសាស្ត្រអន្តរវិន័យ សំរាប់ការអប់រំបរិស្ថាន (EE) ជាចំនុចដែលការអប់រំបរិស្ថានមានបញ្ចូលនៅគ្រប់វិន័យ និងក្តោបយកគ្រប់កំរិត និងប្រភេទនៃការអប់រំបរិស្ថានដោយមានបញ្ចូលទាំងការសិក្សារយៈពេលវែង ។ សកម្មភាពនេះត្រូវបានធ្វើផែនការណ៍ និងអនុវត្តតាមរយៈកម្មវិធី និងផ្នែកមួយចំនួនជាមួយនឹងការរៀបចំ ពិសេសលើផ្នែកវិទ្យាសាស្ត្រ និងផ្នែកអប់រំ ។ គំរោង UNESCO ជាច្រើនមានការទាក់ទងនឹងការអប់រំបរិស្ថាន ។ អង្គការនេះផ្តោតការងាររបស់ពួកគេជាលក្ខណៈជាតិជាមួយនឹងតំបន់គោលដៅជាក់លាក់ ។


***លោកស្រី អ៊ីមកេ ហ្គីលស៊ីង : នាយកអង្គការ***

ទូរស័ព្ទ : ០២៣ ៤២៦ ៧២៦ /២១៧ ២៤៤

គេហទំព័រ : http://www.unesco.org

ផ្ទះលេខ ៣៨ វិថីព្រះសុទ្ធារស ភ្នំពេញ


## មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ_UNICEF

UNICEFគឺជាភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិសំរាប់កុមារ ។ UNICEF ត្រូវបានបង្កើតឡើងដើម្បីធ្វើការលើកកំពស់លើសុខភាពការអប់រំសមភាព និងការការពារដល់គ្រប់កុមារទាំងអស់ ។ កម្មវិធីរបស់ UNICEF នៅក្នុងប្រទេសកម្ពុជាធ្វើការបង្ហាញនូវការគំរាមកំហែងធន់ធរទៅសិទ្ធិកុមារ និងស្ត្រី ។ អាទិភាពចំបងនៃកម្មវិធីក្នុងស្រុករួមមានការធានាលើសិទ្ធិកុមារគ្រប់រូបដើម្បីទទួលបានការអប់រំដែលមានគុណភាពដោយធ្វើការបង្កើនឱកាសនៃការ ចូលរៀន និងកាត់បន្ថយនូវការបែងចែក និងគំលាតយេនឌ័រ អង្គការនេះមានការចូលរួមយ៉ាងសកម្មនៅក្នុងការអប់រំក្នុងប្រព័ន្ធនៅកម្ពុជា និងវិធីសាស្ត្រអប់រំសុខភាពដែលមានការពាក់ព័ន្ធខ្លាំងនឹងការអប់រំបរិស្ថាន ។


***លោក ឃឹតធីន ការីស្រ្តម : ជំនួយការមន្ត្រីកម្មវិធី***

ទូរស័ព្ទ : ០២៣ ៤២៦ ២១៤

ទូរសារ : ០២៣ ៤២៦ ២៨៤

គេហទំព័រ:http//www.unicef.org/infobycountry/cambodia.html

ផ្ទះលេខ ១១ ផ្លូវ៧៥ សង្កាត់ ស្រះចក ភ្នំពេញ


## ក្រុមគាំទ្រភូមិ_VSG

VSG ត្រូវបានចុះឈ្មោះជាមួយរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងគណកម្មាធិការសហប្រតិបត្តិការសំរាប់កម្ពុជា (CCC) នៅឆ្នាំ១៩៩៥។ ចាប់តាំងពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ១៩៩៦ VSG បានដំណើរការកម្មវិធីសុវត្ថភាពស្បៀង និងជំនឿនៅខេត្តបាត់ដំបង ។ ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០០ បានឈានទៅដល់សមាហរណកម្មគំរោងអភិវឌ្ឍន៍សហគមន៍ ។ គោលបំណងគឺ„ដើម្បីផ្សព្វផ្សាយចំណេះដឹង/ជំនាញអោយបានទូលំទូលាយរួមទាំងគំនិតផ្តួចផ្តើមលើការការពារបរិស្ថាននៅថ្នាក់សហគមន៍ ។ បច្ចុប្បន្នសកម្មភាពរបស់អង្គការនេះរួមមានសមាហរណកម្មគំរោងអភិវឌ្ឍសហគមន៍ ធនាគារស្រូវ ឥណ្ឌទានស្រែប្រាំង សួនបន្លែតាមផ្ទះ និងអាហាររូបត្ថម្ភ (និងការចិញ្ចឹមគោ) និងធ្វើលើបញ្ហាជលផលដែលកំពុងកើតមានហើយ VSG បានធ្វើការជាមួយបណ្តាញការងាររបស់អង្គការក្រៅរដ្ឋាភិបាលជាពិសេសជាមួយអង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល ។ គំរោងVSG ដែលទាក់ទងទៅនឹងការអប់រំបរិស្ថានគឺការអភិវឌ្ឍសហគមន៍នេសាទនៅពេលថ្មីៗនេះពួកគេផ្តោតការយកចិត្តទុកដាក់ទៅលើខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ។ គំរោងរបស់ SSP ដែលទាក់ទងនឹងការប់រំបរិស្ថាន គឺការអភិវឌ្ឍសហគមន៍ព្រៃឈើ ។


***លោក រស់ វណ្ណូលវីរ៉ែន : នាយកអង្គការ***

ទូរស័ព្ទ : ០១២ ៩១៥ ៥៤០/០៥៣ ៧៣០ ៣៥៥

អ៊ីម៉ែល : vsg@online.com.kh

ផ្ទះលេខ ១៧៧ ក្រុម ២១ កំពង់ក្របី ស្រុកស្វាយពោរ ខេត្តបាត់ដំបង


## អង្គការដីសើមអន្តរជាតិ

កម្មវិធីដីសើមអន្តរជាតិត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ បន្ទាប់មកបង្កើតទីតាំងភ្នំពេញនៅឆ្នាំ១៩៩៦ ។ សកម្មភាពនៅកម្ពុជាបានចាប់ផ្តើមជាមួយការបង្កើតបញ្ជាតិដីសើម និងជំនួយទៅរដ្ឋាភិបាលនៅការឈានទៅដល់អនុសញ្ញារ៉ាមសារ ។ កម្មវិធីអាងទន្លេមេគង្គក្រោមនៃតំបន់ដីសើមអន្តរជាតិបានកំពុងដំណើរការលើគំរោងនិទស្សន៍សំរាប់ការអភិវឌ្ឍន៍តំបន់គ្រប់គ្រងគំរោងផែនការណ៍ស្របច្បាប់ និងការអនុវត្តគោលការណ៍សំរាប់ខទ្យានជាតិរាមការអភិវឌ្ឍ និងនិទស្សន៍ នៃដំណើរការនៃការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រងខទ្យានជាតិរាម ។ គោលបំណងគឺ „ដើម្បីផ្សព្វផ្សាយ និងគាំទ្រការអភិរក្សតំបន់ដីសើម" ។ គំរោងរបស់អង្គការនេះដែលទាក់ទងនឹងការអភិរក្សតំបន់ដីសើមរួមមានផែនការការងារតំបន់ និងស្ថាប័ន និងការវាយតំលៃលើធនធានបរិស្ថាននៅទន្លេមេគង្គ និងសមិទ្ធផលសៀវភៅណែនាំពីបញ្ជីសារពើភណ្ឌស្តីពីដីសើមអាស៊ី ។អង្គការនេះផ្តោតការងាររបស់ពួកគេគឺទៅលើសារៈសំខាន់នៃដីសើមជាតិ និងនៅក្នុងតំបន់ទាំងមូល ។


***លោក ម៉ម កុសល : អ្នកសំរបសំរួលកម្មវិធី***

ទូរស័ព្ទ : 012 593 007 Fax: 023 211 944

អ៊ីម៉ែលៈ wetland@online.com.kh

ផ្ទះលេខ ២១ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង ខណ្ឌចំការមន ភ្នំពេញ

# របាយការណ៍ស្ថានភាពការអប់រំបរិស្ថាន
# ប្រទេសកម្ពុជា ២០០៥

## យុទ្ធនាការផ្សព្វផ្សាយ និងអប់រំបរិស្ថានថ្នាក់ជាតិ
## ក្រសួងបរិស្ថាន និង អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន

រៀបរៀងដោយ អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន
ផ្ទះលេខ ៣៦៤ ផ្លូវ មន្ទីរវិង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ
ប្រអប់សំបុត្រលេខ ៩១
ទូរស័ព្ទ : (៨៥៥) ២៣ ២២៤ ០៥៣
អ៊ីមែល : livelearn@online.com.kh

ខែ កុម្ភៈ ឆ្នាំ ២០០៦
ការរៀបរបាយការណ៍នេះគឺជាផ្នែកមួយនៃគំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP)
និង យុទ្ធនាការផ្សព្វផ្សាយ និង អប់រំបរិស្ថានថ្នាក់ជាតិ (NEEAC)

ចុះកិច្ចសន្យាដោយ ក្រសួងបរិស្ថាន
ឧបត្ថម្ភដោយ ធនាគារអភិវឌ្ឍន៍អាស៊ី ទឹកប្រាក់កំចីដែលមានលេខកូដ ១៩៣៩ CAM (SF)¦

និពន្ធដោយ លោក ដេឌី ស្មីត និង លោក គាត ប៊ុនថាន
បកប្រែដោយ កញ្ញា ពេជ្រ សុខដានី និង លោក គាត ប៊ុនថាន
ពិនិត្យកែសំរួលដោយ លោកបណ្ឌិត នៅ បោននីរ និង លោក ឡុង ខេង
បោះពុម្ពដោយ ម៉ងឃី ខាថូន
រៀបចំ និងរចនារូបភាពដោយ កញ្ញា ខារីន យ៉ាំង និង លោក សូរ សូវត្ថិ
រូបភាពដោយ លោក ជុំ សំអូន លោក រាជ សម្បត្តិ និង កញ្ញា អាឡិចសិនដ្រា ស៊ីវិនសាន់ និង កញ្ញា សុនចា អេនឌលវីបឺ
រក្សាសិទ្ធិដោយ ក្រសួងបរិស្ថាន និង អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន

សេចក្តីប្រកាស : របាយការណ៍នេះបានរៀបចំដោយទីប្រឹក្សា អង្គការ ការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន សំរាប់ក្រសួងបរិស្ថាន ។
លទ្ធផល ការបកស្រាយ និងការសន្និដ្ឋានដែលបានលើកឡើងនៅក្នុងនេះមិនចាំបាច់តំណាងឲ្យ ទស្សនៈរបស់ក្រសួងបរិស្ថាន រឺ
រាជរដ្ឋាភិបាលកម្ពុជាឡើយ ។
ក្រសួងបរិស្ថានមិនធានាលើសុក្រិត្យភាពទិន្នន័យដែលបានបញ្ចូលនៅក្នុងរបាយការណ៍នេះ និងមិនទទួលខុសត្រូវចំពោះផលវិបាកណាមួយ
នៃការប្រើប្រាស់សៀវភៅនេះឡើយ ។

## អង្គការអភិរក្សសត្វព្រៃ_WCS

អង្គការអភិរក្សសត្វព្រៃជាអង្គការអន្តរជាតិដ៏សកម្មមួយដែលកំពុងធ្វើការទៅលើការអភិរក្សសត្វព្រៃឈើនៅកម្ពុជាតាំងពីឆ្នាំ១៩៩៩មកម្លេះ ។ អង្គការនេះត្រូវបានបង្កើត និងក្លាយជាអង្គការក្នុងស្រុកនៅក្នុងខែមករាឆ្នាំ២០០០ ។ គោលបំណងអង្គការគឺ „មនុស្សលោកចង់មានទំនាក់ទំនងជិតស្និតទៅនឹងសត្វព្រៃ ហើយ អង្គអភិរក្សសត្វព្រៃផ្តល់នូវទំនាក់ទំនងដែលជាមធ្យោបាយ” ទស្សនៈអប់រំរបស់ពួកគេគឺ ”ដើម្បីនាំការអប់រំលើការអភិរក្សទៅកាន់ភាពលេចធ្លោជាងគេនៃការអប់រំវិទ្យាសាស្ត្រដែលធានាអោយមានការយល់ដឹងច្បាស់លាស់ពីកិច្ចការធម្មជាតិដែលវាជាសិទ្ធរបស់សិស្សវិទ្យាល័យគ្រប់រូប និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ៗនៅក្នុងសង្គមប្រជាធិបតេយ្យ” ។

បច្ចុប្បន្ន អង្គការអភិរក្សសត្វព្រៃ មានគំរោងធំចំនួន៣ នៅកម្ពុជា ទំនាបភាគខាងជើងតំបន់អភិរក្សជីវចំរុះសីមា និងបឹងទន្លេសាបវាក៏ផ្សារភ្ជាប់ជាមួយការអភិរក្សដទៃទៀតដែលទាក់ទងនឹងសកម្មភាពទាំងឡាយជុំវិញប្រទេស ។ ទីស្នាក់ការធំរបស់អង្គការស្ថិតនៅក្នុងភ្នំពេញ ហើយពួកគេមានការប្រមូលឯកសារសត្វព្រៃ និងបរិស្ថានដ៏ល្អៗ ។ បច្ចុប្បន្នអង្គការនេះផ្តោតសកម្មភាពរបស់ខ្លួននៅក្នុងវាលទំនាបភាគខាងជើងព្រៃបូណ៌នៅជុំវិញបឹងទន្លេសាប និងមានសកម្មភាពថ្នាក់ជាតិខ្លះផងដែរ ។

**លោក ស៊ុន វិសាល : មន្ត្រីគំរោង**

ទូរស័ព្ទ /ទូរសារ : 023 217 205 / 023 219 443

អ៊ីម៉ែល: Cambodia@wcs.org

គេហទំព័រ:http://www.wcs.org/international/Asia/Cambodia

ផ្ទះលេខ ២១ ផ្លូវ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ

## អង្គការអប់រំពិភពលោកកម្ពុជា_WEC

អង្គការអប់រំពិភពលោកកម្ពុជាបានធ្វើសកម្មភាពយ៉ាងសកម្មទៅលើការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាតាំងពីឆ្នាំ១៩៩២ ។ នៅដើមឆ្នាំ១៩៩០ អង្គការអប់រំពិភពលោកកម្ពុជាបានផ្តល់សេវាកម្មបណ្តុះបណ្តាលជាសំខាន់ទៅលើមនុស្សពេញវ័យ ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៩៨ មកពួកគេបានផ្តោតទៅលើការបណ្តុះបណ្តាលគ្រូ និងការអប់រំជាមូលដ្ឋាន ។ នៅកំរិតបឋមសិក្សាអង្គការមានសកម្មភាពដូចជាការអភិវឌ្ឍសំភារៈ និងកម្មវិធីសិក្សាព្រមទាំង ការបណ្តុះបណ្តាលគ្រូលើកិច្ចការទូទៅនៃការអប់រំបំនិនជីវិត ។ គោលបំណងរបស់ពួកគេគឺ „ដើម្បីបណ្តុះបណ្តាលនូវបំនិនជីវិត អភិវឌ្ឍ ជំនាញគ្រូលើចំនេះដឹងបង្រៀនកសិកម្ម និងវិទ្យាសាស្ត្របរិស្ថាន ជាពិសេសគាំទ្រកម្មវិធីវិធានការចំរុះក្នុងការគ្រប់គ្រងដំណាំនៅតាមសាលារៀន” ។ គំរោងរបស់អង្គការដែលមានការពាក់ព័ន្ធទៅនឹងការអភិរក្សតំបន់ដីសើមរួមមានការអប់រំបរិស្ថាន និងបំនិនជីវិត កម្មវិធីវិធានការចំរុះក្នុងការគ្រប់គ្រងដំណាំក្នុងសាលារៀន) ។ បច្ចុប្បន្នអង្គការនេះផ្តោតការងារនៅក្នុងខេត្តកំពង់ចាមនិងខេត្តព្រៃវែង ។

**លោក រីឆាត ហ្គៀវ : ប្រធានគំរោង វិធានការចំរុះក្នុងការគ្រប់គ្រងដំណាំ**

ទូរស័ព្ទ : 023 216 854 / 012 811 428 / 012 811 429

ទូរសារ : 023 218 369

អ៊ីម៉ែល: worldedcam@online.com.kh

គេហទំព័រ http://www.worlded.org/weiinternet/Projects/

ផ្ទះលេខ ៨៦ ផ្លូវ ២៩៤ សង្កាត់បឹងកេងកង ខ័ណ្ឌចំការមន ភ្នំពេញ

## អង្គការមូលនិធិពិភពលោកសំរាប់អភិរក្សធម្មជាតិ_WWF

អង្គការមូលនិធិពិភពលោកសំរាប់អភិរក្សធម្មជាតិជាអង្គការអភិរក្សអន្តរជាតិមួយដែលបានកំពុងធ្វើការនៅកម្ពុជាតាំងពីឆ្នាំ១៩៩៣មក ហើយបានបើកទីស្នាក់ការជាផ្លូវការណ៍នៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៩៨ ។ ទិសដៅរបស់អង្គការនៅក្នុងឥណ្ឌូចិនគឺ ”ដើម្បីធានាថាជីវចំរុះនៅកម្ពុជា ឡាវ និងវៀតណាមត្រូវបានការពារសំរាប់មនុស្សបច្ចុប្បន្ន និងមនុស្សជំនាន់ក្រោយ” ។ សកម្មភាពអភិរក្សរបស់ពួកគេផ្តោតលើតំបន់បួនសំខាន់ៗ

១.តំបន់ទេសភាពព្រៃឈើ ២.ស្ថានីយ៍ប្រព័ន្ធទឹកសាប

៣.ស្ថានប្រព័ន្ធសមុទ្រ និងឆ្នេរ និង

៤.ប្រភេទផ្សេងៗនៃពពួកសត្វ និងរុក្ខជាតិដែលកំពុងត្រូវបានចាប់អារម្មណ៍ជាពិសេស ។

គំរោងរបស់ពួកគេនៅកម្ពុជារួមមាន ការការពារនៃប្រភេទសត្វ និងរុក្ខជាតិចំបងនៅក្នុងវាលទំនាបទិសខាងកើត ការគ្រប់គ្រងតំបន់ជាយុទ្ធសាស្ត្រសំរាប់ការអភិរក្សចំរុះ ការផ្សព្វផ្សាយពីការគ្រប់គ្រងព្រៃឈើប្រកបដោយចេរភាព ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ និងការអភិរក្សព្រៃដោយការប្រើប្រាស់ប្រកបដោយចេរភាព ។ ពួកគេធ្វើការនៅខេត្តរតនៈគីរី មណ្ឌលគីរី កំពុងស្ពឺ ស្ទឹងត្រែង និងខេត្តក្រចេះ ។

**លោក សេង ទៀក : នាយកអង្គការ**

ទូរស័ព្ទ : ០២៣ ២១៨ ០៣៤

ទូរសារ :០២៣ ២១១ ៩០៩

អ៊ីម៉ែល: wwfcam@everyday.com.kh

គេហទំព័រ : http://www.wwfindochina.org/cambodia/

ផ្ទះលេខ២៨ ផ្លូវ៩ សង្កាត់ទន្លេបាសាក់ ភ្នំពេញ

## ការអប់រំដោយគ្មានការអនុវត្ត
## ដូចជាត្រីដែលគ្មានទឹក

*Education without action is like*
*a fish without water*